ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- តើយើងគួរផ្សះផ្សាប្រទេសជាតិទាំងមូលយ៉ាងដូចម្តេច
- សំណល់សង្គ្រាមនៅប្រទេសកម្ពុជា

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៩០ ខែតុលា ឆ្នាំ២០១៥

ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៩០ ខែតុលា ឆ្នាំ២០១៥

## មាតិកា


◆ តើយើងត្រូវផ្សះផ្សាប្រទេសជាតិទាំងមូល ..........១

**ផ្នែកឯកសារ**

◆ ចម្លើយសារភាពរបស់ យិន លន់ ហៅ សាវ៉ន ..........៣

◆ រៀនសូត្រពិសោធន៍សំខាន់ៗក្នុងការបំពេញភារកិច្ច ..........១០

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ វីរភាពស្ត្រីកម្ពុជា ៖ ក្តីសង្ឃឹម ..........២៥

◆ វត្ថុបុរាណក្នុងបញ្ជីដោះដូរទំនិញរវាងខ្មែរក្រហម និងថៃ ..........២៧

◆ អដ្ឋិធាតុមួយ បានជួបជុំគ្រួសារ ..........២៩

◆ ចាប់ពីរបបខ្មែរក្រហមដល់ឧប្បត្តិហេតុ ហាំបាលី ..........៣០

**ផ្នែកច្បាប់**

◆ សវនាការស្តាប់សក្ខីកម្ម និងថ្ងៃផុតកុំសោក ..........៤១

◆ សវនាការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹង ..........៤៣

**វេទិកាពិភាក្សាសាធារណៈ**

◆ សំណល់សង្គ្រាមនៅប្រទេសកម្ពុជា ..........៤៦

◆ និស្សិតខ្មែររៀននៅសកលវិទ្យាល័យ អកស៍ហ្វ៊ីដ..........៥០

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ រសាត់តាមខ្យល់ ..........៥៣




កងទ័ពជើងទឹករបស់សហរដ្ឋអាមេរិក ពិនិត្យមើលអដ្ឋិធាតុមិនស្គាល់អត្តសញ្ញាណ ដែលតម្កល់ទុកនៅវត្តលង្កា


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ០២៩១ពម.៩៩

ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



***ស្នេរលេខនេះ*** ៖ *សុខ វណ្ណៈ, សេង គន្ធី, អេង កុកថាយ, ស៊ុីវិ សារីណា, ញាណ សុជាតិ, ប៉ុក ប៉ុនសូម៉ាដ* ***អ្នកនិពន្ធនិងស្រាវជ្រាវ*** ៖ *ទាវ សារៈមុនិន្ទ* ***អ្នកបកប្រែ*** ៖ *សុភ័ក្ត្រ ភាណា* ***និពន្ធនាយកទូទៅ*** ៖ *ឆាំង យុ និង ញាណ សុជាតិ* ***ជំនួយការនិពន្ធនាយក*** ៖ *សោម ប៊ុនថន* ***ក្រាហ្វិកកុំព្យូទ័រ*** ៖ *សោម ប៊ុនថន* ***គ្រប់គ្រងការចែកផ្សាយ*** ៖ *ឆេង វើង និង សន ល័ក្ខ* Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# តើយើងត្រូវផ្សះផ្សាប្រទេសជាតិទាំងមូលយ៉ាងដូចម្តេច?

រដូវភ្ជុំបិណ្ឌបានមកដល់ ។ ជារៀងរាល់ឆ្នាំ ចាប់តាំងពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមដែលបានដួលរលំទៅក្នុងឆ្នាំ១៩៧៩ ប្រជាជនកម្ពុជាទាំងអស់ចាប់ផ្តើមប្រារព្ធពិធីនេះឡើងវិញជារៀងរាល់ឆ្នាំ នៅគ្រប់ទីវត្តអារាម ទាំងអស់ក្នុងប្រទេសកម្ពុជា ។ នរណាក៏ដឹងដែរថា មានប្រជាជនកម្ពុជាជាង២លាននាក់បានស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហម ។ គ្រួសារខ្ញុំក៏ដូចជាក្រុមគ្រួសារទាំងអស់នៅក្នុងប្រទេសកម្ពុជាទាំងមូល រួមទាំងព្រះមហាក្សត្រខ្មែរ សុទ្ធសឹងតែមានសាច់ញាតិដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម ។ នរណាក៏ដឹងទៀតដែរថា មានប្រជាជនជាង៣លាននាក់ ដែលបានរស់រានមានជីវិតពីរបបខ្មែរក្រហម ។ ក្នុងនេះ ក៏មានអតីតកម្មាភិបាលខ្មែរក្រហមជាច្រើន ដែលបានរួមគំនិតធ្វើឲ្យជីវិតមនុស្សជាច្រើនបានបាត់បង់ទៅ ។ នៅក្នុងពិធីបុណ្យភ្ជុំបិណ្ឌនេះ ទាំងអស់គ្នានៅក្នុងប្រទេសកម្ពុជាដែលមានប្រមាណ១៥លាននាក់នាបច្ចុប្បន្ន សុទ្ធសឹងតែជាជនរងគ្រោះ ដែលទទួលរងផលប៉ះពាល់ពីរបបខ្មែរក្រហមទាំងផ្លូវកាយ និងផ្លូវចិត្ត ។ ៣៥ឆ្នាំ ឬមួយជំនាន់មនុស្ស ទើបតែនឹងចាប់ផ្តើមកន្លងទៅ ។ នៅក្នុងរបត់នេះ តើយើងផ្សះផ្សាប្រទេសជាតិទាំងមូលយ៉ាងដូចម្តេច? សំណួរនេះបានចោទសួរតាំងពីឆ្នាំ១៩៧៩ មកម្ល៉េះ ហើយយន្តការជាច្រើនបានធ្វើឡើង ដើម្បីទទួលយកឲ្យបានផលប្រយោជន៍រួមមួយនេះ សម្រាប់ប្រជាជនកម្ពុជាទាំងអស់គ្នា ។

ខ្ញុំយល់ឃើញថា ការផ្សះផ្សាគឺជាដំណើរជាបុគ្គល និងក៏ជាបាតុភូតសមូហភាពដែរ ។ ជាការពិត ប្រសិនបើយើងទទួលស្គាល់ថា ការផ្សះផ្សាអាចសម្រេចបាន លុះត្រាតែកិច្ចការនេះចេញពីបេះដូង និងគំនិតរបស់បុគ្គលម្នាក់ៗ យើងនឹងដឹងថា វាគឺជាស្មារតីរបស់បុគ្គល ហើយគឺមិនមែនជាឆន្ទៈរួមនោះទេ ដែលជាគន្លឹះនៃសន្តិភាពក្រោយជម្លោះមួយក្នុងការជម្នះបាននូវអតីតកាលរបស់ខ្លួន ។ នៅពេលដែលខ្ញុំគិតអំពីរឿងនេះ ខ្ញុំនឹកឃើញទំនាក់ទំនងរវាងទន្លេសាប និងទន្លេមេគង្គ ។

ទន្លេសាប និងទន្លេមេគង្គមានលក្ខណៈពិសេសខុសពីគេនៅត្រង់ដំណើរនៃចរន្តខ្សែទឹករបស់ទន្លេទាំងពីរ ។ ទន្លេទាំងពីរប្រសព្វគ្នានៅខាងមុខព្រះបរមរាជវាំង នៅក្នុងរាជធានីភ្នំពេញ ។ នៅពេលដែលទន្លេទាំងពីរប្រសព្វគ្នា ទន្លេសាបមិនបានបាត់បង់នៅលក្ខណៈពិសេសរបស់ខ្លួននោះទេ ។ ដោយសារជំនន់ទឹកភ្លៀងដ៏ឆាប់រហ័សពីទន្លេមេគង្គ ទន្លេសាបបានក្លាយទៅជាប្រព័ន្ធធារាសាស្ត្រដ៏អច្ឆរិយមួយដែលប្រឆាំងទៅនឹងទំនាញផែនដី ដោយចរន្តទឹកហូរបញ្ច្រាសទៅលើចាក់ចូលទៅក្នុងបឹងដែលជាអាងទឹកសាបដ៏ធំបំផុតមួយនៅក្នុងពិភពលោក ។



កងដឹកជញ្ជូនដោយរថយន្តរបស់ក្រសួងសាធារណការ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលមានភារកិច្ចការពារខ្សែក្រវាត់ព្រំដែន ធ្វើដំណើរនៅលើផ្លូវទៅអន្លង់វែង ថតនៅពេលផុងជាប់រថយន្ត នៅឆ្នាំ១៩៨៥

ការផ្សះផ្សាប្រៀបបាន



កងដឹកជញ្ជូនដោយរថយន្តរបស់ក្រសួងសាធារណការ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលមានភារកិច្ចការពារខ្សែក្រវាត់ព្រំដែន ធ្វើដំណើរពីកំពង់ធំ ទៅស្រអែម ខេត្តព្រះវិហារ ។ ថតនៅពេលឈប់សម្រាក នៅខេត្តព្រះវិហារ នៅឆ្នាំ១៩៨៥

ទៅនឹងភាពប្រសព្វគ្នានៃទន្លេទាំងពីរដូច្នេះដែរ គឺមិនបានបំផ្លាញភាពជាបុគ្គលរបស់មនុស្សម្នាក់ៗនោះទេ ។ ផ្ទុយទៅវិញ ដូចជាទន្លេសាបដែរ ភាពប្រសព្វគ្នាបានក្លាយទៅជាកត្តាមួយដែលផ្តល់អំណាចទៅឲ្យបុគ្គលនៅក្នុងទម្រង់ទាំងឡាយដែលមិនអាចព្យាករណ៍បាន ។

ទោះបីជាយើងសម្លឹងមើលមកស្ថានភាពរបស់យើងក្នុងនាមជាបុគ្គល ឬជាសមូហភាព ការផ្សះផ្សាមានសារសំខាន់សម្រាប់ការរស់នៅប្រកបដោយសមភាព និងជីវិតដែលពេញលក្ខណៈ ។ យើងមិនអាចគេចវេះពីប្រវត្តិសាស្ត្ររបស់យើងបានទេ ហើយទោះបីជាយ៉ាងនេះក្តី ក៏យើងមិនត្រូវក្លាយទៅជាទាសករនៃប្រវត្តិសាស្ត្រនោះដែរ ។ ប្រវត្តិសាស្ត្រមានភាពគ្រួតស៊ីគ្នា ។ ជាញឹកញាយមនុស្សបានភ្លេចថា យើងមិនត្រូវបានដកចេញពីប្រវត្តិសាស្ត្រនៃសម័យខ្មែរក្រហមនោះទេ នៅពេលដែលមនុស្សជំនាន់មុនរបស់យើងត្រូវបានដកចេញពីប្រវត្តិសាស្ត្រនៃសម័យអាណានិគមបារាំង សង្គ្រាម និងភាពចលាចលសង្គម ។ ទោះបីជាយ៉ាងនេះក្តី ការផ្សះផ្សាផ្តល់ឲ្យយើងនូវផ្លូវមួយ ដែលយើងអាចចូលរួមចំណែកនៅក្នុងជោគជ័យជាសមូហភាពរបស់ប្រទេសកម្ពុជារបស់យើង ដោយមិនចាំបាច់លះបង់នូវផលប្រយោជន៍របស់បុគ្គល ក៏ដូចជាទន្លេសាប និងទន្លេមេគង្គដូច្នោះដែរ ។ យើងមិនបានបាត់បង់បុគ្គលភាពរបស់យើងទេ នៅពេលដែលយើងរួបរួមគ្នា ។ ផ្ទុយទៅវិញ នៅពេលដែលយើងទទួលស្គាល់គ្នាទៅវិញទៅមក យើងផ្តល់អំណាចទៅឲ្យជីវិតផ្ទាល់ខ្លួនទៅវិញទៅមកហើយចូលរួមចំណែកទៅដល់ប្រទេសកម្ពុជាទាំងមូល ។

នៅពេលដែលរដូវភ្ជុំបិណ្ឌនេះ បានកន្លងផុតទៅ ខ្ញុំសង្ឃឹមថា ការផ្សះផ្សានៅកម្ពុជា នឹងមានភាពរឹងមាំ និងអស្ចារ្យ ដូចជាបឹងទន្លេសាប ។ **ឆាំង យុ**

# ចម្លើយសារភាពរបស់ យិន លន់ ហៅ សាវន អនុប្រធានពេទ្យតំបន់២៣ បូព៌ា

***ដកស្រង់ចេញឯកសារចម្លើយសារភាពលេខ D២១២៧៧***

យិន លន់ ហៅ សាវន ភេទប្រុស អាយុ៣៥ឆ្នាំ កើតនៅភូមិមុខដា ឃុំមុខដា ស្រុករមាសហែក តំបន់២៣ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មុនពេលអង្គការចាប់ខ្លួន សាវន មាននាទីជាអនុប្រធានពេទ្យតំនប់២៣ ។ ប្រពន្ធឈ្មោះ អៀង សន ជាយុវនារីពេទ្យតំបន់២៣ ។ ខាងក្រោមនេះគឺជាសេចក្តីសង្ខេបចេញពីចម្លើយសារភាពរបស់ សាវនៈ

កាលពីក្មេង សាវន បានចូលរៀននៅសាលាបឋមសិក្សាមុខដា បានត្រឹមថ្នាក់ទី៩ ។ ដោយនៅសាលាបឋមសិក្សាគ្មានថ្នាក់រៀនបន្ត សាវនក៏បានទៅរៀនបន្តនៅសាលាបឋមសិក្សាវត្តជ្រៃធំ ក្នុងឆ្នាំ១៩៥៧ ហើយបានស្នាក់នៅជាមួយចៅអធិការវត្តវត្តជ្រៃធំ ព្រះនាម ចាន់ នួយ បច្ចុប្បន្នជាបុគ្គលិកជាងសំណង់នៅពាណិជ្ជកម្មភូមិភាគបូព៌ា ។ លោកគ្រូចៅអធិការវត្ត ចាន់ នួយ និងភិក្ខុ សាបិន ស្រឡាញ់ និងយកចិត្តទុកដាក់ចំពោះ សាវន ណាស់ ដូចជាឲ្យលុយចាយ ទិញសៀវភៅឲ្យរៀនសូត្រ កាត់ខោអាវឲ្យស្លៀកពាក់ជាដើម ។ ក្រោយមក នៅពាក់កណ្តាលឆ្នាំ១៩៥៨ នៅពេលអាយុបាន១៨ឆ្នាំ សាវន ត្រូវបានលោកគ្រូចៅអធិការវត្ត ចាន់ នួយ និងភិក្ខុ សាបិន លេខាឃុំអង្គប្រស្រែ ស្រុករមាសហែក (តំបន់២៣) អប់រំឲ្យចូលបម្រើក្នុងចលនាខ្មែរសេរី ឲ្យធ្វើជានីរសាររត់សំបុត្រសម្ងាត់យកទៅឲ្យខ្មែរយៈរបស់ខ្លួនឈ្មោះ សៅ សាគិត និង បាឡាត់ យ៉ែម ។

ឆ្នាំ១៩៥៩ ក្រោយសឹកពីបួស សាបិន បានយក សាវន មកនៅជាមួយ ។ បន្ទាប់មក សាបិន បានណែនាំ សាវន ឲ្យស្គាល់បក្ខពួកចំនួន៥នាក់ដែលជាខ្មែរយៈមានឈ្មោះ ឡុង ង៉ាន់ អតីតមេភូមិជ្រៃធំ ស្លាប់ឆ្នាំ១៩៧៣, ឈ្មោះ សាន់ ចូលបង្កប់ខ្លួនក្នុងជួរបដិវត្តន៍ដល់ឆ្នាំ១៩៧៦ ធ្វើគណៈឃុំកំពង់ត្រាច បច្ចុប្បន្នជាប្រធានកសិកម្មស្រុករមាសហែក, ឈ្មោះ អៀង មេភូមិម្រាម ស្លាប់ឆ្នាំ



មន្ទីរសន្តិសុខស-២១ ឬគុកទួលស្លែង (ក្រោយរបបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩ គុកនេះត្រូវបានផ្លាស់ឈ្មោះទៅជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង)

១៩៧០, ឈ្មោះ សាផាត អង្គការចាប់ខ្លួនហើយ និងឈ្មោះ ជុន ហៅ វិចិត ជាបុគ្គលិកសេដ្ឋកិច្ចតំបន់២៣ ។

ឆ្នាំ១៩៦០ សាវ៉ន ត្រូវបានឪពុកម្តាយយកមកបំបួសនៅវត្តម្រាម ។ ឆ្លៀតនៅក្នុងឱកាសនោះ សាបិន បានដាក់ផែនការឲ្យ សាវ៉ន ធ្វើសកម្មភាពកសាងកម្លាំង និងចលនាបំផុសលោកនៅក្នុងវត្តឲ្យប្រឆាំងនឹងពួកខ្មែរក្រហម, តាមដានរាល់សភាពការណ៍ និងសកម្មភាពរបស់ខ្មែរក្រហម ហើយបានខទ្ទេសនាមឲ្យស្គាល់ខ្សែរយៈបីនាក់ទៀត ងាយស្រួលទាក់ទងគ្នាពេលធ្វើសកម្មភាពមានឈ្មោះ ម៉ុត មេភូមិជ្រុងពពេល បុគ្គលិកសេដ្ឋកិច្ចឃុំម្រាម (ស្រុករមាសហែក), ឆែ ប្រជាជននៅភូមិបឹងកេ ឃុំម្រាម, និង ហ៊ាង ប្រជាជននៅភូមិត្រពាំងជ័រ ឃុំម្រាម ស្រុករមាសហែក ។ ក្រោយពីបានមកបួសនៅវត្តម្រាមបាន៧ថ្ងៃ សាវ៉ន បានធ្វើការទាក់ទងជាមួយ ឆែ និង ហ៊ាង តាមការណែនាំរបស់ សាបិន និងបានធ្វើសកម្មភាពជាមួយគ្នា ដោយចលនាអប់រំលោកសង្ឃនៅក្នុងវត្ត និងប្រជាជនជាបន្តបន្ទាប់ឲ្យប្រឆាំងជាមួយខ្មែរក្រហមដោយបំផុសថា «ខ្មែរក្រហមគឺជាពួកចោរព្រៃ ដើរលួចឆក់ប្លន់ទ្រព្យសម្បត្តិរបស់ប្រជាជន ដុតបំផ្លាញវត្តអារាម និងចូលដៃជើងជាមួយយួនយៀកកុងដើម្បីប្លន់យកទឹកដីខ្មែរ» ជាដើម ។

ចុងឆ្នាំ១៩៦១ សាវ៉ន, ឆែ និង ហ៊ាង បានធ្វើសកម្មភាពបំផុសប្រជាជន និងតាមដានសកម្មភាពរបស់ខ្មែរក្រហមនៅក្នុងឃុំ ។ ពេលនោះបានឃើញឈ្មោះ យ៉ាត មានការទាក់ទងជាមួយខ្មែរក្រហម ។ ឃើញបែបនេះ សាវ៉ន និងបក្ខពួកបានរាយការណ៍ទៅឲ្យ សាបិនៗ ក៏បានរាយការណ៍បន្តទៅឲ្យ សៅ សាគិតៗ ក៏បានចាត់តាំងប៉ូលីសស័ក្តិ១ឈ្មោះ សាវ៉ុធ បច្ចុប្បន្ននៅភូមិមុខដា ឃុំមុខដា ស្រុករមាសហែក តំបន់២៣ ឲ្យដឹកនាំកម្លាំងប៉ូលីសមួយក្រុមមានគ្នា៩នាក់ទៅចាប់ឈ្មោះ យ៉ាត នេះបាត់ទៅ ។ ក្រោយពីចាប់ឈ្មោះយ៉ាតនេះហើយ សាបិន បានណែនាំ សាវ៉ន, ឆែ និង ហ៊ាង ឲ្យខិតខំធ្វើសកម្មភាពតាមដានស្រាវជ្រាវរកខ្សែរបស់ខ្មែរក្រហមដើម្បីកម្ទេចចោលឲ្យអស់ និងខិតខំកសាងកម្លាំងឲ្យបានកាន់តែច្រើនថែមទៀត ហើយត្រូវប្រុងប្រយ័ត្នកុំឲ្យបែកការណ៍ ។ ពេលណែនាំហើយ សាបិន បានខទ្ទេសនាមឲ្យអ្នកទាំងបីបានស្គាល់កម្លាំងបង្កប់៨នាក់ទៀតមានឈ្មោះ សាផល់ អង្គការចាប់ខ្លួនហើយ, ឈ្មោះ សឿង លេខាឃុំមុខដា, ឈ្មោះ វ៉ាង ជាប្រជាជននៅឃុំមុខដា, និងឈ្មោះ ឆន អតីតមេភូមិមុខដា ស្លាប់ឆ្នាំ១៩៧៦ ។

នៅពាក់កណ្តាលឆ្នាំ១៩៦៤ សាផាត, សាផល់, ចាន់ ឆ្លួយ បានដឹកនាំការប្រជុំមួយដោយមានបក្ខពួករបស់ខ្លួនចូលរួមចំនួន១២នាក់មានឈ្មោះ សាបិន, អៀង, ង៉ាន់, សាន់, ជុន ហៅ វិចិត្រ, ហ៊ាង, ឆែ, សាវ៉ន, ម៉ុត, សាវ៉ុធ, ចាន់, និង វ៉ាំង ។ ខ្លឹមសារនៃការប្រជុំគឺបានណែនាំសមាជិកទាំងអស់ឲ្យអនុវត្ត ទី១) ខិតខំកសាងកម្លាំងតទៅទៀត ហើយត្រៀមចាត់តាំងកម្លាំងឲ្យចូលបង្កប់ខ្លួនក្នុងចលនាខ្មែរក្រហម ទី២) បំផុសប្រជាជនឲ្យប្រឆាំងជាមួយខ្មែរក្រហមឲ្យជាប់ ទី៣) តាមដានរកកម្លាំងខ្មែរក្រហមឲ្យឃើញ ហើយរកវិធីកម្ទេចចោល និងទី៤) ត្រូវរក្សាការសម្ងាត់ឲ្យបានល្អនៅពេលអនុវត្តផែនការ ។

ឆ្នាំ១៩៦៥ ក្រោយសឹកពីបួស ឆ្លួយ បានយក សាវ៉ន ទៅនៅជាមួយនៅភូមិព្រៃឈើទាល ឃុំព្រៃធំ ស្រុករមាសហែករហូតមក និងបានដើរទាក់ទងធ្វើសកម្មភាពជាមួយបក្ខពួកផ្សេងៗទៀត ។ បន្ទាប់មក ឆ្លួយ បានណែនាំ សាវ៉ន ឲ្យស្គាល់ខ្សែរយៈចំនួន៤នាក់ទៀតមានឈ្មោះ យុន អតីតអ្នកលក់ដូរនៅសហករណ៍ចន្ទ្រី (បច្ចុប្បន្ន (ស្លាប់), ឈ្មោះ សឿង លេខាឃុំមុខដា, ឈ្មោះ អ៊ីង យោធា (ស្លាប់ឆ្នាំ១៩៧៤), សាំ យោធា (ស្លាប់ឆ្នាំ១៩៧៤) ។ ក្រោយមក សាវ៉ន កសាងកម្លាំងបានពីរនាក់ឈ្មោះ ទេព អាយ នៅភូមិបាក់ព្រា ឃុំចន្ទ្រី ស្រុករមាសហែក និងម្នាក់ទៀតឈ្មោះ ពៀក រ៉ន គ្រូបង្រៀនកុមារនៅភូមិមុខដា ឃុំមុខដា ដោយអប់រំអ្នកទាំងពីរឲ្យមើលឃើញពីការរស់នៅសម្បូរសប្បាយក្នុងរបបសេរី ចំណែករបបខ្មែរក្រហមជារបបកុម្មុយនីស្តមិនដូចជារបបសព្វថ្ងៃនេះទេ ហេតុនេះត្រូវនាំគ្នាការពារ ទប់ស្កាត់កុំឲ្យខ្មែរក្រហមឡើងកាន់អំណាចបានឲ្យសោះ ហើយត្រូវបន្តកសាងកម្លាំងឲ្យបានច្រើនថែមទៀត ។

ឆ្នាំ១៩៦៨ សាផាត, សាផល់, សាបិន និង ចាន់ ឆ្លួយ បានបញ្ចូល សាវ៉ន, ពៀក រ៉ន, និង ទេព អាយ ក្នុងខ្សែ សេ.អ៊ី.អា ។ ពិធីបញ្ចូលសមាជិក សេ.អ៊ី.អា ត្រូវបានរៀបចំឡើងនៅពេលយប់នៅផ្ទះរបស់ សាផល់ ក្នុងភូមិព្រៃឈើទាល ឃុំជ្រៃធំ ។ ការបញ្ចូលសមាជិក សេ.អ៊ី.អា នេះ សាបិន និង ចាន់ ឆ្លួយ ជាអ្នកខទ្ទេសនាម រីឯ សាផល់, សាផាត, នង សារឿន និង អ៊ុំប ជាអ្នកទទួលស្គាល់ ។

ក្រោយពីចូលជាសមាជិក សេ.អ៊ី.អា ហើយ សាផាត និង សាផល់ បានដាក់ភារកិច្ចឲ្យ សាវ៉ន, ពៀក វ៉ន, និង ទេព អាយ អនុវត្តគឺ ធ្វើយ៉ាងណាកសាងកម្លាំងឲ្យបានច្រើន, បំផុសចលនាប្រជាជនឲ្យប្រឆាំងនឹងពួកខ្មែរក្រហម និងរក្សាការសម្ងាត់ឲ្យបានល្អពេលធ្វើសកម្មភាព និងបានចាត់តាំងអ្នកទាំងបីរួមជាមួយបក្ខពួកផ្សេងទៀតនៅសហគមន៍សហករណ៍ ឃុំចន្ទ្រី ស្រុករមាសហែកឲ្យចូលបង្កប់ខ្លួនធ្វើសកម្មភាពនៅតាមភូមិឃុំ ។

ក្រោយរដ្ឋប្រហារ ថ្ងៃ១៨ មីនា ឆ្នាំ១៩៧០ បានចំនួនពីរខែ អង្គការបានឡើងមកក្តោបក្តាប់ និងដឹកនាំប្រជាជននៅក្នុងស្រុករមាសហែកទាំងមូល និងបានចាត់តាំង សាផាត ឲ្យធ្វើជាលេខាស្រុក សាផល់ ជាអនុលេខាស្រុក និង តាចាន់ ជាសមាជិក ។ បន្ទាប់មកនៅក្នុងខែកក្កដាឆ្នាំដដែល ក្នុងនាមជាលេខាស្រុក សាផាត បានបើកការប្រជុំមួយ ហើយបានផ្តល់តួនាទីដល់បក្ខពួករបស់ខ្លួនមួយចំនួនដើម្បីងាយស្រួលចូលបង្កប់ខ្លួនក្នុងរដ្ឋអំណាចបដិវត្តន៍ធ្វើសកម្មភាពប្រឆាំងនឹងអង្គការ ដែលពេលនោះ ឈ្មោះ សាន់ បានទទួលធ្វើជាគណៈឃុំកំពង់ត្រាច សឿង ទទួលជាគណៈឃុំមុខដា យា ហៅ សំ សុផាន ធ្វើជាគណៈឃុំចន្ទ្រី សាវ៉ន ទទួលធ្វើជាប្រធានភូមិបាក់ព្រា នេត សាប៊ុន ជាអនុប្រធាន និង ប៉ែន យ៉ា ជាសមាជិក ចំណែក យ៉ុន ត្រូវទៅនៅខាងយោធាស្រុករមាសហែក រីឯ ពៀក វ៉ន, ទេព អាយ, និង កែវ ត្រូវបានចាត់តាំងឲ្យនៅជាមួយ សាវ៉ន ។ ពេលដែលបានធ្វើការចាត់តាំងកម្លាំងបង្កប់របស់ខ្លួនរួចរាល់ហើយ សាផាត និង សាផល់ បានធ្វើការណែនាំបន្ថែមទៀតដល់បក្ខពួករបស់ខ្លួនឲ្យខិតខំកសាងកម្លាំងនៅក្នុងភូមិឃុំឲ្យបានច្រើន ដើម្បីត្រៀមរៀបចំកម្លាំងចូលបង្កប់ក្នុងរដ្ឋអំណាចបដិវត្តន៍ទៅថ្ងៃមុខ និងបានបំផុសប្រជាជនជាប្រចាំកុំឲ្យមានជំនឿលើការដឹកនាំរបស់អង្គការ ហើយធ្វើយ៉ាងណារក្សាការសម្ងាត់ឲ្យបានល្អ ។ ពេលណែនាំរួចហើយ សាផាត បានប្រកាសបិទអង្គប្រជុំ សមាជិកទាំងអស់ក៏បានបំបែកគ្នាទៅកន្លែងរៀងៗខ្លួន ។

ឆ្នាំ១៩៧១-៧២ សាវ៉ន រួមជាមួយ សំអឿន, សាវិន, យា ហៅ សំ សុផាន, ប៉ែន យ៉ា, នេត សាប៊ុន និង សាមិត្ត ហៅ ស៊ីន ណារ៉ុង កសាងកម្លាំងថ្មីបានចំនួនបីនាក់មានឈ្មោះ សៅ ណូង បច្ចុប្បន្នជាប្រធានក្រុមសហករណ៍ភូមិព្រៃកប្បាស ឃុំចន្ទ្រី, ឈ្មោះ យឹម យ៉ន (បច្ចុប្បន្នជាអនុប្រធានក្រុមសហករណ៍ភូមិទួលសំរោង ឃុំចន្ទ្រី និងឈ្មោះ ស៊ុន ហាន ស្លាប់) និងបានប្រើវិធីគាបសង្កត់តឹងតែងក្នុងការដឹកនាំប្រជាជន បើប្រជាជនណាម្នាក់មិនអនុវត្តតាម ឬធ្វើការតវ៉ា ត្រូវបានចោទថា ជាសត្រូវសម្ព័ន្ធ ហើយចាប់ចងអ្នកទាំងនោះយកទៅធ្វើបាបដែលជាហេតុធ្វើឲ្យប្រជាជនមានការថ្នាំងថ្នាក់ ខ្វាចរអា មិនពេញចិត្តចំពោះការដឹកនាំរបស់អង្គការឡើយ ។ ជាបន្តមកទៀត សាវ៉ន ត្រូវបានចាត់តាំងឲ្យធ្វើជាអនុប្រធានផ្នែកវប្បធម៌ឃុំចន្ទ្រី ឈ្មោះ យី ទទួលជាប្រធាន និង ឈ្មោះ រស់ ជី ទទួលធ្វើជាសមាជិក ។

ក្នុងឆ្នាំ១៩៧៣ សាផល់ បានបើកការប្រជុំចំនួនពីរលើកនៅផ្ទះរបស់ខ្លួន ។ លើកទីមួយមានសមាជិកចូលរួមចំនួន១៤នាក់ ។ នៅក្នុងអង្គប្រជុំលើកទីមួយនេះ សាផល់ បាននិយាយរៀបរាប់ប្រាប់សមាជិកទាំងអស់ថា ពេលនេះអង្គការបានដក សាផាត ឲ្យទៅទទួលនាទីជាគណៈតំបន់២៣ ។ ដូច្នេះចំពោះគណៈតំបន់ដែលអង្គការបានចាត់តាំងនៅពេលថ្មីៗនេះ គឺសុទ្ធតែជាខ្សែរបស់យើងទាំងអស់ ដូចជា សូ បានទទួលជាលេខា, នង សារឿន បានទទួលជាអនុលេខា, និង សាផាត បានទទួលជាសមាជិក ។ នៅពេលជាមួយគ្នានោះដែរ សាផល់ បានរៀបចំចាត់តាំង និងផ្លាស់ប្តូរកម្លាំងមួយចំនួននៅតាមភូមិឃុំដូចជា ចាត់តាំង សំអឿន ឲ្យឡើងទទួលផ្នែកសន្តិសុខស្រុករមាសហែក, សារិន ទទួលជាសមាជិកស្រុកមានជ័យថ្មី ។ ចំណែកឃុំចន្ទ្រី សារី ត្រូវបានចាត់តាំងឲ្យទទួលខុសត្រូវជាមួយ យា ជំនួស សំអឿន ។ សាផល់ បានធ្វើការណែនាំបន្ថែមថា ឥឡូវនេះ តំបន់២៣ គឺសុទ្ធតែបក្ខពួកយើងក្តោបក្តាប់ទាំងអស់ យើងចង់ធ្វើអីក៏បាន តែពិសេសបច្ចុប្បន្ននេះ យើងត្រូវខិតខំកសាងកម្លាំងបង្កប់នៅតាមមូលដ្ឋាននីមួយៗឲ្យបានច្រើនដើម្បីងាយស្រួលក្នុងការដឹកនាំប្រជាជន ។ ដូច្នេះយើងម្នាក់ៗ នៅតាមឃុំនីមួយៗត្រូវខិតខំអនុវត្តផែនការនេះឲ្យបានសម្រេចជោគជ័យតាមផែនការដែលថ្នាក់លើបានដាក់ចុះ ។ រីឯការប្រជុំលើកទីពីរមានសមាជិកចូលរួមចំនួន១៥នាក់ ។ នៅក្នុងអង្គប្រជុំ សាផល់ បានមានមតិណែនាំថា ឥឡូវនេះអង្គការមានផែនការរៀបចំសហករណ៍ផលិតកម្មឲ្យស្រុកភូមិ និងឃុំនីមួយៗហើយ ហើយបានឲ្យប្រជាជនចូលធ្វើការក្នុងសហករណ៍រួមនេះ ។ តាមពិតផែនការនេះ មាន៥-៦ខែ

មកហើយ តែយើងលាក់មិនបានធ្វើការផ្សព្វផ្សាយប្រាប់ប្រជាជនឲ្យបានដឹងពីរឿងនេះទេ ។ ចំពោះផែនការណាដែលយើងអាចលាក់បានយើងលាក់ ។ តែបើផែនការណាលាក់មិនបានទេ យើងធ្វើការផ្សព្វផ្សាយខ្លះៗ តែប៉ុណ្ណោះដល់ប្រជាជន មិនផ្សព្វផ្សាយទាំងស្រុងទេ ធ្វើបែបនេះដើម្បីងាយស្រួលដោះស្រាយជាមួយថ្នាក់លើ តែផែនការដែលយើងផ្សព្វផ្សាយ យើងត្រូវប្រែក្រឡាស់ផែនការនេះឲ្យទៅជាផែនការគាបសង្កត់ និងតឹងតែងជាមួយប្រជាជនទៅវិញ ធ្វើយ៉ាងនេះដើម្បីឲ្យប្រជាជនមានការថ្នាំងថ្នាក់ជាមួយនិងការដឹកនាំរបស់អង្គការ ។ ក្រោយពីបានទទួលការណែនាំពីសាផល់ ហើយ សាវ៉ន និងបក្ខពួកបានបំផុសចលនាប្រជាជនឲ្យប្រឆាំងនឹងផែនការចាត់តាំងសហករណ៍របស់អង្គការបន្តបន្ទាប់ ។

ឆ្នាំ១៩៧៤ សាវ៉ន ត្រូវបានចាត់តាំងឲ្យធ្វើជាប្រធានទទួលខុសត្រូវយុវជននៅក្នុងស្រុករមាសហែកចំនួន១.៨៥០នាក់ រួមជាមួយ ផុន ហៅ វិចិត ជាអនុប្រធាន និងឈ្មោះ ប្រាក់ វណ្ណា ជាសមាជិក ហើយថ្នាក់លើក៏បានខទ្រេសនាមកម្លាំងបីនាក់ទៀតទទួលខុសត្រូវផ្នែកខាងនារី ប្រគល់មកឲ្យ សាវ៉ន ជាអ្នកដឹកនាំរួមដែរ ។ ក្រោយពីបានទទួលនាទីជាប្រធានយុវជនស្រុកមក សាវ៉ន ផុន និង ប្រាក់ វណ្ណា បានរួមគ្នាធ្វើសកម្មភាពប្រឆាំងនឹងផែនការរបស់អង្គការជាប់ជានិច្ច ដូចជាអប់រំបំផុសយុវជនឲ្យមានសតិអារម្មណ៍ខ្លាចរអាមិនហ៊ានទៅសមរភូមិមុខជាដើម ។ សាវ៉ន បានណែនាំនារី សាលន់, នារី សាភណ្ឌ, និងនារី ចាន់ ថន ដែលជាអ្នកទទួលខុសត្រូវផ្នែកនារីខិតខំកសាងកម្លាំងផ្នែកនារីធ្វើយ៉ាងណាអូសទាញកម្លាំងយុវជនឲ្យចូលបម្រើក្នុងចលនា សេ.អ៊ី.អា ឲ្យបានច្រើន ។ ក្រោយមក សាវ៉ន កសាងកម្លាំងយុវជនបានពីរនាក់ឈ្មោះ ស៊ីណាត និង សន ហើយបានប្រគល់ភារកិច្ចឲ្យអ្នកទាំងពីរកសាងកម្លាំងយុវជន និងបំផុសប្រជាជនឲ្យប្រឆាំងជាមួយអង្គការជាបន្តទៀត ។

ឆ្នាំ១៩៧៥ ក្រោយពីបានទទួលផែនការធ្វើផ្ទះតាមការណែនាំរបស់ ស៊ូ ហើយ សាវ៉ន និងបក្ខពួកមួយចំនួនបានចុះទៅធ្វើផ្ទះអស់រយៈពេលពីរខែ ពោលគឺរហូតដល់ខែមេសា ឆ្នាំ១៩៧៥ ក្រោយរំដោះទើបធ្វើផ្ទះនោះរួចរាល់ ។ បន្ទាប់មក សាផល់, សាផាត និង ស៊ូ បានចាត់តាំង សាវ៉ន, ប្រាក់ វណ្ណា, និង វិចិត ឲ្យយកសត្វជ្រូកចំនួន៩ក្បាលពី តាប៊ីចេង លេខាឃុំដូង យកទៅឲ្យយួនដែលជាចៅហ្វាយខេត្តតៃនិញឈ្មោះ ទី វ៉េ ។ ការបញ្ជូនជ្រូកទៅឲ្យយួននេះ សាផល់ បានណែនាំឲ្យឈ្មោះ សំអឿន លេខាវរសេនាតូចស្រុករមាសហែក បច្ចុប្បន្នប្រធានពេទ្យស្រុករមាសហែក និង ស៊ូក ហៅ ការ៉ូ សមាជិកវរសេនាតូចស្រុករមាសហែក បច្ចុប្បន្ន សមាជិកវរសេនាតូចលេខ៦៨ វរសេនាធំ១១២ តំបន់២៣ ជាអ្នកជូនដំណើរទៅ ។ ចំណែកចៅហ្វាយខេត្តយួនឈ្មោះ ទី វ៉េ នៅចាំទទួលយកជ្រូកនៅភូមិទួល ជាប់ព្រំប្រទល់ដែន ។ ពេលដែលប្រគល់ជ្រូកឲ្យទៅចៅហ្វាយខេត្តតៃនិញហើយ សាវ៉ន ក៏បាននាំគ្នាត្រឡប់មកវិញ ។ នៅក្នុងអំឡុងខែកញ្ញា រហូតដល់ខែធ្នូ សាវ៉ន មិនបានចូលរួមធ្វើសកម្មភាពណាមួយជាមួយបក្ខពួករបស់ខ្លួនទេ ព្រោះកើតជំងឺគ្រុនចាញ់ ត្រូវសម្រាកដើម្បីព្យាបាលជំងឺ ។

នៅដើមឆ្នាំ១៩៧៦ ពេលជាសះស្បើយពីជំងឺគ្រុនចាញ់មក សាវ៉ន រួមជាមួយ ប្រាក់ វណ្ណា និង ផុន ហៅ វិចិត្រ បានទទួលការចាត់តាំងពី សាផល់ ឲ្យដឹកនាំកងចល័តយុវជនចំនួន១.៨៣០នាក់ទៅបង្កបង្កើនផលនៅឃុំដូង ។ ពេលនោះ សាវ៉ន និងបក្ខពួកបានធ្វើសកម្មភាពដឹកនាំដោយដាក់ការគាបសង្កត់ និងចេញវិន័យតឹងតែងដល់យុវជននៅក្នុងកងចល័តជាប់ជាប្រចាំ ហើយបានប្រើឲ្យយុវជនធ្វើការគ្មានពេលឈប់សម្រាក ពេលមានជំងឺឈឺថ្កាត់ទៅធ្វើការមិនកើត បក្ខពួក សាវ៉ន បានចោទថា ជាសក្តិសម្ព័ន្ធ ម៉្លោះហើយយុវជននៅក្នុងកងចល័តទាំងអស់ចេះតែទ្រាំទៅធ្វើការទាំងឈឺទាំងជា ពេលខ្លះ ពេលទៅដល់ស្រែធ្វើការរហូតដល់ស្លាប់នៅនឹងកន្លែងធ្វើការក៏មានដែរ ។ ក្នុងរយៈពេលពីរខែ យុវជនក្នុងកងចល័តបានស្លាប់បាត់បង់ជីវិតដោយសារធ្វើការងារគ្មានពេលឈប់សម្រាកហូបចុកមិនគ្រប់គ្រាន់ និងពេលឈឺគ្មានថ្នាំព្យាបាលអស់ចំនួន៨នាក់ ។ ឆ្លៀតក្នុងឱកាសនោះដែរ សាវ៉ន បានចាត់តាំងបក្ខពួកផ្សេងទៀត ឲ្យធ្វើសកម្មភាពបំផុសអប់រំយុវជនឲ្យប្រឆាំងជាមួយអង្គការជាបន្តបន្ទាប់ និងកសាងកម្លាំងយុវជនបានពីរនាក់ដែរ នៅពេលនោះ គឺឈ្មោះ សៀន ជាអនុប្រធានកង ចល័តស្រុករមាសហែក និងម្នាក់ទៀតឈ្មោះ សុវណ្ណ ប៉ម ប្រធានកងចល័តស្រុករមាសហែក ។ ខែតុលាឆ្នាំដដែល សាវ៉ន និងបក្ខពួកបាននាំគ្នាលួចគោរបស់ប្រជាជននៅសហករណ៍ភូមិដូងយកទៅកាប់ស៊ីជប់លៀងអស់បួនក្បាល ។ ខែធ្នូឆ្នាំដដែល សាវ៉ន និងបក្ខពួកបានទទួលការ

ចាត់តាំងពី សាផល់ ម្តងទៀតឲ្យយកក្របីចំនួន១០ក្បាលពីឈ្មោះ សឿង ទៅឲ្យចៅហ្វាយខេត្តតៃនិញឈ្មោះ ទី វ៉ េ នៅកន្លែងដែលធ្លាប់ទៅកាលពីលើកមុន ។ ពេលប្រគល់ក្របីឲ្យទៅ ទី វ៉េ ហើយ ទី វ៉េ ក៏បានផ្ញើសំបុត្រពីរច្បាប់មកឲ្យ សាផល់ វិញដែរ ចំពោះអត្ថន័យនៅក្នុងសំបុត្រយ៉ាងណានោះគ្មាននរណាដឹងទេ ។

ខែមករា ឆ្នាំ១៩៧៧ សាវ៉ន, ប្រាក់ វណ្ណា, សឿន, សារុំ, និង ផន បាននាំគ្នាទៅដុតបំផ្លាញម៉ាស៊ីនកិនស្រូវឆេះខ្ទេចខ្ទីអស់មួយគ្រឿងដែលអង្គការទើបរៀបចំហើយថ្មីៗ នៅវេលាម៉ោងប្រហែល៦ល្ងាចនៅភូមិស្រះ ឃុំជ្រៃធំ ។ ក្រោយមកនៅខែកុម្ភៈ អង្គការបានប្រមូលយុវជន-យុវនារីនៅតាមគ្រប់ភូមិ-ឃុំ និងស្រុកទាំងអស់ឲ្យទៅជីកព្រែកថ្មីនៅវត្តដកពរ ក្នុងឃុំជ្រៃធំ ។ ពេលនោះ សាវ៉ន, វណ្ណា, ផុន ហៅ វិចិត, នារី សាលន់, នារី ចាន់ថន, និងនារី សាភ័ណ្ឌ បាននាំគ្នាបំភ្លៃមាគ៌ាអង្គការគឺជំរុញឲ្យយុវជនយុវនារីទាំងអស់ធ្វើការងារទាំងថ្ងៃទាំងយប់គ្មានពេលឈប់សម្រាកចំណែកការហូបចុកមិនបានគ្រប់គ្រាន់ ដែលជាហេតុធ្វើឲ្យយុវជនយុវនារីធ្លាក់ខ្លួនឈឺ ធ្វើការងារមិនកើត និងមានអ្នកស្លាប់ជាជាហូរហែ ។ មើលឃើញស្ថានភាពនេះ ខាងភូមិភាគបានឧបត្ថម្ភជាថ្នាំពេទ្យដើម្បីយកមកព្យាបាលអ្នកជំងឺ តែ សាវ៉ន បានចែកឲ្យតែបក្ខពួករបស់ខ្លួនប៉ុណ្ណោះ ។

ខែមីនា ឆ្នាំ១៩៧៧ សាវ៉ន, វណ្ណា, ផុន, នារី សាលន់, នារី សាភ័ណ្ឌ, និងនារី ចាន់ថន និងបក្ខពួកចំនួន១៣នាក់ផ្សេងទៀត បានចូលរួមប្រជុំនៅផ្ទះរបស់ សាផល់ ។ ពេលនោះ សាផល់ បានណែនាំទាំងអស់គ្នាឲ្យរៀបចំខ្សែចាត់តាំងនៅតាមកន្លែងនីមួយៗឲ្យបានល្អដើម្បីចាំរួមកម្លាំងធ្វើរដ្ឋប្រហារ វាយរំលំរដ្ឋអំណាចបដិវត្តន៍ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៧ ខាងមុខ ។ ចំណុចសំខាន់គឺត្រូវដឹកនាំប្រជាជននៅតាមភូមិឃុំនីមួយៗឲ្យមានទំនាស់ជាមួយនឹងអង្គការឲ្យបានជាប់ជាប្រចាំ នៅពេលដែលផែនការធ្វើរដ្ឋប្រហារផ្ទុះឡើង ត្រូវបំផុសប្រជាជនឲ្យរួមកម្លាំងជាមួយក្រុមយើងតែម្តង ។ ក្រោយពីបានធ្វើការណែនាំរួចរាល់ហើយ សាផល់ ក៏បានបិទអង្គប្រជុំ សមាជិកទាំងអស់បានវិលត្រឡប់ទៅកន្លែងរៀងៗខ្លួនវិញ ។ មុនថ្ងៃទី១៧ ខែមេសា ចំនួនពីរថ្ងៃ សាផល់ បានហៅសមាជិករបស់ខ្លួនប្រជុំម្តងទៀត ហើយបានប្រកាសនៅពេលនោះថា ផែនការធ្វើរដ្ឋប្រហារថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៧ ត្រូវផ្អាកសកម្មភាពសិនព្រោះខ្សែទាក់ទងនៅខាងលើធ្វើឲ្យបែកការណ៍ហើយ តែការរៀបចំកម្លាំង និងការអប់រំបំផុសប្រជាជនឲ្យមានទំនាស់ជាមួយអង្គការគឺនៅធ្វើសកម្មភាពដដែល ដើម្បីត្រៀមរង់ចាំអនុវត្តផែនការរបស់យើងទៅថ្ងៃខាងមុខទៀត ។

ខែកក្កដា ឆ្នាំ១៩៧៧ សាវ៉ន បានទៅជួប សូ នៅមន្ទីរតំបន់២៣ ។ ពេលនោះ សូ បានចាត់តាំង សាវ៉ន ឲ្យទទួលនាទីជាអនុប្រធានពេទ្យតំបន់២៣ និងបានណែនាំឲ្យភ្ជាប់ខ្សែជាមួយ យ៉ាន ប្រធានពេទ្យតំបន់២៣ (អង្គការចាប់ហើយ) ដើម្បីងាយស្រួលធ្វើសកម្មភាពជាមួយគ្នាទៅថ្ងៃមុខទៀត ។ បន្ទាប់ពីបានណែនាំឲ្យស្គាល់គ្នាហើយ យ៉ាន បាននាំ សាវ៉ន ដើរមើលមន្ទីរពេទ្យមួយចំនួនដូចជាមន្ទីរពេទ្យនៅក្រុងស្វាយរៀងពីរកន្លែង មន្ទីរពេទ្យនៅវត្តថ្មីមួយកន្លែង មន្ទីរពេទ្យនៅរូបគោមួយកន្លែង និងមន្ទីរពេទ្យនៅវត្តព្រៃធ្លាក់មួយកន្លែង ។ ពេលនោះ យ៉ាន ក៏បានណែនាំឲ្យស្គាល់ខ្សែរយៈរបស់ខ្លួនមួយចំនួននៅក្នុងមន្ទីរពេទ្យតំបន់២៣ មានឈ្មោះ សារ៉េន ប្រធានក្រុមនៅខាងមន្ទីរពេទ្យយោធា (អង្គការចាប់ខ្លួនហើយ), ឡូន ប្រធានក្រុមពេទ្យតំបន់២៣ (ផ្នែកគ្រុនចាញ់អង្គការចាប់ខ្លួនហើយ), ឈន ប្រធានក្រុមនេសាទត្រីនៅពេទ្យតំបន់២៣ (អង្គការចាប់ខ្លួនហើយ), គន់ អនុប្រធានបង្កបង្កើនផលពេទ្យតំបន់២៣ (អង្គការចាប់ខ្លួនហើយ), នារី សុខា ប្រធានក្រុមពេទ្យតំបន់២៣ នៅផ្នែកឆ្មប (អង្គការចាប់ខ្លួនហើយ), គឹម ហ៊ាង ប្រធានក្រុមពេទ្យតំបន់២៣ នៅខាងវត្តថ្មី, វិសារ អនុប្រធានក្រុមពេទ្យតំបន់២៣ នៅខាងវត្តថ្មី, សាវុធ ប្រធានក្រុមពេទ្យតំបន់២៣ នៅវត្តព្រៃធ្លាក់, សុត ប្រធានក្រុមខាងស្លថ្នាំពេទ្យតំបន់២៣, ចិន ប្រធានផ្នែកបង្កបង្កើនផលពេទ្យតំបន់២៣, សំអ៊ាន ប្រធានឃ្លាំងថ្នាំពេទ្យតំបន់២៣, សុន ប្រធានក្រុមពេទ្យតំបន់២៣ នៅក្រសួង, យឿន អនុប្រធានក្រុមពេទ្យតំបន់២៣ ផ្នែកជំងឺគ្រុនចាញ់, សំអឿ បុគ្គលិកពេទ្យយោធាតំបន់២៣, នារី សុវណ្ណ ប្រធានក្រុមពេទ្យតំបន់២៣ ផ្នែកខាងនារីនៅក្រសួង, នារី សាខន អនុប្រធានក្រុមនារីពេទ្យតំបន់២៣ នៅក្រសួង, នារី ម៉ាន់សារី បុគ្គលិកពេទ្យយោធាតំបន់២៣, ឈា អនុប្រធានក្រុមពេទ្យយោធាតំបន់២៣ ។

ជារៀយៗ នៅក្នុងមន្ទីរពេទ្យ សាវ៉ន, យ៉ាន និងបក្ខពួកបាន

ធ្វើសកម្មភាពធ្វើបាបប្រជាជន យុទ្ធជនដែលមកសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ ដោយមិនយកចិត្តទុកដាក់ក្នុងការថែទាំអ្នកជំងឺ ទុកដាក់អ្នកជំងឺធ្ងន់ និងអ្នកជំងឺស្រាលឲ្យដេកប្រឡូកប្រឡាក់ជាមួយគ្នា សម្ភារ មុង ភួយ កន្ទេល ដែលអង្គការឧបត្ថម្ភសម្រាប់អ្នកជំងឺ មិនយកមកចែកឲ្យអ្នកជំងឺប្រើប្រាស់ទេ បែរជាទុកចោលនៅក្នុងឃ្លាំង មិនតែប៉ុណ្ណោះ ថែមទាំងកាត់បន្ថយរបបអាហារអ្នកជំងឺមិនឲ្យហូបចុកគ្រប់គ្រាន់ទៀត ជាហេតុធ្វើឲ្យអ្នកជំងឺស្លាប់ជាបន្តបន្ទាប់ ។

ខែសីហា ឆ្នាំ១៩៧៧ សូ បានបើកអង្គប្រជុំមួយមានសមាជិកចូលរួមចំនួន១៩នាក់ ។ នៅក្នុងអង្គប្រជុំ សូ បានលើកឡើងថា ផែនការវាយរំលំរដ្ឋអំណាចបដិវត្តន៍នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៧ មិនបានសម្រេច ដូច្នេះយើងត្រូវរៀបចំផែនការធ្វើរដ្ឋប្រហារវាយរំលំបដិវត្តន៍ម្ដងទៀត គឺនៅថ្ងៃបុណ្យខួបបក្សខែកញ្ញា ឆ្នាំ១៩៧៧ នេះ ដោយយើងរួមសហការណ៍ជាមួយយួន ។ ដូច្នេះ ទាំងផ្នែកកងទ័ព ទាំងស្រុក ទាំងក្រសួង គឺត្រូវរៀបចំកម្លាំង និងត្រៀមសម្ភារឲ្យបានរួចរាល់ដើម្បីរួមចំណែកអនុវត្តផែនការនេះឲ្យបានជោគជ័យ ហើយធ្វើយ៉ាងណាត្រូវរក្សាការសម្ងាត់ឲ្យបានល្អ ។ ចប់ការប្រជុំ សាវ៉ន និង យ៉ាន បាននាំយកផែនការខាងលើមកផ្សព្វផ្សាយឲ្យសមាជិកក្នុងក្រុមទាំងអស់បានដឹង និងបានចាត់តាំងបក្ខពួកឲ្យប្រមូលថ្នាំពេទ្យល្អៗទុកដើម្បីត្រៀមធ្វើរដ្ឋប្រហារ ។

ខែកញ្ញា ឆ្នាំ១៩៧៧ មុនពេលថ្ងៃបុណ្យខួបបក្សចំនួនបីថ្ងៃ សូ បានបើកការប្រជុំនៅត្រើយតាហោ ដែលពេលនោះមានសមាជិកទាំងអស់ចំនួន១៨នាក់ចូលរួម ។ សូ បាននិយាយថា ឥឡូវនេះ សភាពការណ៍មិនសូវស្រួលទេ ហេតុនេះផែនការធ្វើរដ្ឋប្រហាររបស់យើងត្រូវផ្អាកសិន តែយើងត្រូវបើកផ្លូវឲ្យយួនវាយចូលពីខាងក្រៅរំដោះតំបន់២៣របស់យើងនេះឲ្យបាន ហើយសឹមយើងប្រមូលកម្លាំងរួមជាមួយយួនវាយសម្រុកទៅមុខបន្តទៀត ។ ពេលណែនាំចប់ សូ បានប្រកាសបិទអង្គប្រជុំ ។ នៅពាក់កណ្ដាលខែធ្នូ យួនបានវាយចូលខ្លាំងមកដល់ស្រុកប្រសូត្រ ។ ពេលនោះ សូ បានចាត់តាំង សាវ៉ន, យ៉ាន, ថាន់, និង យូន ដឹកថ្នាំពេទ្យចំនួនបួនឡានឡង់រ៉ូវែ មានថ្នាំគ្លូរ៉ូគីន និងថ្នាំអាស្ពីរីន យកទៅឲ្យយួនឈ្មោះ ទីញ៉ូវ និងឈ្មោះ មិន គណៈខេត្តឡុងអាន នៅគល់ស្ពានបូមក្នុងស្រុកប្រសូត្រ ។

ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨ កងទ័ពកម្ពុជាប្រជាធិបតេយ្យបានវាយបណ្ដេញកងទ័ពយួនចេញពីទឹកដីកម្ពុជាវិញ ។ នៅដើមខែកុម្ភៈ ឆ្នាំដដែល សូ បានហៅ សាវ៉ន និង យ៉ាន ទៅជួប និងបានណែនាំអ្នកទាំងពីរឲ្យប្រមូលថ្នាំពេទ្យលាក់ទុកឲ្យបានស្រួលបួល ដើម្បីត្រៀមលក្ខណៈរៀបចំកម្លាំងវាយកម្ទេចកងទ័ពអង្គការនៅក្នុងឱកាសថ្ងៃបុណ្យចូលឆ្នាំនាខែមេសា ឆ្នាំ១៩៧៨នេះ ដោយឲ្យយួនវាយបុកពីខាងក្រៅ ចំណែកយើងវាយផ្ទប់ពីខាងក្រោយ ។ ពេលណែនាំហើយ សូ បានបើកកាំភ្លើងឲ្យ សាវ៉ន និង យ៉ាន ក្នុងម្នាក់ៗ ១០ដើម មានកាំភ្លើងអាកាមួយដើម អាអ៊ែរ១៥ ចំនួន៥ដើម និងការ៉ាប៊ីនចំនួនបួនដើមយកមកចែកឲ្យកម្លាំងដែលជាបក្ខពួកនៅក្នុងមន្ទីរពេទ្យ ។ បន្ទាប់ពីបានទទួលផែនការហើយ សាវ៉ន និង យ៉ាន បានប្រមូលថ្នាំពេទ្យដែលត្រៀមទុកកាលពីលើកមុនដឹកយកមកលាក់ទុកនៅក្នុងវត្តអង្គរសចំនួនបីឡាន មាន សេរ៉ូមទឹកថ្នាំអាស្ពីរីន ថ្នាំគ្លូរ៉ូគីន ជីវជាតិគ្រប់មុខ ថ្នាំតេត្រាស៊ីគ្លីន និងថ្នាំប៉េនីស៊ីលីន ស្រ្ដិបតូ និងសម្ភារពេទ្យមួយចំនួនទៀត ។ ផែនការធ្វើរដ្ឋប្រហារលើកនេះក៏មិនបានសម្រេចដែរ ដោយសារអង្គការបានដក សូ ចេញពីតំបន់២៣ ឲ្យមកទទួលខុសត្រូវតំបន់២៤វិញ ។ ក្រោយពីដក សូ ចេញបានបន្តិចមក អង្គការក៏បានចាប់ខ្សែរយៈ សាវ៉ន ជាបន្តបន្ទាប់រហូតដល់ថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៨ យ៉ាន ប្រធានមន្ទីរពេទ្យតំបន់២៣ក៏ត្រូវបានអង្គការចាប់ខ្លួនដែរ ។ រំលងបាន១៤ថ្ងៃក្រោយមក គឺនៅថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៨ សាវ៉ន ក៏ត្រូវបានអង្គការចាប់ខ្លួនតែម្ដង ។

ឯកសារចម្លើយសារភាពរបស់ យិន លន់ ហៅ សាវ៉ន ជាឯកសារសរសេរដោយដៃ ដែលបានរៀបរាប់ពីប្រវត្តិ និងសកម្មភាពក្បត់រួមជាមួយបក្ខពួកមានចំនួន៥៤ទំព័រ និងមានថែមផ្នែកខាងក្រោយចំនួន៨ទំព័រផ្សេងទៀត ដែលជាបញ្ជីរាយនាមបក្ខពួកដែលបានរួមសកម្មភាពក្បត់បក្សចំនួន១០២នាក់ទៀត ។ ចុងបញ្ចប់នៃ ចម្លើយសារភាពផ្នែកខាងស្ដាំ មានចុះហត្ថលេខា និងស្នាមផ្ដិតមេដៃរបស់ សាវ៉ន ដែលជាអ្នកសារភាពផ្ទាល់ ចុះកាលបរិច្ឆេទថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៧៨ ។ នៅផ្នែកខាងឆ្វេង មានចុះហត្ថលេខារបស់អ្នកធ្វើឯកសារឈ្មោះ ហៀង និងចុះកាលបរិច្ឆេទថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៧៨ ។ **ឆេង ឌើង**

# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែង គឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះបីជាយ៉ាងនេះក្តី នៅពេលអនាគតដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទង ដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះ ក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែលៈ truthmpechet@dccam.org ។

**◆ទីកន្លែង : អគារ "ក" ជាន់លើ ◆ពេលវេលា : ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# រៀនសូត្រពិសោធន៍សំខាន់ៗក្នុងការបំពេញភារកិច្ចនយោបាយរបស់បក្ស ឆ្នាំ១៩៧៨ ឆមាសទី១

*(ដកស្រង់ចេញពីឯកសារទង់បដិវត្តន៍លេខពិសេស ខែឧសភា-មិថុនា ឆ្នាំ១៩៧៨)*

### ១) ទិដ្ឋភាពពិសេសនៃសកម្មភាពអនុវត្តភារកិច្ចនយោបាយឆ្នាំ ១៩៧៨ ឆមាសទី១

តាមការកំណត់របស់មជ្ឈិមបក្ស ក្នុងសន្និបាតពីខែវិច្ឆិកា ឆ្នាំ១៩៧៧ មានបញ្ហាជាច្រើនដែលមជ្ឈិមបក្សបានលើកឡើងគឺ មានភារកិច្ចនយោបាយរួមប្រចាំឆ្នាំ, មានភារកិច្ចស្នូល និងភារកិច្ចតាមផ្នែកនីមួយៗ ដើម្បីអនុវត្តភារកិច្ចនយោបាយរួម និងភារកិច្ចស្នូល ប៉ុន្តែយើងអាចសរុបបានថា បញ្ហាសំខាន់មានមួយចំនួនដូចតទៅ៖

១ - ភារកិច្ចការពារប្រទេស

២ - ភារកិច្ចបន្តធ្វើបដិវត្តន៍សង្គមនិយម

៣ - ភារកិច្ចកសាងសង្គមនិយម

៤ - ជីវភាពប្រជាជន

៥ - ភារកិច្ចកសាងកម្លាំងបក្សដឹកនាំ និងកម្លាំងស្នូល ពិសេសកសាងកម្មាភិបាល

៦ - សភាពការណ៍បដិវត្តន៍យើងនៅលើឆាកអន្តរជាតិ

ទិដ្ឋភាពពិសេសក្នុងការបំពេញភារកិច្ច ឆ្នាំ១៩៧៨ ឆមាសទី១ មានដូចតទៅ៖

**ចំណុចពិសេសទី១**



កងយុវជន និងកងទ័ពបដិវត្តន៍ ប្រជុំរៀនសូត្រ បន្ទាប់ពីបំពេញការងារប្រចាំថ្ងៃរួច

ក្នុងឆមាសទី១ ឆ្នាំ១៩៧៨ នេះ មានការបន្តការប្រយុទ្ធរវាងខ្មាំង និងយើងបន្តទៅទៀត ទាំងខ្មាំងខាងក្រៅ ទាំងខ្មាំងខាងក្នុង ។ ជាការប្រយុទ្ធតឹងតែង ស៊ុតស្មាញ ជ្រាលជ្រៅ ដណ្ដើមយកជ័យជម្នះលើគ្នាយ៉ាងរមួតយ៉ាងក្ដៅគគុក ទាំងខាងយោធា ទាំងខាងនយោបាយ ទាំងខាងសេដ្ឋកិច្ច រហូតដល់ការប្រយុទ្ធខាងការបរទេស ក៏រមួត ស៊ុតស្មាញ និងជ្រាលជ្រៅ ។

នេះជាទិដ្ឋភាពមួយនៃការប្រយុទ្ធពិសេសនាឆមាសទី១ ។

យើងកំណត់ថា ៖ ពិសេស ពីព្រោះជាការប្រយុទ្ធបន្តពីមុនមក តែមានលក្ខណៈស្រួចស្រាវជាងឆ្នាំមុនៗ ។

## ចំណុចពិសេសទី២

ការប្រយុទ្ធក្នុងឆមាសទី១ ឆ្នាំ១៩៧៨នេះ បង្ហាញឲ្យយើងឃើញធាតុពិតរបស់ខ្មាំង ទាំងខ្មាំងខាងក្រៅ ទាំងខ្មាំងខាងក្នុងរឹតតែច្បាស់ថែមទៀត ដែលវាខិតខំវាយរំលំកម្ពុជាប្រជាធិបតេយ្យ វាយរំលំរបបសមូហភាពរបស់យើង ខិតខំវាយទាំងខាងក្នុងទាំងខាងក្រៅ ទាំងខាងនយោបាយ ទាំងការទូត ។ វាខិតខំរើបម្រះប្រកាច់ប្រកិន ដើម្បីយកឈ្នះលើបដិវត្តន៍យើង ។ តែវាត្រូវបរាជ័យលើកនេះធ្ងន់ធ្ងរជាងឆ្នាំមុនៗទៅទៀត ។ ត្រូវបរាជ័យទាំងក្រៅប្រទេស ទាំងក្នុងប្រទេស ទាំងផ្នែកយោធា ទាំងផ្នែកនយោបាយ ទាំងផ្នែកសេដ្ឋកិច្ច ទាំងការទូត ។ ក្នុងនេះ បរាជ័យធ្ងន់ធ្ងរជាងគេគឺខាងយោធា និងផ្នែកនយោបាយ ។ តាមរយៈនេះ យើងក៏ដណ្ដើមបានជ័យជម្នះធំជាងឆ្នាំមុន ទាំងផ្នែកយោធា ទាំងផ្នែកនយោបាយ ទាំងផ្នែកការទូត ។

## ចំណុចពិសេសទី៣

ទន្ទឹមនឹងការបរាជ័យរបស់ខ្មាំង និងជ័យជម្នះដ៏ធំធេងរបស់យើងក្នុងឆមាសទី១នេះ ខ្មាំងវាបានបំផ្លិចបំផ្លាញផែនការរបស់យើងមួយចំនួនដែរ ពិសេសផែនការ៣គោន និង៦គោនដែលយើងទទួលផល៩០ភាគរយហើយ ក៏យើងត្រូវបាត់បង់មួយចំនួនទៅវិញ ។ តាមតួលេខជាបឋម យើងឃើញថាបង់ខាតពី៣០ ទៅ៤០ភាគរយ ។

ទន្ទឹមនេះ ក៏វាបំផ្លិចបំផ្លាញដល់ជីវភាពប្រជាជនយើងមិនឲ្យសម្រេចបានតាមផែនការរបស់បក្ស ទាំងខាងផ្នែកស្បៀង ទាំងសម្លៀកបំពាក់ ទាំងជម្រករស់នៅ ។

## ចំណុចពិសេសទី៤

ដែលត្រូវចាប់អារម្មណ៍ ក្នុងឆមាសទី១ឆ្នាំ១៩៧៨ នេះ គឺខ្មាំងវាវាយយើងនេះ សំដៅរំលំរដ្ឋអំណាចរបស់បក្សកុម្មុយនីស្ដកម្ពុជា រំលំរបបសមូសភាពរបស់កម្មករ-កសិករ ដើម្បីបក្សមួយទៀតឡើងកាន់អំណាចហៅថា "បក្សពលកររកម្ពុជា" របស់យួន ហើយដែលយកទិសដៅសហព័ន្ធឥណ្ឌូចិនជាមូលដ្ឋាន ហើយវាយរបបសមូហភាពបច្ចុប្បន្ន យករបបឯកជន នាយទុនត្រឡប់មកវិញ ។

ក្នុងការប៉ុនប៉ងវាយរំលំរដ្ឋអំណាចសង្គមនិយម សមូហភាពរបស់យើងនេះ ខ្មាំងវាវាយលើសមរភូមិដឹកនាំ ។ បានសេចក្ដីថា ៖ ខ្មាំងយកចិត្តទុកដាក់ វាយកម្មាភិបាលល្អរបស់បក្សកុម្មុយនីស្ដកម្ពុជា ហើយរៀបចំកម្មាភិបាលរបស់បក្សពលករខ្ញុំយួនវិញ ។ ដូច្នេះហើយ បានជាខ្មាំងខំយកចិត្តទុកដាក់ប្រយុទ្ធជាមួយយើងដោយសម្ងាត់ និងដោយចំហ យកកម្មាភិបាលរបស់វាមកកាន់កាប់រដ្ឋអំណាចនៅគ្រប់មុខព្រួញ ដើម្បីរៀបចំលក្ខណៈសម្បត្តិ បង្កើនលក្ខណៈសម្បត្តិវាយរំលំកម្ពុជា វាយរំលំរដ្ឋអំណាចបដិវត្តន៍យើងដោយស្របច្បាប់ និងដោយអាវុធតែម្ដង ។ ការប្រយុទ្ធគ្នាលើសមរភូមិរដ្ឋអំណាចលើសមរភូមិដឹកនាំនេះ ឃើញទិដ្ឋភាពដែលប្លែក មានលក្ខណៈពិសេសដែលយើងត្រូវតែលើកក្នុងទីនេះដើម្បីជាបទពិសោធន៍តទៅមុខទៀតក្នុងការប្រយុទ្ធតស៊ូដណ្ដើមរដ្ឋអំណាចគ្នាទៅវិញទៅមក ។

## ពិសោធន៍ទី១

តាមពិសោធន៍ការប្រយុទ្ធរបស់យើងហូរហែពីមុនមកពិសេស ចាប់ពីរំដោះមកទល់សព្វថ្ងៃនេះ យើងប្រយុទ្ធមួយឆ្នាំៗរវាងយើងនិងខ្មាំង តឹងតែងជាប់រហូតដល់ឥឡូវនេះ យើងវាយកម្ទេចវាច្រើនដងថែមទៀត ។ នេះបង្ហាញឲ្យឃើញថា ការប្រយុទ្ធដណ្ដើមរដ្ឋអំណាច ជាការតស៊ូស៊ុតស្មាញ ហើយជាការតស៊ូជាបន្តបន្ទាប់ ។

ជាមូលដ្ឋាន បក្សទាំងមូល កងទ័ពទាំងមូល ប្រជាជនទាំងមូល បំពាក់បានគោលជំហរតស៊ូវណ្ណៈ ។ តែផ្នែកមួយចំនួន ហើយពេលវេលាខ្លះ ឱកាសខ្លះយើងស្ថិតនៅក្នុងសភាពសន្តិភាពនិយម យើងស្ថិតនៅក្នុងសភាពសុខសាន្ត យើងមិនក្ដៅគគុកក្នុងការតស៊ូ

វណ្ណៈ បានជាខ្មាំងវាធ្វើសកម្មភាពបាន ។ ឯខ្មាំងវិញ វាធ្វើសកម្មភាពវាយយើងជាប់ ។ នេះជាបទពិសោធន៍ ជាមេរៀនរបស់យើងមួយដែលយើងបានលើកហើយ តែត្រូវតែលើកទៀត ។

**ពិសោធន៍ទី២**

កន្លងមកយើងចាប់អារម្មណ៍ខ្មាំងទាំងខាងក្រៅ ទាំងខាងក្នុង ហើយចាប់អារម្មណ៍លើខ្មាំងខាងក្នុង ដែលវាបែកមុខហើយ ។ តែខ្មាំងខាងក្នុងដែលវាបង្កប់ដែលវាស៊ីរូងខាងក្នុងយើងអត្តនោម័តិច្រើន ។

ដូច្នេះក្នុងឆមាសទី១នេះ ដែលយើងឃើញច្បាស់ក្រឡែតជាងគេ គឺសភាពគ្រោះអាសន្នបំផុតរបស់ខ្មាំងដែលបង្កប់ខាងក្នុង ។ ខ្មាំងវាវាយយើងលើកនេះ គឺយកកម្លាំងខាងក្នុងជាមូលដ្ឋាន គឺខ្មាំងនៅក្នុងជនបទ នៅក្នុងក្រសួង មន្ទីរ ក្នុងកងទ័ព ឯខ្មាំងខាងក្រៅ ក៏គ្រាន់តែរួមផ្សំ ។

យើងបានឃើញពិសោធន៍ថ្មីនេះថែមទៀត ឃើញសភាពពិសពុលនៃខ្មាំងខាងក្នុងនេះថែមទៀត នាំឲ្យយើងមានមេរៀនជាវិធានការថា អំណេះតទៅ យើងត្រូវពង្រឹងគោលជំហរតស៊ូវណ្ណៈឲ្យកាន់តែរឹងប៉ឹងថែមទៀត ឲ្យកាន់តែក្តៅថែមទៀត ដើម្បីកម្ចាត់ខ្មាំងទាំងក្នុង ទាំងក្រៅ ពិសេសខ្មាំងខាងក្នុងនេះជាបន្តបន្ទាប់ ដើម្បីឲ្យវាបាត់ម្ចាស់ការ កុំឲ្យវាវាយសម្រុកលើបក្សយើងបាន លើបដិវត្តន៍យើងបាន ។

វិធានការដែលយើងលើកឡើងនេះ មិនមានអីខុសប្លែកពីវិធានការមុនៗទេ តែយើងត្រូវសម្រួចគោលជំហរ វាយកម្ចាត់ខ្មាំងខាងក្នុងនេះ ឲ្យកាន់តែស្រួចស្រាវថែមទៀត មានវិធានការដាច់ខាតជាបន្តបន្ទាប់ ជាមួយខ្មាំងសត្រូវខាងក្នុងតទៅទៀត ពីព្រោះខ្មាំងខាងក្នុងវាយកនាមជាកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ជាកម្មាភិបាលរបស់ប្រជាជនកម្ពុជា តែធាតុពិតរបស់វា ជាកម្មាភិបាលរបស់បក្សពលករកម្ពុជារបស់យួន ជាកម្មាភិបាលរបស់ សេ.អ៊ី.អា ដើម្បីវាយរំលំរបបសមូហភាព វាយរំលំបក្សកុម្មុយនីស្តកម្ពុជា ដើម្បីបក្សពលករក្បត់របស់យួន សម្រាប់ សេ.អ៊ី.អា សម្រាប់យួនមកវិញ យករបបឯកជន នាយទុនមកវិញ ។ នេះជាគ្រោះថ្នាក់ចំពោះប្រជាជនកម្ពុជាយើង ចំពោះពូជសាសន៍កម្ពុជាយើង ។

## ២) ពិនិត្យអំពីសភាពការណ៍ អនុវត្តភារកិច្ចការពារប្រទេស

ទី១) មជ្ឈិមបក្សបានលើកភារកិច្ច ការពារក្បាលម៉ាស៊ីនដឹកនាំ ៈ

ទី២) ការពាររដ្ឋអំណាចកម្មករ-កសិកររបស់បក្ស ហើយការពារកម្ពុជាប្រជាធិបតេយ្យ ការពារបូរណភាពដែនដីកម្ពុជា ការពារឯករាជភាពរបស់កម្ពុជា ។

ភារកិច្ចការពារខាងលើនេះ មានលក្ខណៈគ្របដណ្តប់ទាំងអស់ ។ បើការពារបាន គឺដោះស្រាយបញ្ហាដទៃទៀតក៏បាន ។ បើការពារមិនបានគឺជះឥទ្ធិពលអាក្រក់ដល់ផ្នែកដទៃទៀតទាំងអស់ ។ ក្នុងឆមាសទីមួយនេះ បញ្ហាដែលលេចធ្លោឡើង គឺផ្នែកយួន ផ្នែកសូវៀត និងបក្ខពួក ខិតខំរើបម្រះយ៉ាងខ្លាំង វាយរំលំបក្សកុម្មុយនីស្តកម្ពុជា ។

មួយផ្នែកទៀតពួក សេ.អ៊ី.អា ក៏វារួមសហការជាមួយយួន និងសូវៀត ដើម្បីវាយបក្សកុម្មុយនីស្តកម្ពុជាដែរ ដោយយកកម្លាំងយួនជាសំខាន់ ។

សុំលើកព្រឹត្តិការណ៍ជាបន្តបន្ទាប់ ដែលខ្មាំងវាយយើងដូចតទៅ ៈ

**ទី១) គឺវាយពីក្រៅ ៈ**

ខែធ្នូ ខ្មាំងវាយយើងធំ ។ វាយនេះ គឺវាយទូទាំងប្រទេសដោយកម្លាំងវាចាត់តាំងដូចតទៅ ៈ

◆ ខាងកើតគឺយួនវាយយើងតាំងពីរតនគិរីរហូតដល់កំពត ដោយប្រើប្រាស់កម្លាំងតាមកន្លែងយុទ្ធសាស្ត្រ និងរួមផ្សំ ។ កន្លែងយុទ្ធសាស្ត្រសំខាន់ គឺបូពា៌ និង និរតី ក្នុងនេះគឺយកបូពា៌ជាកម្លាំងមូលដ្ឋាន និងគន្លឹះ ។

សំណូមពររបស់ខ្មាំងយួន គឺដណ្តើមភូមិភាគបូពា៌ឲ្យបាន ហើយឈានពីភូមិភាគបូពា៌ដណ្តើមយកកន្លែងផ្សេងទៀត ។

ឯទិសដៅយកភូមិភាគបូពា៌ គឺតាមពីរមុខព្រួញ ៈ

មុខព្រួញផ្លូវជាតិលេខ១ ពីបាវិត មកស្វាយរៀង មកអ្នកលឿង ។ បើវាយកផ្លូវជាតិលេខ១បាន វាយកភាគខាងត្បូងនៃភូមិភាគបូពា៌បាន ។

មុខព្រួញទីពីរ គឺផ្លូវលេខ៧ ។ បើយកផ្លូវលេខ៧ បាន គឺវាយកភាគខាងជើងនៃភូមិភាគបូពា៌បាន ។ វាយកភូមិភាគបូពា៌បាន

វាកាត់ផ្លូវទឹកបាន ហើយយកភូមិភាគឦសានបាន ។

◆ ឃើញសភាពយ៉ាងនេះ បានឃើញសមរភូមិជាយុទ្ធសាស្ត្រ គឺភូមិភាគបូព៌ា ។

ទន្ទឹមនឹងនេះ អាខាងលិចក៏វាធ្វើសកម្មភាព ។ អាខាងលិចនេះនិយាយរួមវាខ្សោយ ប៉ុន្តែវាមានផែនការរួមផ្សំជាមួយអាខាងកើត ។ សំណូមពរទី១ គឺរួមផ្សំកៀកបដិវត្តន៍កម្ពុជាឲ្យលំបាក ។ សំណូមពរទី២ គឺវាយកដីខ្លះ ដើម្បីវាបានខ្លួនឯងខ្លះ ។ តែកម្លាំងវាខាងជើងគោកវាតិចទេ ។ សំខាន់វាគិតគូរខាងជើងទឹក ។ ក្នុងពេលនោះមានកប៉ាល់ចម្បាំងអាមេរិកមួយគ្រឿង មកសុំចតនៅកំពង់ផែថៃ ។ ទន្ទឹមនេះវាធ្វើសកម្មភាពតាមសមុទ្រ ។ នេះជាផែនការសហការវវាង សេ.អ៊ី.អា, សូវៀត និង យួន នៅក្នុងនេះយួនដើរតួជាងគេបំផុត ។

នេះជាផែនការវាយពីក្រៅ ។ វាយពីក្រៅនេះមានលក្ខណៈធំណាស់ ។ យកឧទាហរណ៍ តែការប្រើប្រាស់កម្លាំង និងគ្រាប់រំសេវ ខ្មាំងវាប្រើច្រើនជាងមុនៗ ។ កម្លាំងទ័ពខ្មាំងយួនវាប្រើ១១ កងពលស្រួច នៅក្នុងនេះ មានកងពលឆ្នើតមួយចំនួនៈ គឺកងពលទី៩ កងពលទី៥ កងពលទី២ និងកងពលទី៣ ។ កងពលមកពីខាងជើង គឺ កងពល៣២០ ។ ទន្ទឹមនេះ កាំភ្លើងធំច្រើនរយគ្រឿង រថក្រោះច្រើនរយគ្រឿង ហើយមានទីប្រឹក្សាសូវៀតទៀត ។

វាចង់បុកមួយវគ្គនេះយកកម្ពុជាតែម្តង ។ តែវាវាយយើងមិនបាន ។ យើងវាយវាឲ្យបាក់ ក្នុងសភាពដែលពេលនោះ យើងមិនទាន់បានរៀបចំស្រួលបួលផង ។

តែវាបរាជ័យហើយ វាមកវាយយើងទៀត ។ វាប្រើបីកងពលមួយកន្លែងៗ ។ តាំងពីខែ១១ រហូតដល់ខែ៤ ខែ៥ -៧៨នេះ ។ ដូច្នេះផែនការវាធំណាស់ខាងផ្លូវយោធា ។ ប៉ុន្តែដោយយើងវាយវាបាក់ អាខាងលិចអត់ហ៊ានធ្វើសកម្មភាពអ្វីធំដុំទេ ។

### ទី២) គឺវាយពីក្នុង

- ◆ វាយខាងយោធា
- ◆ វាយខាងនយោបាយ
- ◆ វាយខាងសេដ្ឋកិច្ច
- ◆ វាយក្បាលម៉ាស៊ីនដឹកនាំ

### វាយខាងយោធា

អង្គភាពយោធានៅបូព៌ា ក្នុងមួយវរៈសេនាធំ វាចាត់តាំងមួយវរៈសេនាតូចមកវាយយើងពីក្រោយខ្នង ហើយមួយស្រុកៗ វាចាត់តាំងមួយអនុសេនាធំ វាយយើងពីខាងក្រោយខ្នងទៀត ។ នៅខាងក្រចេះក៏ដូច្នោះដែរ ។ វាយខាងយោធាមួយទៀត គឺវាត្រៀមវាយភ្នំពេញ ។ វាយភ្នំពេញមានពីរផ្នែក វាយពីក្នុង និង វាយពីក្រៅ ។

វាយពីក្រៅ គឺដោយប្រើកម្លាំងតំបន់២២ និយាយរួម ហើយមុខកំពូលនិយាយដោយឡែក ។ មុខកំពូលរួមជាមួយពញាពុ ។ ២៥ក៏ត្រូវវាយរួមផ្សំពីខាងត្បូងដែរ ។ វាយពីក្នុង គឺដោយប្រើកម្លាំងមន្ទីរ ពីព្រោះវាគ្មានកងទ័ពៈ ឧទាហរណ៍ ដូចជា ក្រសួងឧស្សាហកម្ម សង្គមកិច្ច ពេទ្យ ក្រសួងវប្បធម៌ ។ កម្លាំងទាំងនេះមិនមែនជាកងទ័ពទេ តែជាកម្លាំងឈ្លប ។ វាវាយពីរទិស ពីខាងក្រៅផង ពីខាងក្នុងផង ។ ឯវាយខាងក្នុងគឺសំដៅវាយក្បាលម៉ាស៊ីនដឹកនាំ ។ តែវាវាយយើងមិនបាន ។ យើងវាយវាមុន ។ ផែនការវាល្អិតដែរ តែវាប្រទាក់ក្រឡាគ្នាមិនបានល្អទេ ។

### វាយខាងនយោបាយ

គឺកម្ទេចក្បាលម៉ាស៊ីនដោយប្រើថ្នាំបំពុល ។ វារៀបចំល្អិតល្អន់របស់វាដែរ ។ យើងវាយលើកនេះ គឺវាយចំក្បាលម៉ាស៊ីនក្បត់ ។ ពីមុនយើងស្មានតែវាយចំក្បាលវា តែការពិតមិនមែនទេ ។ ឥឡូវនេះយើងវាយចំក្បាល ។ បើនៅសល់ទៀតគឺជាដៃជើងទេ ។ បើវាឈ្នះ គឺបាត់ពូជសាសន៍កម្ពុជា ។ ការដែលយើងវាយបាននេះ គឺជាការកម្ចាត់ សេ.អ៊ី.អា សូវៀត និងយួន ។ មូលហេតុដែលយើងដណ្តើមជ័យជម្នះនេះបាន គឺបក្សទាំងមូលប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ ។ នេះជាគុណសម្បត្តិ ។ ប៉ុន្តែការខ្វះខាតរបស់យើង គឺចំណុចប្រុងប្រយ័ត្នមិនទាន់ដល់កម្រិតទេ នៅស្ទើកស្រពន់ នៅសន្តិភាពនិយម ផ្នែកណាខ្លះមិនបានប៉ាន់ប្រមាណ នូវសភាពសកម្មប្រយុទ្ធរបស់ខ្មាំង ពិសេសខ្មាំងខាងក្នុង ។

បច្ច័យគឺវាធ្វើសកម្មភាពបានមួយកម្រិតដែរ ហើយប្រកិតយើងដែរ ។ បើខុសគ្នាត្រឹមតែ៤-១០ ថ្ងៃទេ ។

◆ វិធានការតទៅមុខទៀត គឺត្រូវប្រុងប្រយ័ត្នបដិវត្តន៍ឲ្យកាន់តែខ្ពស់ ពិសេសខ្មាំងខាងក្នុង ។ ដើម្បីឃើញខ្មាំង តើមានវិធីយ៉ាងម៉េច? តាមពិសោធន៍គឺៈ

◆ បើកន្លែងណា បុគ្គលណាអនុវត្តមាគ៌ាដោយ “ឆ្វេង” ជាខ្សែសង្វាក់គឺមានបញ្ហាហើយ ។

◆ បើកន្លែងណា បុគ្គលណាអនុវត្តមាគ៌ាដោយ “ស្តាំ” ជាខ្សែសង្វាក់ គឺមានបញ្ហាហើយ ។ ដូច្នេះ ចំពោះបុគ្គលទាំងនេះត្រូវមានវិធានការ ។ វិធានការដោយអប់រំ កសាង ដោយដក ឬដោយវិធានការខ្ពស់ជាងនេះទៀត ។

◆ មូលដ្ឋានណា អង្គភាពណា ដែលជីវភាពប្រជាជនដុនដាបដោះស្រាយមិនរួចក្នុងរយៈ៣ឆ្នាំជាបន្តបន្ទាប់ គឺមានបញ្ហាហើយ ឬគ្មានសមត្ថភាព ឬជាខ្មាំង ។

បើមិនទាន់មានភស្តុតាងអីត្រូវដកសិន ហើយបើមានឯកសារច្បាស់លាស់ ត្រូវមានវិធានការទៅតាមនេះទៀត ។

ប៉ុន្តែចំពោះបញ្ហាអត់បាយ ពីឆ្នាំ១៩៧៨ នេះទៅ បើអត់បាយតែមួយឆ្នាំគឺមានបញ្ហាហើយ ពីព្រោះលក្ខណៈសម្បត្តិវាគ្រប់គ្រាន់ហើយ ប្រជាជនធ្លាប់ឆ្លងកាត់ហើយ ទឹក ពូជ ដី ក៏មានគ្រប់អស់ហើយ ។ ភូមិភាគមួយ ក៏ត្រូវពិនិត្យយ៉ាងនេះ ។ តែស្រុកមួយ តំបន់មួយ សហករណ៍មួយ ក៏ត្រូវពិនិត្យយ៉ាងនេះដែរ ។

ចំពោះអ្នកដែលទទួលការចាត់តាំងពីខ្មាំងសុំលើកជាមតិរបស់បក្សដូចតទៅៈ

ទី១) បុគ្គលណាជាខ្សែក្បត់របស់យួន ឬរបស់ សេ.អ៊ី.អា មុនឆ្នាំ១៩៦៨ មិនមានទោសទេ បើគ្មានសកម្មភាពអីទេ មកក្រោយទៀត ។ យើងកំណត់ថាៈ ជាការភាន់ច្រឡំ ក្នុងកាលៈទេសៈលំបាកពេលនោះ ។

ទី២) ពី ៦៨ មក ៧០ បក្សយើងមានអត្តភាពរបស់ខ្លួនហើយពន្លឺមាគ៌ា អត្តភាពនយោបាយរបស់បក្ស ខ្លួនខបក្ខម្មខ្លួនមានអស់ហើយ ។ តែបើចូល សេ.អ៊ី.អា ឬចូលយួន ពេលនោះក៏មិនយកទោសពៃរ៍អីដែរ ។ យើងកំណត់ថាៈ ពេលនោះ ការតស៊ូនៅមានការលំបាកដែរ ។ ដូច្នោះអាចសម្ងំសុខ ។ ការនេះមិនត្រូវទេ តែយើងអនុគ្រោះបាន ។

ទី៣) ពី៧០ មក ៧៥ អត្តនោម័តិ យើងកាន់តែខ្លាំងហើយ ។ តែទោះជាមានការភាន់ច្រឡំទៅចូលយួន ឬចូល សេ.អ៊ី.អា ក៏សន្មតថា មិនមានទោសពៃរ៍អីដែរ ព្រោះចាញ់និងឈ្នះ នៅចោទនៅឡើយ ។ ខុសគឺខុសហើយ តែការខុសនេះទុកជាផ្ទៃក្នុង ។


កសិករសហករណ៍ និងកងទ័ពបដិវត្តន៍ នៅភូមិភាគនិរតីវាយសម្រុកជីកព្រែក



ទី៤) ចាប់ពី៧៥ ក្រោយរំដោះមកដល់បច្ចុប្បន្ន សុំចែកជាពីរៈ

◆ អ្នកដែលចូលខ្មាំង ធ្វើសកម្មភាពប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា ប្រឆាំងនឹងរបបសម្ពូហភាពសង្គមនិយម អ្នកទាំងនេះត្រូវមានទោស ពីព្រោះធ្វើសកម្មភាពដោយភ្ញាក់រឭក ដោយពេញចិត្តពេញថ្លើមបម្រើ សេ.អ៊ី.អា ។ បម្រើយួន ។

◆ ចំពោះបុគ្គលណាដែលនៅកាន់ច្រឡំពី៧៥មក ហើយពីនេះតទៅមុខទៀត មិនធ្វើសកម្មភាពអ្វី ។ ដោយសម្តែងកំហុសក្តី ដោយមិនសម្តែងក្តី តែឈប់ធ្វើសកម្មភាព ខិតខំកែប្រែ ខិតខំបំពេញភារកិច្ច ក៏មិនមានទោសពៃរ៍អីទេ ។ នេះដោយគោលជំហររបស់បក្សចង់ស្រោចស្រង់មនុស្ស ពីព្រោះបើវាយមួយ វាមិនមែនប៉ះតែម្នាក់ទេ វាប៉ះ៤-៥នាក់ ។ ដូច្នេះយើងចង់បន្ថែមមិត្ត ។

ប៉ុន្តែបើនៅតែធ្វើសកម្មភាពតទៅទៀត គឺព្រំដែនរបស់គេច្បាស់ ។ ដូច្នេះបក្សកុម្មុយនីស្តកម្ពុជា ត្រូវតែកម្ចាត់ ។

បក្សយើងលើកមាគ៌ានេះដើម្បីៈ

១) ប្រមូលកម្លាំង

២) ដើម្បីវាយខ្មាំង

ដើម្បីវាយខ្មាំងបាន យើងត្រូវប្រមូលកម្លាំង ។ ដើម្បីមហាជនគេយល់ ដើម្បីមហាជនជាកម្លាំងគាបខ្មាំង ។ បើមហាជនយល់ ខ្មាំងវាធ្វើសកម្មភាពគេឃើញ ។ ដូច្នេះបានជាអ្នកណាកាន់ច្រឡំកាលមុនរំដោះ ក៏ទុកជាខុស តែមិនយកទោសពៃរ៍ទេ ។ តែក្រោយរំដោះហើយ អ្នកណាធ្វើសកម្មភាពបម្រើ សេ.អ៊ី.អា បម្រើយួន គឺធ្វើដោយភ្ញាក់រឭក ដោយយល់ ។ ត្រូវមានទោស ។ តែបើតទៅមុខទៀតឈប់ធ្វើក៏គ្មានរឿងរ៉ាវអី ។ យើងលើកមាគ៌ានេះ ដើម្បីប្រមូលកម្លាំង ។

ទីពីរ ដើម្បីធ្វើឲ្យស៊ប់ ។ កុំឲ្យខ្មាំងវាបង្កើលឲ្យរត់ចូលស៊ីងវា ហើយកន្ទេលមក ខ្មាំងវាបង្កើលបានច្រើនដែរ ។ កម្មាភិបាល យុទ្ធជន-យុទ្ធនារី ដែលមានការខុសឆ្គងបន្តិចបន្តួច ខ្មាំងវាបង្កើល ។ ខុសខាងសីលធម៌ក៏ដោយ ក៏មិនទាន់បដិបក្ខទេ យើងត្រូវស្រោចស្រង់ ។

ម្យ៉ាងទៀត ដែលគួរឲ្យស្តាយកម្លាំង គឺខ្មាំងវាបង្ខូចសីលធម៌ ហើយវាបង្កើល ។ អានេះ ជាផែនការរបស់ខ្មាំង ។ ដូច្នេះ បានជា

មានរឿងសីលធម៌គ្រប់ទីកន្លែង ។

រឿងសីលធម៌វាមានពីរយ៉ាង ៖

◆ ម្យ៉ាងជាកំហុស ដែលជាសំណល់សង្គមចាស់

◆ ម្យ៉ាងជាផែនការរបស់ខ្មាំង

ឥឡូវយើងផ្សាយមាគ៌ានេះ ដើម្បីវាយសម្រុកខ្មាំងវិញ ។ ធ្វើឲ្យមហាជនយល់មាគ៌ានេះ ដើម្បីគេវាយសម្រុកខ្មាំងវិញ ។ នេះហៅថាប្រមូលកម្លាំងវាយខ្មាំង ។ ពីមុនមហាជនគេមិនយល់ មានការខុសឆ្គងបន្តិចបន្តួច ខ្មាំងវាបង្អើលបាន ។ បើមហាជនគេយល់ខ្មាំងវាបង្អើលគេ គេវាយសម្រុកវាវិញ ។

ម្យ៉ាងទៀតបក្សយើងលើកមាគ៌ានេះ ដើម្បីបញ្ជាក់ក្នុងផ្ទៃក្នុងបក្ស ផ្ទៃក្នុងប្រជាជន ពីព្រោះអ្នកខ្លះមិនចង់វាយបក្សទេ តែខ្មាំងវាតាមដាប់ សង្កត់ដាប់ ថាបើអ្នកឯងមិនបន្តសកម្មភាព អ្នកឯងគង់តែស្លាប់ ពីព្រោះអ្នកឯងជា សេ.អ៊ី.អា អ្នកឯងចូលយួន ។ ឯបក្សយើងមិនប្រានគេទេ ត្រូវតែទាញគេ ។ ដើម្បីទាញត្រូវអប់រំឲ្យគេយល់វិធានការរបស់បក្ស ។ ត្រូវប្រទាញ ត្រូវប្រយុទ្ធបណ្តើមកម្លាំងរវាងខ្មាំងនិងយើង ។ កុំប្រើពាក្យស្លោកគំរាម ប្រានកម្លាំង ។ ត្រូវប្រើពាក្យស្លោកប្រមូលកម្លាំង ។ នេះជាការប្រយុទ្ធតឹងតែង ។ ជាការប្រយុទ្ធតឹងតែង ស៊ុតស្វាញជ្រាលជ្រៅ តែកម្លាំងបដិវត្តន៍ខ្លាំងជាង ។ ជាបុគ្គលក៏យើងខ្លាំងជាង ជាចលនាក៏យើងខ្លាំងជាង ។ ខ្មាំងវាមិនហ៊ានលើកពាក្យស្លោកវាយបដិវត្តន៍ដោយចំហទេ គឺមកពីមហាជនគេមាននិន្នាការទៅរកបដិវត្តន៍ ។ យុទ្ធជន-យុទ្ធនារី គេមាននិន្នាការទៅរកបដិវត្តន៍ ។ ការដែលយើងបានដោះស្រាយពួកក្បត់ទាំងនេះ នាំឲ្យកិច្ចការពារប្រទេសរបស់យើងបានល្អប្រសើរ ។ ធ្វើឲ្យខ្មាំងខាងក្រៅវាដាច់ដៃដាច់ជើង ។

លទ្ធផលទី២ គឺខាងបង្កបង្កើនផល ។ ដូចនៅបូព៌ា ប្រជាជនធ្វើបានច្រើនដែរ ។ តែនារីនៅស្រុកប្រសូត្រ ចន្ទ្រា កំពង់រោទិ៍ ខ្វះខាតសំពត់អាវ ។ នៅស្រុកទ្រមូងក៏ដូច្នេះដែរ ។ ប្រជាជនខ្វះខាតស្បៀង ។ ស្រុកឆ្លូង ស្រុកក្រូចឆ្មារក៏ខ្វះខាត ។ ដល់យើងដោះស្រាយខ្មាំងបាន យើងដោះស្រាយស្បៀង សម្លៀកបំពាក់ ហើយដោះស្រាយបង្កបង្កើនផលបាន ។ ឧទាហរណ៍ ស្រុកក្រចេះ ពីមុនខ្វះខាតស្បៀង ។ ឥឡូវខេត្តក្រចេះ មករ៉ាប់រងខាងស្បៀងឲ្យស្រុកឆ្លូងនិងស្រុកទ្រមូងបាន ។ ត្រង់នេះចង់បញ្ជាក់ថា ក្នុងបញ្ហាដោះស្រាយជីវភាពប្រជាជនក្តី បង្កបង្កើនផលក្តី កត្តាកំណត់គឺរដ្ឋអំណាច ។ បើរដ្ឋអំណាចជារដ្ឋអំណាចរបស់បក្សពិតប្រាកដ គឺខ្លាំង ជីវភាពប្រជាជនក៏ដោះស្រាយបាន បង្កបង្កើនផលក៏ខ្លាំង ការពារក៏ខ្លាំង ។ ដូច្នេះជាពិសោធន៍ គឺបើកន្លែងណាខ្វះខាតស្បៀងហើយ ត្រូវតែរៀបចំរដ្ឋអំណាចថ្មីឡើងវិញ ។

## ទិសវិវត្តទៅមុខទៀតយ៉ាងម៉េច?

សភាពការណ៍ ការពារក្នុងឆ្នាំ១៩៧៧ ក៏យើងឃើញថាល្អ ពីព្រោះអស់ អាធុច អស់ អាយ៉ា អស់ អាចក្រី ។ល ។ សកម្មភាពរបស់ខ្មាំងក្នុងឆ្នាំ១៩៧៨ វាស្ថិតក្នុងសភាពដែលកម្លាំងវានៅសេសសល់តិចជាងមុន ។ យើងបោសសម្អាតវាទៅ សភាពការណ៍កាន់តែល្អជាងឆ្នាំ១៩៧៧ ។

### នៅព្រំដែនខាងលិច ៖

ពីមុនវាវាយសម្រុកយើង រហូតដល់វាមកចាត់តាំងរដ្ឋអំណាចក្បត់តាមព្រំដែនបាន១-២ភូមិ ដូចនៅខាងពាយ័ព្យ និងខាងឧត្តរ ។ ឥឡូវសភាពការណ៍ធូរស្រាលជាអតិបរមា ទាំងនៅក្នុងដែនដីយើង ទាំងនៅខាងថៃ រហូតដល់បដិវត្តន៍ថៃ វាយសម្រុកវាខ្លាំងថែមទៀត ។ ឥឡូវវាស្ថិតនៅក្នុងសភាពការពារ វាមិនមែនស្ថិតនៅក្នុងសភាពវាយសម្រុកទេ ។ ផ្លូវគមនាគមន៍របស់ថៃ នៅតាមព្រំប្រទល់យើងដាច់ វាប្រើប្រាស់មិនបាន ។ ភូមិជាច្រើនរបស់ប្រជាជននៅតាមព្រំប្រទល់ វាត្រូវដកទៅក្នុង ។ ទីតាំងរបស់វាក៏ត្រូវដកមួយចំនួន ។ អ្នករកស៊ីនៅតាមស្រុក តាមព្រំប្រទល់ត្រូវរត់ទៅខេត្ត ។ អ្នកមានខ្លះៗនៅតាមខេត្ត ត្រូវរត់ទៅបាងកក ។ ដំបូងក្នុងឆ្នាំ១៩៧៥-១៩៧៦ ខ្មាំងវាព្រហើនមើលងាយយើង ។ ឥឡូវវាក្រញោន ។

### នៅព្រំដែនខាងកើត ៖

ពីឆ្នាំ១៩៧៥ រហូតមកដល់ឆ្នាំ១៩៧៨ វាវាយយើងមិនបាន តទៅមុខទៀត រឹតតែវាយយើងលែងបាន ។ ខែ១១ ខែ១២ ឆ្នាំ១៩៧៧ វាប្រើកម្លាំងធំវាយយើងដោយមិនឲ្យយើងដឹងខ្លួនមុន វាវាយយើងមិនបាន ។ តទៅមុខទៀត វារឹតតែវាយយើងលែងបាន ។ ផ្ទុយទៅវិញ ចាប់ពីខែ១ ឆ្នាំ១៩៧៨មក យើងវាយសម្រុកវាវិញ ។ ក្នុងនេះយើងវាយវា១០ វាវាយយើងបានតែបួនទេ ។ ដូច្នេះមុខព្រួញខ្លះ វាវាយបុកយើង ។ តែស្ថានការទូទៅ

យើងវាយបុកវា ។ តទៅមុខទៀត យើងមានលទ្ធភាពវាយបុកខ្លាំងបានច្រើនថែមទៀត ។

**ឯខាងយួនវិញវាខ្វះកម្លាំង៖**

១) យើងកម្ទេចអស់កម្លាំងរស់វាច្រើនណាស់ ចាប់ពីខែ ១១ ឆ្នាំ១៩៧៧ មកដល់ឥឡូវ ពិសេសនៅនិរតី ។ ខ្លាំងយួនវាចាប់ទាហានថ្មីមកពីខាងជើងក្ដី យកពីខាងត្បូងក្ដី ក៏មានការលំបាកខ្លាំងណាស់ ។ វាគ្មានកម្លាំងយុទ្ធសាស្ត្រដើម្បីវាយបុកយើងទេ មានតែកម្លាំងយុទ្ធវិធីដើម្បីការពារ ។

២) ក្នុងសភាពយួនមានការលំបាកយ៉ាងនេះ ឥឡូវវាមានការលំបាកថែមទៀត ។ យើងបានពិនត្យទិសវិវត្តពីឆ្នាំ១៩៧៥ រហូតមកដល់ឥឡូវ គឺត្រឹមត្រូវ ។ យុទ្ធសាស្ត្រយួន គឺយកលាវ ហើយហ៊ុមព័ទ្ធកម្ពុជា ។ ឥឡូវយួនកំពុងតែចាញ់នៅកម្ពុជា ។ ឯលាវអត់មានអីមកវាយយើងបានទេ ។ ថៃ និងអាស៊ីអាគ្នេយ៍អត់ទៅជាមួយវាទេ ។ បដិវត្តន៍ថៃ និងបដិវត្តន៍អាស៊ីអាគ្នេយ៍ យួនក៏វាមិនចុះ ។ ឥឡូវយួនទំនាស់ជាមួយនឹងចិនទៀត ។ រឿងនេះជាយុទ្ធសាស្ត្រនយោបាយ យុទ្ធសាស្ត្រយោធារបស់សូវៀត ។ ឥឡូវឈ្លោះគ្នាជាចំហហើយ ។ ដូច្នេះវាមិនហ៊ានដកកម្លាំងមកពីខាងជើងមកវាយកម្ពុជាទេ ។ ដកជាកងពលមិនបានទេ ។ ដកជាកម្មាភិបាលពីនេះពីនោះអាចបានខ្លះ ។ វាចាប់កម្លាំងពីខាងត្បូងក៏មិនបានដែរ ។

៣) វាលំបាកខាងសេដ្ឋកិច្ចយូរមកហើយ ។ ឥឡូវចិនកាត់ជំនួយទៀត ។ តាមយួនថា ចិនកាត់៧២គម្រោង ។ ត្រង់នេះធ្វើឲ្យយួនរឹតតែមានការលំបាក ។ លំបាកយោធា លំបាកសេដ្ឋកិច្ច ។ ដូច្នេះនាំឲ្យលំបាកខាងនយោបាយទៀត ។ ដូច្នេះយួនមិនមែនស្ថិតក្នុងសភាពវាយសម្រុកទេ ។ យើងស្ថិតក្នុងសភាពវាយសម្រុកទាំងយោធា ទាំងនយោបាយ ទាំងសេដ្ឋកិច្ច ទាំងការទូត ។

**វិធានការ៖**

១) បន្តសម្អាតផ្ទៃក្នុងបក្ស កងទ័ព រដ្ឋអំណាច ឲ្យកាន់តែស្អាតបរិសុទ្ធថែមទៀត ។

២) ជំរុញការវាយសម្រុកនៅតាមព្រំប្រទល់ឲ្យខ្លាំង ក្នុងឋានៈកម្ទេចកម្លាំងរស់ កម្ទេចនយោបាយ កម្ទេចសេដ្ឋកិច្ចខ្លាំង ។



កសិករនៅស្រុកភ្នំស្រុក ជញ្ជូនថ្មយកទៅលាយជាមួយបាយអសម្រាប់ធ្វើទ្វារទំនប់

ទំនាស់រវាងបដិវត្តន៍យើង និងប្រឆាំងបដិវត្តន៍ តើជាទំនាស់អី? កម្លាំងអីប្រឆាំងបដិវត្តន៍យើង?

ការលើកឡើងនេះដើម្បីពិគ្រោះគ្នា ហើយយើងនឹងពិនិត្យជាបន្តបន្ទាប់ទៀត ពីព្រោះបញ្ហានេះជាបញ្ហានយោបាយ ។ តាមសកលលោកធ្លាប់លើក គឺជាទំនាស់រវាងសង្គមនិយម និងនាយទុន ។ បញ្ហានេះត្រឹមត្រូវជាមូលដ្ឋាន ហើយវិធានការត្រូវវាយមូលធននិយម ក៏ត្រឹមត្រូវជាមូលដ្ឋាន ។ តែនៅកម្ពុជាទំនាស់នេះ វាមានសភាពជាក់ស្តែងរបស់វាដែលយើងត្រូវពិនិត្យ ។ និយាយរួមជាទំនាស់រវាងបដិវត្តន៍សង្គមនិយម និងមូលធននិយម ។ តែវាមានសភាពជាក់ស្តែងទៀតដែលត្រូវពិនិត្យ ។ ក្រោយរំដោះភ្លាម វាចាប់ផ្តើមវាយយើងភ្លាម ។ តើនរណាវាយយើង? គឺ សេ.អ៊ី.អា យួន កា.ហ្សេ.បេ ។ យើងមិនដែលឃើញសមាសភាពជានាយទុនធម្មតា អនុធនធម្មតាទេ ។ ដូច្នេះបានជាចង់សង្កត់ថា បើនិយាយរួមៗថា មូលធននិយម ខ្លាចក្រែងទស្សនៈវិភាគរបស់យើងមិនច្បាស់ ហើយវិធានការវាយមិនត្រូវចំក្បាលដែលត្រូវវាយ ។ ក្បាលដែលត្រូវវាយ គឺ សេ.អ៊ី.អា យួន និង កា.ហ្សេ.បេ ។ តាំងពីឆ្នាំ១៩៧៥មក កម្លាំងដែលយើងវាយសុទ្ធតែ សេ.អ៊ី.អា និងយួន ។ អាចក្រី អាឈូក អាធុច អាខឿន អាភីម អាស៊ុំ អាកែវ មាស អាជ័យ ទាំងអស់សុទ្ធតែ សេ.អ៊ី.អា ។ គ្រាន់តែ សេ.អ៊ី.អា មួយ វាធ្ងន់ខាងអាមេរិក អាមួយវាធ្ងន់ខាងយួនជាង ។ ឯកសារជាបន្តបន្ទាប់



កងយុវជនបំពេញការងារបង្កបង្កើនផលប្រចាំថ្ងៃនៅក្នុងមន្ទីរ

ដែលវាបញ្ជាក់ថា ៖ មុនដិបូងវារួមជាមួយ អាណុល វាយកុម្មុយនីស្ត ។

នេះចង់បញ្ជាក់ថា ៖ ពួកខ្មែរក្បត់នេះ វានៅតែជាមួយ សេ.អ៊ី.អា នៅតែជាមួយយួន ហើយផ្ទៃក្នុងយួន សេ.អ៊ី.អា វាគ្របដណ្តប់ហើយ ។ សរុបមក មិនឃើញកម្លាំងឯណា ក្រៅពីពួកខ្មែរក្បត់ទាំងនេះទេដែលវាយយើង ។

កម្លាំងដែលប្រឆាំងបដិវត្តន៍យើងនេះ គឺអន្តការ សេ.អ៊ី.អា ដែលតំណាងឲ្យចក្រពត្តិអាមេរិក និងកម្លាំងប្រតិកិរិយាដទៃទៀត ហើយយួន និងសូវៀត ដែលវាចាត់តាំងខ្មែរក្បត់នៅកម្ពុជា ។ កម្លាំងនេះវាចាត់តាំងរួចមកហើយ វាកំពុងចាត់តាំង ហើយវាចាត់តាំងតទៅទៀត ។ កម្លាំងប្រឆាំងទាំងនេះ ជាភ្នាក់ងារចារកម្មរបស់ សេ.អ៊ី.អា របស់យួន និងរបស់សូវៀត ។ កម្លាំងទាំងនេះដែលយើងត្រូវវាយ ។

សរុបសេចក្តីទៅ គូទំនាស់ជាមួយយើង គឺ សេ.អ៊ី.អា យួន និង កា.ហ្សេ.បេ នៅក្នុងនេះ ពិសពុល ស្រួចស្រាវជាងគេ គឺយួន ។ ឈរលើការវិភាគទំនាស់ស្លាប់រស់ ស្រួចស្រាវនេះ តើវិធានការយើងវាយវាយ៉ាងម៉េច?

**១) វាយអាស្រួចជាងគេ គឺយួនឈ្លានពានលេបទឹកដី ។**

**២) ព្រមជាមួយនេះ វាយ សេ.អ៊ី.អា និង កា.ហ្សេ.បេ ។**

វាយព្រមជាមួយគ្នា ប៉ុន្តែយកចិត្តទុកដាក់វាយយួនជាងគេ ពីព្រោះវាស្រួចស្រាវពិសពុលជាងគេ ។ យួនវាស្រួចស្រាវ វាមិនមែនធំជាងចក្រពត្តិអាមេរិក ជាងសូវៀតទេ ។ តែធាតុរបស់វា វាត្រូវការយកកម្ពុជា ដើម្បីយកដីរស់នៅ ។ ចេញពីសេដ្ឋកិច្ចនេះបានជាចេញជានយោបាយយកកម្ពុជាចូលសហព័ន្ធឥណ្ឌូចិន ហើយចេញជាវិធានការវាយកម្ពុជាដោយយោធា ។ យួនវាស្រួចស្រាវម្យ៉ាងទៀតដោយយួនវាធ្វើផ្ទាល់ ។ ឯ សេ.អ៊ី.អា វានៅឆ្ងាយ ។ ប្រទេសវាអន្តការកណ្តាលវានៅឆ្ងាយ ។ កា.ហ្សេ.បេ ក៏ដូច្នេះដែរ ។ ទន្ទឹមនេះ យើងត្រូវពិនិត្យ តើប្រជាជនកម្ពុជាមានអ្វីទំនាស់ និងបដិវត្តន៍ ហើយមានអ្វីដែលឯកភាពជាមួយបដិវត្តន៍ ។

ក្នុងរយៈកាលបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ យើងប្រមូលកម្លាំងបានជាបន្តបន្ទាប់ ដើម្បីដណ្តើមបានជ័យជម្នះជាបន្តបន្ទាប់ ។ ប៉ុន្តែដោយប្រៀបធៀបកម្លាំងដែលយើងប្រមូលបានក្នុងរយៈកាលបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ និងរយៈកាលបដិវត្តន៍សង្គមនិយម គឺកម្លាំងប្រជាជនដែលយើងប្រមូលបានក្នុងរយៈកាលបដិវត្តន៍សង្គមនិយមខ្លាំងជាង និងច្រើនជាងកាលពីជំនាន់បដិវត្តន៍ប្រជាធិបតេយ្យ ។ ខ្លាំងជាង និងច្រើនជាងពីព្រោះបក្សយើងកាន់អំណាចទូទាំងប្រទេស ។ ម្យ៉ាងទៀតកសិករក្រ កសិករកណ្តាលថ្នាក់ក្រោមជាទូទៅមកខាងបដិវត្តន៍ ។ អនុធនសិស្ស និស្សិត មិនខ្លាំងដូចកសិករក្រ កសិករកណ្តាលថ្នាក់ក្រោមទេ ប៉ុន្តែជាទូទៅនៅជាមួយបដិវត្តន៍ ។ ភាគតិចទេដែលស្មុគស្មាញស្មាក់ស្មើរ ។ ត្រូវឃើញយ៉ាងនេះ បានឃើញថា បដិវត្តន៍យើងមិនមែនឯកោទេ ។ យើងមានកម្លាំងមហាជន ហើយយើងមានកម្លាំងមហាជនច្រើនជាងកាលបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យទៅទៀត ។

យើងមិនឃើញកម្លាំងអ្វីដែលខ្លាំងក្លា ដែលចេញមកពីប្រជាជនមកវាយបដិវត្តន៍យើងទេ ។ មានតែកម្លាំង សេ.អ៊ី.អា កម្លាំងយួន និងកម្លាំងសូវៀត ដែលវាវាយបដិវត្តន៍យើង ។

**៣) ពិនិត្យអំពីភារកិច្ច បន្តធ្វើបដិវត្តន៍សង្គមនិយម**

ក្នុង៦ខែកន្លងមកនេះ តើយើងមានគុណសម្បត្តិ និងការខ្វះខាតអ្វីខ្លះ? ជាគុណសម្បត្តិ ខាងបដិវត្តន៍សង្គមនិយម ៖

ទីមួយ យើងបានកម្ចាត់របបសក្តិភូមិនិយម មូលធននិយម ឯកជននិយមបន្តទៅទៀត ។ ទោះជាខ្លាំងរើយ៉ាងម៉េចក៏ដោយ ក្នុងឆមាសទី១ ឆ្នាំ១៩៧៨ ក៏វារើមិនរួច ។ យើងបានបន្តវាយតទៅទៀត ហើយដណ្តើមបានជ័យជម្នះ ខាងផ្នែកសតិអារម្មណ៍ នយោបាយចាត់តាំង ។ នៅក្នុងនេះ ជ័យជម្នះខាងផ្នែកចាត់តាំងដើរតួសំខាន់ ពីព្រោះយើងវាយក្បាលម៉ាស៊ីនក្បត់ដែលជាកម្លាំងជ្រៅផងទផងឯកជន- នាយទុនឲ្យវាខ្ទេចខ្ទី ។ វាយពួកនេះ បានសេចក្តីថា វាយទីតាំងសក្តិភូមិនិយម មូលធននិយម ឯកជននិយមឲ្យវាបរាជ័យ ។ ចក្រពត្តិនិយម ក៏បរាជ័យ សេរីនិយម ក៏បរាជ័យ ។ សក្តិភូមិ នាយទុននៅក្នុងប្រទេសក៏បរាជ័យ ។

បើវាយខាងចាត់តាំងយ៉ាងនេះ វាជួយខាងនយោបាយសតិអារម្មណ៍ខ្លាំងណាស់ ។ បើមិនវាយខាងចាត់តាំង គ្រាន់តែវាយខាងសតិអារម្មណ៍ វាយខាងនយោបាយគឺទៅមិនរួចទេ ពីព្រោះនរណាអ្នកផ្សព្វផ្សាយនយោបាយ សតិអារម្មណ៍ គឺកម្មាភិបាល ។ បើកម្មាភិបាលជា សេ.អ៊ី.អា យួន និងសេរី វាស៊ីរូង

ហើយ វាមិនផ្សព្វផ្សាយនយោបាយសតិអារម្មណ៍ទេ ។ យើងវាយពួកអាអស់នេះ គឺវាយកម្ចាត់ពិសពុលរបស់ខ្មាំង ។

តាមពិសោធន៍នេះ ទូទាំងប្រទេស ត្រូវបន្តខិតខំធ្វើការផ្សារនយោបាយសតិអារម្មណ៍ ដើម្បីឲ្យអ្នកល្អគេកាន់តែល្អ ។ តែទន្ទឹមនេះត្រូវខិតខំតស៊ូ ខាងចាត់តាំងវាយសមាសភាពដែលប្រឆាំងនឹងបដិវត្តន៍សង្គមនិយមខាងចាត់តាំង ។ បើយើងមិនគិតខាងចាត់តាំងទេ យើងប្រយុទ្ធជាមួយវាមិនឈ្នះទេ ។ ដូច្នេះ ពេលនេះ មានចំណុចពិសេសមួយដែលយើងបន្ថែម ។ គឺមិនមែនធ្វើបដិវត្តសង្គមនិយម ដោយតស៊ូតែខាងនយោបាយ សតិអារម្មណ៍តែប៉ុណ្ណោះទេ ។ ត្រូវតស៊ូវាយរដ្ឋអំណាចរបស់ខ្មាំង ពង្រឹងពង្រីករដ្ឋអំណាចរបស់បក្ស ។ បើមិនដោះស្រាយខាងចាត់តាំង យើងគាស់រំលើងខាងនយោបាយសតិអារម្មណ៍មិនបានទេ ។

**គុណវិបត្តិខាងផ្នែកបដិវត្តន៍សង្គមនិយម គឺ ៈ**

មួយរយៈនេះ យើងធ្ងន់ខាងការផ្សារនយោបាយ សតិអារម្មណ៍ ។ ការពិតការផ្សារនយោបាយ សតិអារម្មណ៍ វាជួយបំពាក់បំប៉នខាងនយោបាយ សតិអារម្មណ៍បដិវត្តន៍សង្គមនិយមហើយ តែវាមិនគ្រប់គ្រាន់ទេ ។ យើងអប់រំនៅសាលាតែខាងចាត់តាំងខ្មាំងវានៅជាប់ជាប្រចាំ វាបំពាក់បំប៉ន វាបំពុលតាមចិត្ត ។ ដូច្នេះត្រូវដាច់ខាតខាងចាត់តាំង ។ បើមិនដាច់ខាតខាងចាត់តាំងទេ អត់ធ្វើបដិវត្តន៍សង្គមនិយមកើតទេពីព្រោះអ្នកណាអ្នកធ្វើបដិវត្តន៍សង្គមនិយមនេះ ទាល់តែអ្នកដែលពេញចិត្តនឹងបដិវត្តន៍សង្គមនិយមនេះ បានធ្វើបដិវត្តន៍សង្គនិយមបាន ។

សមាសភាពខ្មាំង យើងត្រូវសម្រិតសម្រាំង សមាសភាពមិនល្អ ធម្មតា ក៏យើងត្រូវតែដកឲ្យទៅបំពេញភារកិច្ចផ្សេង ។ កុំអាងតែបក្ខជន កុំអាងតែយុវកក ពីព្រោះខ្មាំងវារៀបចំម៉ាស៊ីនក្បត់វាយមកយូរហើយ ។ ដូច្នេះបានជាត្រូវយកការតស៊ូខាងចាត់តាំងនេះជាគន្លឹះ ។ បើដោះស្រាយការចាត់តាំងបានហើយការអប់រំក៏រហ័ស ពីព្រោះគ្មានកម្លាំងប្រឆាំង ។

## ៤) ពិនិត្យអំពីភារកិច្ច កសាងសង្គមនិយម

ជាគុណសម្បត្តិ គឺយើងបានបញ្ចប់ភារកិច្ចឆ្នាំ១៩៧៧ ហើយបន្តការកសាងសង្គមនិយមក្នុង៦ខែកន្លងមក ដោយចលនាមហាជនសស្រាក់សស្រាំ ។ ភោគផលស្រូវបានច្រើន ។ ដោយឡែកតែភូមិភាគបូព៌ា បើគិតជាមធ្យម មួយហិកតាពីរតោនស្រូវនៅសល់មួយសែនតោនអង្ករ ។ តែឥឡូវយ៉ាងម៉េច ។ វាប្រមូលផលស្រូវអស់យកទៅឲ្យយួន ហើយវាយកទៅលាក់ដើម្បីវាយបដិវត្តន៍យើង ។ តែចង់និយាយថាផលិតផលបានច្រើន ។ ឯចលនាក្នុងឆមាសទីមួយខ្លាំងក្លា និយាយរួម ៈ ចលនាស្រូវដើមឆ្នាំ ចលនាទំនប់ប្រឡាយ ។ នៅកន្លែងខ្លះដែលពីមុនខ្វះ ឥឡូវគេហូបគ្រប់គ្រាន់ហើយ គេធ្វើដំណាំយុទ្ធសាស្ត្រជា ចេក ពោត ដំឡូង បានច្រើនទៀត ។

គុណវិបត្តិ ៈ ផលស្រូវខូចខាត ពី៣០ ទៅ៤០ភាគរយ ប៉ះពាល់ដល់ការនាំចេញមួយកម្រិត ទន្ទឹមនេះ ប៉ះពាល់ដល់ជីវភាពប្រជាជនមួយកម្រិត ។ ប្រជាជន២០ទៅ៣០ភាគរយ ខ្វះខាតហូបមិនបានតាមរបបរបស់បក្សកំណត់ ។ នេះជាការខ្វះខាតទី២ ។ ការខ្វះខាតទី៣ ដែលជាមូលហេតុសំខាន់ គឺការខ្វះខាតមិនបានកម្ចាត់នូវសមាសភាពបំផ្លិចបំផ្លាញក្នុងការកសាងសង្គមនិយមឲ្យទាន់ពេលវេលា ។

### វិធានការដោះស្រាយ

ទីមួយ) បំពាក់បំប៉ន ខាងនយោបាយសតិអារម្មណ៍

ទីពីរ) តែដើរតួសំខាន់ ត្រូវដោះស្រាយខាងចាត់តាំង ពីព្រោះខាងនយោបាយ សតិអារម្មណ៍យល់អស់ហើយ បំពាក់បំប៉នអស់ហើយ ។ បញ្ហាដែលចោទគឺ នរណាអ្នកអនុវត្តការកសាងសង្គមនិយម ។ បើអ្នកល្អ គេអនុវត្តល្អ ។ ដូច្នេះត្រូវតស៊ូកម្ចាត់រដ្ឋអំណាចខ្មាំង រៀបចំរដ្ឋអំណាចថ្មី ។ បក្ខជនក៏ដោយ មិនបក្ខជនក៏ដោយ កម្មាភិបាលចាស់ក៏ដោយ កម្មាភិបាលថ្មីក៏ដោយ ឲ្យតែស្មោះត្រង់គេធ្វើបាន ។ ដូច្នេះ សហករណ៍ក្តី មុខព្រួញមួយៗក្តី ស្រុកក្តី ត្រូវយកចិត្តទុកដាក់ជាបន្តបន្ទាប់ ។ ផែនការ៣តោនកន្លះ និង៧តោនក្នុងឆ្នាំ១៩៧៨នេះ សម្រេចបានឬមិនបាននៅលើបញ្ហាចាត់តាំងហើយបញ្ហាចោទ មិនមែនមហាជនជាសំខាន់ទេ គឺបញ្ហាស្នូលដឹកនាំ ។ បើភាគ គឺគណៈភាគ បើស្រុកគឺគណៈស្រុក បើសហករណ៍គឺគណៈសហករណ៍ និងស្នូលដឹកនាំតាមមុខព្រួញផ្សេងៗ ។ ត្រូវដោះស្រាយបញ្ហាចាត់តាំងជាបន្តបន្ទាប់ ហើយកែលម្អការចាត់តាំងជាបន្តបន្ទាប់ ។ បើដោះស្រាយបញ្ហានេះបាន កសាងសង្គមនិយមខ្លាំងហើយ ។ អត់ចោទបញ្ហាប្រជាជនថ្មី ប្រជាជនចាស់ទេ ។

តើមានកម្មាភិបាលទេ បើផ្លាស់ដូច្នេះ ។ ពីឆ្នាំ១៩៧៦ រហូតមកដល់ឥឡូវផ្លាស់មិនតិចទេ ។ តែយើងកាន់កាប់បាន ហើយខ្លាំងជាងមុនទៀត ពីព្រោះកត្តាកំណត់ មិនមែនកត្តាជាឈ្មោះចាស់ថ្មីទេ ។ កត្តាកំណត់គឺ តើអ្នកនោះស្មោះត្រង់ និងមាគ៌ាឬមិនស្មោះត្រង់ ។

### ៥) ពិនិត្យអំពីសភាពការណ៍ ជីវភាពប្រជាជន

ចំពោះបញ្ហាជីវភាពប្រជាជន តាមពិសោធន៍ឆមាសទី១ ឆ្នាំ១៩៧៨ ក៏ប្រហាក់ប្រហែលនិងបញ្ហាដទៃទៀតដែរ ។

**ជាគុណសម្បត្តិ ៈ**

កន្លែងមួយចំនួនច្រើន គេដោះស្រាយបានៈ សម្លៀកបំពាក់ក៏គ្រប់គ្រាន់ ជម្រកកត់មត់ សុខភាព អនាម័យក៏ល្អជាងមុនច្រើន រៀនសូត្រមានការចាត់តាំងហ្មត់ចត់ ។ ស្បៀងអាហារ ចំណីចំណុកគ្រប់គ្រាន់ ។ កន្លែងដែលចម្រើននេះ គេមានទុនច្រើនធានាដល់ការដោះស្រាយជីវភាពប្រជាជនបានពេញទី ។ ដូច្នេះគេម្ចាស់ការបាន ។ ហើយម្ចាស់ការនេះមិនមែនម្ចាស់ការដោយចៃដន្យទេ ។ គេមានមូលដ្ឋានរបស់គេ ។

**គុណវិបត្តិ ៈ**

ផលឆ្នាំ១៩៧៧នេះ យើងយកមកបម្រើជីវភាពប្រជាជនមិនបាន១០០ភាគរយទេ ។ តាមទំហំផលត្រូវសម្រេចបាន១០០ភាគរយ ។ តែខ្វះស្បៀងអាហារ ខ្វះថ្នាំសង្កូវ ខ្វះសម្លៀកបំពាក់ ។ ខ្វះនេះមិនមែនមកពីចលនាប្រជាជនទេ ។ ខ្វះដោយសមាសភាពក្បត់វាបំផ្លាញ ។ នេះជាគុណវិបត្តិរបស់យើងធំខាងដោះស្រាយជីវភាពប្រជាជន ។

### តើត្រូវដោះស្រាយយ៉ាងម៉េច?

មានតែរំលំរដ្ឋអំណាចក្បត់ដែលវាបង្កប់ស៊ីរូងផ្ទៃក្នុង ហើយចាត់តាំងរដ្ឋអំណាចថ្មីស្មោះត្រង់របស់បក្ស ។ កន្លែងណាដែលយើងដោះស្រាយបានយ៉ាងនេះ យើងដោះស្រាយជីវភាពប្រជាជនបាន ។ ដោះស្រាយទី១ ដោយយកស្រូវដែលខ្មាំងលាក់ ។ ដោះស្រាយទី២ ដោយយកពីកន្លែងជិតខាងមកជួយ ។ យើងដោះស្រាយបានទាំងអង្ករ ទាំងពោត ទាំងដំឡូង ។ ជាពន្លឺក្នុងការដោះស្រាយជីវភាពប្រជាជន គឺភ្លឺស្វាង ៈ យើងមានលក្ខណៈសម្បត្តិដោះស្រាយ ជីវភាពប្រជាជនបានច្រើនណាស់ ។ យើងមានមូលដ្ឋានសង្គមដើម្បីដោះស្រាយបានល្អ ។ បញ្ហានេះ ចាប់ពីនេះទៅ កន្លែងណាជាភាគ ជាតំបន់ ជាស្រុក ជាសហករណ៍ បើអត់បាយមួយឆ្នាំត្រូវផ្លាស់ ។ ដើម្បីឲ្យអ្នកល្អ អ្នកខ្លាំងគេទៅដោះស្រាយ ។

### ៦) បញ្ហាកសាងកម្លាំងដឹកនាំរបស់បក្ស ទាំងកម្មាភិបាលក្នុងបក្ស ទាំងកម្មាភិបាលក្រៅបក្ស

**គុណសម្បត្តិមានច្រើន**

វគ្គទី១) យើងបានផ្លាស់ប្តូរកម្មាភិបាលថ្នាក់ភាគ ថ្នាក់ស្រុក ថ្នាក់សហករណ៍បានមួយកម្រិត ។ តែវានៅទៀត ។

វគ្គទី២) យើងបានវាយរំលំកម្មាភិបាល ដែលវាក្បត់ស៊ីរូងផ្ទៃក្នុង តាមភាគ តាមតំបន់ តាមក្រសួង តាមមន្ទីរ បានទាំងផ្ទាំងៗទៀត ។ ឃើញថាសភាពធូរស្រាល ។ មិនមានអ្វីស្មុគស្មាញច្រើនទេ ។ ពីមុនស្មុគស្មាញ១០ ឥឡូវស្មុគស្មាញតែ១ តែ២ ហើយគេដោះស្រាយជាបន្តបន្ទាប់បាន ។

តើជ្រើសរើសអ្នកថ្មីមានពិសោធន៍យ៉ាងម៉េច? យកពីណាមក? យកអ្នកល្អក្នុងមហាជន ក្នុងបក្ស ក្នុងកងទ័ពជាអ្នកចាស់ក្តី ជាអ្នកថ្មីក្តី ។ អ្នកថ្មីនេះខ្លាំងជាងអ្នកចាស់ទៀត ខ្លាំងក្នុងឋានៈជាអ្នកស្អាត ។ ជុយទៅវិញយើងបានកម្មាភិបាលថ្មី ខ្លាំងជាងពីមុនឆ្ងាយណាស់ ។ កម្មាភិបាលនេះមកសាកល្បងក្នុងការប្រយុទ្ធវាយខ្មាំងដោះស្រាយជីវភាពប្រជាជន ដឹកនាំបង្កបង្កើនផល ។ គេប្រយុទ្ធបាន ។

គុណវិបត្តិ ៈ យើងដោះស្រាយពួកក្បត់ មិនបានទាំងអស់ភ្លាម ។ យើងដោះស្រាយបានជាបន្តបន្ទាប់ វាមានឱកាសបង្កប់បានយូរ ។

មូលហេតុត្រូវពន្យារពេល ៈ

◆ ពិនិត្យឯកសារ ថ្លឹងថ្លែងហ្មត់ចត់ឯកសារផង វិភាគផង និងរកទិសដោះស្រាយឲ្យត្រឹមត្រូវ ពីព្រោះដោះស្រាយកម្មាភិបាលមួយៗ មិនប៉ះតែមួយនាក់ទេ គឺប៉ះពាល់មួយខ្សែ ។ ខ្សែតូច ខ្សែធំតែមួយខ្សែ ។

◆ មូលហេតុទី២ ប្រវត្តិកម្មាភិបាលមួយៗ យើងក្តាប់មិនបានច្បាស់ ។ មួយផ្នែកណាយើងក្តាប់បាន មួយផ្នែកទៀតយើងក្តាប់មិនបាន ។ ដូច្នេះ បានជាយើងមិនហ៊ានវិនិច្ឆ័យ ដោយមិនបានទូទាត់ច្បាស់លាស់ ។ យើងត្រូវការទូទាត់ច្បាស់លាស់ ជាសមូហភាព ។

តែទោះជាយ៉ាងនេះក៏ដោយ ក៏ទុកជាការខ្វះខាត ។ តាម

ពិសោធន៍នេះ យើងត្រូវឲ្យប្រញាប់ប្រញាល់ដាងនេះ ។ ប្រញាប់ប្រញាល់ក្តាប់ប្រវត្តិរូបកម្មាភិបាល ។ យើងត្រូវចុះទៅស្ទាបស្ទង់ត្រង់គ្រាប់ប្រមូលមតិមហាជន ដើម្បីក្តាប់ប្រវត្តិរូបកម្មាភិបាល ។ ទី២ គឺយកភេទជាក់ស្តែងក្នុងចលនាមកពិនិត្យ អនុវត្ត "ឆ្មេង" ឲ្យខ្មោចក៏ត្រូវពិនិត្យ ស្តាំក៏ត្រូវពិនិត្យ ។ ប្រព្រឹត្តិអំពើផ្សេងៗទៀតក៏ត្រូវពិនិត្យ ។ យកការជាក់ស្តែងទាំងអស់នេះមកពិនិត្យ ជាខ្លឹមសារនៃប្រវត្តិដែរ ។ នាំឲ្យយើងវិនិច្ឆ័យបានរហ័សជាងកន្លងមក ។ កុំឲ្យវាយឺត ។ បើយឺតវាខាត ។ ខាតដល់កិច្ចការការពារប្រទេស ខាតដល់កិច្ចការបដិវត្តន៍សង្គមនិយម ដល់កិច្ចការកសាងសង្គមនិយម ដល់ជីវភាពប្រជាជន ។ ឥឡូវនេះ ប្រជាជនក៏ជ្រួតជ្រាបមាគ៌ា មហាជនក្នុងបក្សក៏ជ្រួតជ្រាបមាគ៌ា កងទ័ពក៏ជ្រួតជ្រាបមាគ៌ា ខុសឬត្រូវគេឃើញ បដិវត្តន៍ឬមិនបដិវត្តន៍គេឃើញ ។ យុទ្ធជន-យុទ្ធនារី យើងត្រូវសាកសួរគេពីកម្មាភិបាល ។ អ្នកល្អក៏មហាជនគេវិនិច្ឆ័យ អ្នកមិនល្អក៏មហាជនគេវិនិច្ឆ័យ ។

ដូច្នេះ យើងជាកម្មាភិបាលរបស់បក្ស ត្រូវរក្សាភាពជាលក្ខណៈមហាជនគេហ៊ានប្រាប់យើង កុំឲ្យមហាជនគេខ្លាច ។ ធ្វើឲ្យមហាជនកាន់តែមានកម្លាំងចិត្តកម្លាំងកាយមកតស៊ូកសាងកម្មាភិបាលល្អ ហើយកម្ចាត់កម្មាភិបាលមិនល្អ ។

### ៧) ឋានៈអន្តរជាតិរបស់បដិវត្តន៍កម្ពុជាបច្ចុប្បន្ន

តើការវិវត្តនៃឋានៈអន្តរជាតិរបស់បដិវត្តន៍កម្ពុជាលើឆាកអន្តរជាតិ វិវត្តថយក្រោយ ឬកើនចម្រើនទៅមុខទៀត? ទី១) ឋានៈបដិវត្តន៍យើងអត់ថយក្រោយទេ ។ ពិតមែនតែចក្រពត្តិអាមេរិក និងពួកប្រតិកិរិយា វាចំកោងដេរយើងយ៉ាងម៉េចក៏ដោយ ។ ទូទាត់ពួកប្រឆាំងនិងពួកឧបត្ថម្ភកាន់តែច្រើនឡើង ពួកស្អាក់ស្ទើរកាន់តែថយចុះ ។

ពិសេសក្នុង៦ខែ កន្លងទៅនេះ ឋានៈអន្តរជាតិនៃបដិវត្តន៍យើងមានលក្ខណៈលោតផ្លោះ ។ មូលហេតុមានដូចតទៅ ៈ

◆ មូលហេតុទី១ គឺល្បីល្បាញក្នុងសកលលោក កម្ពុជាលក់អន្តរក្នុងសភាពដែលយួនអត់បាយ និងប្រទេសខ្លះទៀតអត់បាយ យើងកសាងបានដោយខ្លួនយើង ដោយឯករាជ្យ ម្ចាស់ការ ដោះស្រាយជីវភាពប្រជាជនបាន ។

◆ មូលហេតុទី២ មកពីយើងការពារប្រទេសបាន ។ ការពារប្រទេសបាននេះ គឺឥទ្ធិពលសម្បើមណាស់ ។ ឈ្នះអាមេរិកក៏ជាឥទ្ធិពលមួយធំ តាំងពី៧៥ រហូតដល់ឥឡូវ ។ ប៉ុន្តែកម្ចាត់ការឈ្លានពានរបស់យួន ហើយវាយវា ធ្វើឲ្យវាលំបាក គឺឥទ្ធិពលសម្បើមណាស់ ។ យើងជ្រោងទង់ឯករាជ្យ ជ្រោងទង់អធិបតេយ្យភាពលើសកលលោក មិនឲ្យខ្មាំងយួនវាមកឈ្លានពានបានតាមចិត្តទេ ។ បញ្ជាក់ឃើញសភាពអង់អាចក្លាហានរបស់យើង ហើយយើងប្រយុទ្ធបាន ។ សកលលោកឃើញថា យើងឯករាជ្យពិតប្រាកដ ហើយការពារឯករាជ្យបាន ។ ដូច្នេះគេត្រូវការមិត្តភាពយើងណាស់ ។ មានការអី គេត្រូវការសំឡេងយើងណាស់ ពីព្រោះជាសំឡេងឯករាជ្យ ។ ឯយួនវាអស់ឯករាជ្យហើយ សំដីរបស់វាជាសំឡេងរបស់សូវៀត ។ បក្ស ម៉ាក្ស ឡេនីន នៅអាមេរិក ទាំងខាងជើង ទាំងខាងត្បូង នៅស្រុកបារាំង អ៊ីតាលី គេការពារយើង ។ ម្យ៉ាងគេឈរខាងបដិវត្តន៍ ។ ម្យ៉ាងទៀតគេរំភើប គេពេញចិត្តនឹងបដិវត្តន៍យើង ។ អង្គការមហាជននៅប្រទេសផ្សេងៗក្នុងសកលលោក គេការពារយើង ។ ប្រទេសមិនចូលបក្សសម្ព័ន្ធភាគច្រើនគេឧបត្ថម្ភយើងជាគោលជំហរ ។ រដ្ឋថៃ រដ្ឋផ្សេងៗ នៅអាស៊ីអាគ្នេយ៍ ទោះជាមិនឧបត្ថម្ភយើង តែអបអរដោយឃើញយើងការពារខ្លួនបាន ។ ការដែលជប៉ុនអញ្ជើញយើង គឺមកពីយើងមានអត្តភាពរបស់យើង ។

ទិដ្ឋភាពទាំង៧នេះ បង្ហាញច្បាស់នូវចលនាបដិវត្តន៍ យើងក្នុងរយៈពេល៦ខែនេះ ទាំងគុណសម្បត្តិ ទាំងគុណវិបត្តិ នៅក្នុងនេះបញ្ហាជាគន្លឹះ ដើរតួជាងគេ គឺបញ្ហាចាត់តាំង កម្ចាត់រដ្ឋអំណាចក្បត់បង្កប់ស៊ីរូងរដ្ឋអំណាចរបស់យើង ហើយរៀបចំរដ្ឋអំណាចថ្មីរបស់បក្ស របស់បដិវត្តន៍យើង បញ្ហានេះដើរតួជាគន្លឹះជាងគេ ពីព្រោះបើដោះស្រាយបានត្រឹមត្រូវ វាជះឥទ្ធិពលល្អដល់ភារកិច្ចផ្សេងទៀត ទាំងកិច្ចការពារ ទាំងកិច្ចការបដិវត្តន៍សង្គមនិយម កសាងសង្គមនិយម ជីវភាពប្រជាជន ។ បញ្ហានេះវានាំឲ្យពង្រឹងជំហរតស៊ូវណ្ណៈរបស់យើងថែមទៀត ។ ពីមុនយើងវាយស្មើភារកិច្ចទាំង៧នេះ ។ ឥឡូវយើងឃើញថា បញ្ហាចាត់តាំងកម្ចាត់រដ្ឋអំណាចក្បត់ដែលវាបង្កប់ស៊ីរូងរដ្ឋអំណាចយើង ហើយចាត់តាំងរដ្ឋអំណាចថ្មីរបស់បក្ស វាដើរតួជាគន្លឹះគ្របដណ្តប់ជាងគេ ។

**ឆេង ម៉េងងង**

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជា ផល្លា តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល *truthphalla.c@dccam.org* ។





















# គេហទំព័រទស្សនាវដ្ដីស្វែងរកការពិតជាភាសាខ្មែរ

## www.truthcambodia.com

*ទស្សនាវដ្ដីស្វែងរកការពិត បង្កើតគេហទំព័រ* www.truthcambodia.com *ក្នុងគោលបំណងផ្សព្វផ្សាយ និងអប់រំឲ្យបានកាន់តែទូលំទូលាយអំពីរបបកម្ពុជាប្រជាធិបតេយ្យ (របបខ្មែរក្រហម) ដើម្បីសម្រេចឲ្យបាននូវការចងចាំ យុត្តិធម៌ និងការផ្សះផ្សាជាតិក្នុងសង្គមដែលទទួលរងនូវការបែកបាក់ និង សង្គ្រាមជាច្រើនទសវត្សរ៍ ។*

*គេហទំព័រ* www.truthcambodia.com *ក៏នឹងដើរតួនាទីដ៏សំខាន់ផងដែរក្នុងការចែករំលែកព័ត៌មានអំពីដំណើរការសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមជាមួយសាធារណជន និងជួយសាលាក្ដីក្នុងការរំលែកព័ត៌មានទាក់ទងប្រវត្តិសាស្ត្រខ្មែរក្រហម នៅខណៈពេលអត្ថបទមួយចំនួននៅក្នុងគេហទំព័រនេះត្រូវបានយកទៅប្រើប្រាស់ជាភ័ស្តុតាងដើម្បីដាក់បន្ទុកមេដឹកនាំខ្មែរក្រហម ។*

*គេហទំព័រ* www.truthcambodia.com *បែងចែកជា៥ផ្នែកសំខាន់ គឺ១) ផ្នែកឯកសារ ២) ផ្នែកប្រវត្តិសាស្ត្រ ៣) ផ្នែកច្បាប់ ៤) ផ្នែកវេទិកាពិភាក្សាជាសាធារណៈ និង ៥) ផ្នែកស្រាវជ្រាវស្វែងរកក្រុមគ្រួសារដែលបានស្លាប់ ឬបាត់ខ្លួនក្នុងរបបខ្មែរក្រហម ។ នៅក្នុងគេទំព័រ* www.truthcambodia.com *ក៏មានផ្ទុកនូវឯកសារជាវីដេអូ, សំឡេង, រូបថត និងឯកសារដើមរបស់ខ្មែរក្រហមដែរ ។*

*អត្ថបទសម្រាប់ផ្នែកទី១) នឹងរៀបរៀងឡើង ដោយស្មេរមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយផ្អែកលើឯកសារដើមទាំងស្រុង ។ សរសេរឲ្យស្រួលអាន គឺការសង្ខេបចេញពីឯកសារដើមមកជាអត្ថបទ ។ គោលបំណងនៃផ្នែកនេះ គឺចង់ជម្រាបជូនសាធារណជនថា តើមានឯកសារអ្វីខ្លះដែលតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ផ្នែកទី២) គឺជាអត្ថបទវិភាគលើប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម ។ អត្ថបទផ្នែកនេះគឺជាអត្ថបទចូលរួមមកពីអ្នកជំនាញជាន់ខ្ពស់លើប្រវត្តិសាស្ត្រខ្មែរក្រហម ហើយមានទិសដៅសម្រិតសម្រាំងប្រវត្តិសាស្ត្រនេះឲ្យមានភាពកាន់តែសុក្រឹតទ្រឡើងទៀត ។ ផ្នែកទី៣) គឺជាផ្នែកច្បាប់ដែលធ្វើការវិភាគដោយមេធាវី ឬចៅក្រម ឬអ្នកជំនាញការច្បាប់អន្តរជាតិ ។ ការវិភាគនេះនឹងជួយជាគំនិតលើផ្នែកច្បាប់ថា តើឧក្រិដ្ឋកម្មអ្វីខ្លះដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ហើយថា តើឧក្រិដ្ឋកម្មនីមួយៗត្រូវតែដោះស្រាយតាមនីតិវិធីបែបណា ដើម្បីរកឲ្យបាននូវយុត្តិធម៌ពិតប្រាកដមួយដល់ជនរងគ្រោះ ។ ផ្នែកទី៤) គឺជាវេទិកាពិភាក្សា និង ផ្ដល់គំនិតនានាលើបញ្ហាខ្មែរក្រហម ។ អត្ថបទទីនេះ គឺជាវិភាគទានចូលរួមពីសំណាក់អង្គការក្រៅរដ្ឋាភិបាលនានា សមាជិករាជរដ្ឋាភិបាល គ្រូ សិស្ស និស្សិត ជាដើម ។ល ។ ផ្នែកទី៥) គឺជាទំព័រស្រាវជ្រាវស្វែងរកក្រុមគ្រួសារដែលបានស្លាប់ ឬ បាត់ខ្លួនក្នុងរបបខ្មែរក្រហម ឬការសាកសួររកព័ត៌មានអំពីមិត្តភក្តិ សាច់សារលោហិតដែលបានស្លាប់ដោយសាររបបខ្មែរក្រហម ។ ជាទំព័រឈឺចាប់ អាណោចអាធ័ម ប៉ុន្តែក៏ជាទំព័ររម្ងាប់ការមន្ទិលសង្ស័យដើម្បីសេចក្ដីសុខក្នុងខ្លួនជាអមតៈ ។*

*សរុបសេចក្ដីទៅផ្នែកទាំង៥ ខាងលើនៃគេហទំព័រ* www.truthcambodia.com *នឹងបើកចំហជូនដល់ការចូលរួមស្វែងរកការពិតពីសាធារណជនគ្រប់ស្រទាប់ ជាន់ថ្នាក់ ដោយមិនប្រកាន់ពណ៌សម្បុរ ភេទ អាយុ ឬនិន្នាការនយោបាយណាមួយឡើយ ។ គេហទំព័រ* www.truthcambodia.com *នឹងបម្រើដល់សាធារណជន និងដើម្បីជួយជ្រោមជ្រែងស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាគ្រប់រូប ។ គ្រប់លិខិត ឬអត្ថបទ ដែលផ្ញើមកកាន់គេហទំព័រ* www.truthcambodia.com *សូមដាក់ឈ្មោះ មុខងារ អាសយដ្ឋាន និងលេខទូរសព្ទសម្រាប់ធ្វើសេចក្ដីបញ្ជាក់លើខ្លឹមសារនៃលិខិត ឬអត្ថបទមុនការចេញផ្សាយ ។*

*គេហទំព័រ* www.truthcambodia.com *សូមរក្សាសិទ្ធិក្នុងការកែលម្អពាក្យពេចន៍នៃលិខិតទាំងឡាយ ក្នុងន័យថែរក្សានូវអត្ថន័យដើមទាំងស្រុង ។ ប៉ុន្តែ គេទំព័រ* www.truthcambodia.com *នឹងចុះផ្សាយទាំងស្រុងចំពោះអត្ថបទចូលរួមទាំងឡាយ ។*

# វីរភាពស្ត្រីកម្ពុជា ៖ ក្ដីសង្ឃឹម

ខ្ញុំសូមថ្លែងអំណរគុណចំពោះ ការបង្កើតគោលនយោបាយថ្នាក់ជាតិសម្រាប់ស្ត្រី របស់សម្ដេចតេជោ នាយករដ្ឋមន្ត្រីហ៊ុន សែន ដែលសម្ដេចបានថ្លែងសុន្ទរកថាស្ដីពីសមភាពយេនឌ័រ និងការលើកកម្ពស់សិទ្ធិស្ត្រី នៅក្នុងកិច្ចប្រជុំ កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៥ កន្លងទៅនេះនៅក្នុងកិច្ចប្រជុំកំពូល "ប្រមុខដឹកនាំពិភពលោក ស្ដីពីសមភាពយេនឌ័រ និងការលើកកម្ពស់ស្ត្រី ការប្ដេជ្ញាចិត្តឆ្ពោះទៅរកវិធានការ" នៅទីស្នាក់ការធំរបស់អង្គការសហប្រជាជាតិ នៅបុរីញូវយ៉ក សហរដ្ឋអាមេរិក ដើម្បីលើកកម្ពស់សមភាពស្ត្រី ទាំងក្នុងសេដ្ឋកិច្ច និងសង្គម សិទ្ធិអំណាចស្ត្រី តាមរយៈផែនការសកម្មភាពផ្សេងៗក្រោយឆ្នាំ២០១៥ ។ ខ្លឹមសារនៃកំណត់គោលនយោបាយនេះ បានផ្ដល់ក្ដីសង្ឃឹម និងមូលដ្ឋានដ៏រឹងមាំ ដល់ស្ត្រីកម្ពុជាក្នុងការអភិវឌ្ឍសង្គមជាតិទាំងមូល ។ ស្ត្រី គឺកម្លាំងចលករយ៉ាងសំខាន់ក្នុងការកសាងសង្គមកម្ពុជាក្រោយពីរបបខ្មែរក្រហម ។


រូបចម្លាក់ "វីរភាពស្ត្រីកម្ពុជា ៖ ក្ដីសង្ឃឹម"

ខ្មែរក្រហមបានធ្វើឲ្យស្ត្រី និងកុមារជាងពីរសែននាក់រស់នៅដោយគ្មានស្វាមី និងឪពុក ។ តួលេខអ្នកដែលរស់រានមានជីវិតពីរបបខ្មែរក្រហម ចំនួនប្រមាណ៧០ភាគរយ គឺជាស្ត្រី ។ ស្ត្រីទាំងអស់ដែលរស់រានពីរបបខ្មែរក្រហម បានឆ្លងកាត់ឧបសគ្គជាច្រើន ដើម្បីការពារអ្នកទីស្រលាញ់របស់ខ្លួន និងអភិវឌ្ឍប្រទេសជាតិ ។

ក្នុងទសវត្សរ៍ឆ្នាំ១៩៨០ និងទសវត្សរ៍ឆ្នាំ១៩៩០ នៅពេលដែលកម្ពុជាស្ថិតក្នុងភាពលំបាកផ្នែកនយោបាយ និងសង្គ្រាមស៊ីវិល ស្ត្រី គឺជាអ្នកជួយទ្រទ្រង់ដល់សេដ្ឋកិច្ចប្រទេស កសាងរចនាសម្ព័ន្ធសង្គម រួមមាន វប្បធម៌ ការអប់រំ ប្រពៃណីទំនៀមទម្លាប់ ដែលត្រូវបំផ្លាញទាំងស្រុងដោយខ្មែរក្រហម ។ នៅក្នុងកាលៈទេសៈដ៏ស្មុគស្មាញនៃសង្គមក្រោយជម្លោះនាពេលនោះ ស្ត្រីកម្ពុជាបានបង្ហាញពីភាពរឹងមាំ ដែលមិនទ្រុឌទ្រោមដោយសាររបបប្រល័យពូជសាសន៍ខ្មែរក្រហម ។

ដើម្បីជាការតបស្នងគុណ និងការរំឭកដល់វីរភាពស្ត្រីកម្ពុជា និងជានិមិត្តរូបចំពោះការតស៊ូរបស់ស្ត្រីកម្ពុជាក្នុងការស្ដារ និងកសាងប្រទេសឡើងវិញ រូបសំណាកស្ត្រីដែលជាម្ដាយគួរតែត្រូវបានកសាងឡើង ។ ដើម្បីបង្ហាញពីវីរភាពស្ត្រីដែលតស៊ូនឹងរបបប្រល័យពូជសាសន៍ និងពោរពេញទៅដោយក្ដីសង្ឃឹម តើសិល្បករជាងចម្លាក់នឹងត្រូវបកស្រាយគោលគំនិតទៅក្នុងសិល្បៈដោយរបៀបណា? តើសិល្បករនឹងត្រូវសូនរូបបដិមាយ៉ាងណាដើម្បីឆ្លើយតបទៅនឹងរសជាតិសិល្បៈនៃសតវត្សរ៍ទី២១ ក្នុងសម័យសាកលភាវូនីយកម្មនេះ? រឿងរ៉ាវដែលបានកើតឡើងក្នុងសម័យខ្មែរក្រហម គឺជាបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាអំពើប្រល័យពូជសាសន៍ក៏ដូចជារឿងរ៉ាវរបស់ពិភពលោកដែរ ។ រឿងរ៉ាវស្ត្រីនៅកម្ពុជា គឺជារឿងរ៉ាវពិភពលោក ។ តើសិល្បករគួរបង្ហាញរូបបដិមាក្នុងទម្រង់បែបណាសម្រាប់មនុស្សគ្រប់គ្នាលើពិភពលោកដែលអាចយល់បាន? តើនរណាជាសិល្បករគួរសាងសង់រូបបដិមានេះ? សំណួរទាំងអស់នេះបានបង្កើតឲ្យមានលក្ខ

ខណ្ឌមួយចំនួនដល់សិល្បករដើម្បីសាងសង់រូបបដិមា វីរភាពស្ត្រីកម្ពុជា ៖ ក្ដីសង្ឃឹម ។

លោកឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកវិទ្យាស្ថានអចិន្ត្រៃយ៍ ស្លឹករឹត បានចាប់ផ្ដើមសរសេរទស្សនៈគាំទ្រគំនិតនេះ ក្នុងឆ្នាំ២០០៨ និងបានផ្សព្វផ្សាយជារៀងរាល់ឆ្នាំនៅក្នុងទិវាសិទ្ធិនារី ថ្ងៃទី៨ ខែមីនា តាមរយៈព័ត៌មានបណ្ដាញសង្គម និងសាធារណមតិក្នុងស្រុក ។ លោកបានធ្វើការងារជាមួយដៃគូ ស្ថាប័នពាក់ព័ន្ធជាច្រើន ដើម្បីធ្វើយ៉ាងណាជំរុញឲ្យមានការពិភាក្សាជាសាធារណៈ និងកសាងបដិមា វីរស្ត្រីកម្ពុជា ៖ ក្ដីសង្ឃឹមនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជា បន្តជំរុញគំនិតកសាងបដិមាមួយដើម្បីឧទ្ទិសដល់វីរភាព និងការតស៊ូរបស់ស្ត្រីដែលបានរស់រានមានជីវិតពីរបបខ្មែរក្រហម ។ តាមទស្សនៈលោក ឆាំង យុ បដិមានេះគឺជារូបម្ដាយប្រឹងទាញដៃកូនឡើង ដែលបានបង្ហាញពីសេចក្ដីសង្ឃឹមរបស់ស្ត្រីដែលជួយយឹតយោងកូនឲ្យរួចផុតពីក្ដីលំបាក ។

មានវិចិត្រករខ្មែរមួយចំនួន បានព្រាងបដិមាស្ត្រីទៅតាមការបកស្រាយរបស់ខ្លួនចេញពីគោលគំនិតរបស់លោក ឆាំង យុ ប៉ុន្តែមិនទាន់ត្រូវបានស្ថាបនាចេញជារូបចម្លាក់ ។ ដោយសារសម្ពាធសាកលភាវូបនីយកម្ម វិចិត្រករមួយចំនួនបានប្ដូរគំនិតពីការគូរគំនូរបែបបុរាណ មកជាគំនូរសហសម័យ ដែលជាសិល្បៈថ្មីនិងអរូបមួយសម្រាប់ប្រជាជនកម្ពុជាវិញ ។

ថ្មីៗនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា បានទទួលរូបបដិមាអំពីស្ត្រី បែបសហសម័យពីវិចិត្រករ អាយ នីយូមែន នូត្រា ដែលបានពិភាក្សារូបបដិមានេះជាមួយនឹងលោក ឆាំង យុ ដែលស្ទូនចេញពីទស្សនៈលើស្ត្រីដែលបានឆ្លងកាត់របប ប៉ុល ពត ហើយនឹងកសាងឡើងជាបដិមាមួយសម្រាប់ជាអំណោយដល់វិទ្យាស្ថានស្លឹករឹត ។ រូបចម្លាក់នេះបានបង្ហាញស្នាដៃថ្មី ហើយក៏បានបង្ហាញឲ្យនិស្សិតនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈផ្នែកស្ទូនរូបដើម្បីធ្វើការធ្វើការពិភាក្សា និងលើកទឹកចិត្តឲ្យនិស្សិតទាំងនេះ មានកម្លាំងចិត្ត និងមានសង្ឃឹមក្នុងការធ្វើចម្លាក់បែបនេះឲ្យមានជារូបក្នុងទម្រង់ផ្សេងទៀតសម្រាប់តំណាងរូបស្ត្រីនៅប្រទេសកម្ពុជា ។

ស្របគ្នានេះក៏មានមតិមួយចំនួនបានលើកឡើងចំពោះរូបចម្លាក់ស្ត្រីដែលបានប្រគល់មកឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាដែរ ដូចជាលោក ៖

◆ ប្រាយអែន ខែល ជាស្ថាបត្យករ នៅប្រទេសអង់គ្លេស បាននិយាយថា រូបចម្លាក់នេះ ក្រឡេកមើលទៅសុភាពរាបសារ ប៉ុន្តែមានឥទ្ធិពលខ្លាំងណាស់ ។

◆ ភីធើ សារ៉ក ៖ ជាការពិត រូបចម្លាក់ ធ្វើឲ្យមានការចាប់ខ្លាំងណាស់ ។

◆ ជែម ប្លេក ៖ បាទជាការពិត ។ មានរឿងរ៉ាវជាច្រើនដែលយើងអាចមើលឃើញនៅក្នុងរូបចម្លាក់នេះ ។ អមជាមួយនឹងភាពរឹករាវ ភាពមិនប្រាកដប្រជា និងការភ័ន្តច្រឡំ នាំឲ្យមានរូបម្ដាយដែលរំពឹងចំពោះអនាគត និងពេលវេលាដ៏ប្រសើរជាងនេះ ។ ខ្ញុំអាចមើលឃើញមិនត្រឹមតែពីសេចក្ដីស្រឡាញ់របស់ម្ដាយចំពោះកូនតែប៉ុណ្ណោះទេ ប៉ុន្តែខ្ញុំក៏អាចមើលឃើញនូវការបង្ហាញសេចក្ដីស្រឡាញ់របស់មនុស្សម្នាក់ និងសេចក្ដីស្រឡាញ់របស់ម្ដាយនិងកូនចំពោះអ្នកដទៃ ។ វាពិតជាពោរពេញដោយថាមពល ។ ខ្ញុំពេញចិត្តវាខ្លាំងណាស់ ។ សូមអរគុណចំពោះការផ្ញើរូបថតនេះមកខ្ញុំ ។ ខ្ញុំទន្ទឹងរង់ចាំមើលនូវ “វីរភាពស្ត្រីកម្ពុជា ៖ ក្ដីសង្ឃឹម” លេចចេញជារូបរាង ។ ក្នុងពេលនេះ ខ្ញុំនឹងផ្ដិតចេញជារូប ហើយដាក់តាំងនៅលើតុការងាររបស់ខ្ញុំ ។ ខ្ញុំនឹងមើលវានៅរាល់ពេលដែលខ្ញុំអង្គុយនៅខាងមុខកុំព្យូទ័រ ។ អតីតនាយកសាកលវិទ្យាល័យរបស់យើង បណ្ឌិត រ៉ូណល ហ្សាការី ដែលលោក បណ្ឌិត បូហ្គាត និងខ្ញុំធ្វើការជាមួយ ក៏ជាអ្នកស្ទូនរូបដែរ ។ បើទោះបីគាត់ចូលនិវត្តន៍ក្ដី ក៏គាត់នៅតែបន្តធ្វើកិច្ចការងារសិល្បៈ និងការងារទាក់ទងនឹងដែក ។ ខ្ញុំនឹងផ្ដិតរូបនេះជូនគាត់ ។ គាត់ក៏ពេញចិត្តចំពោះការងារនេះដែរ ។ តើវានឹងធ្វើឡើងដោយសមាសធាតុអ្វី? ជាទង់ដែង ឬឈើកិន?

មជ្ឈមណ្ឌលឯកសារកម្ពុជា មានបំណងឲ្យរូបបដិមានេះមានលក្ខណៈជាសាកល ហើយវាអាចតំណាងឲ្យស្ត្រីនៅក្នុងតំបន់និងប្រទេសលើសាកលលោកទាំងឡាយដែលឆ្លងកាត់សម័យកាលប្រវត្តិសាស្ត្រដ៏ជូរចត់ ហើយសាកសម និងស្របទៅនឹងគោលនយោបាយថ្នាក់ជាតិ ស្ដីពី សមភាពយេនឌ័រ ការលើកកម្ពស់ស្ត្រីនិងការប្ដេជ្ញាចិត្តឆ្ពោះទៅរកវិធានការ ។

**សោម ប៊ុនថន និង សេង គន្ធី**

# វត្ថុបុរាណស្ថិតក្នុងបញ្ជីដោះដូរទំនិញរវាងខ្មែរក្រហម និងប្រទេសថៃ



បន្ទាប់ពីទទួលបានជ័យជំនះ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក្រសួងការបរទេសរបបខ្មែរក្រហមបានចរចាជាមួយក្រសួងការបរទេសប្រទេសថៃដើម្បីបង្កើតជាគណៈទំនាក់ទំនងកម្ពុជា-ថៃ ប្រចាំនៅច្រកព្រំដែនអន្តរជាតិប៉ោយប៉ែតស្ថិតនៅក្នុងតំបន់៣នៃភូមិភាគពាយ័ព្យ ។ នៅដើមឆ្នាំ១៩៧៦ ភាគីទាំងពីរបានឯកភាពគ្នាបង្កើតជាផ្សារនៅប៉ោយប៉ែតជាប់នឹងព្រំដែនសម្រាប់ដោះដូរពាណិជ្ជកម្ម ។ ភាគីខាងខ្មែរក្រហមតំណាងក្រសួងពាណិជ្ជរដ្ឋបាននាំយកទំនិញមួយចំនួនដូចជាជ័រកៅស៊ូកក, បន្លែ, ត្រី, សាច់, កាហ្វេ, គ្រាប់ឈូក និង រូបបដិមាធ្វើអំពីសំរិទ្ធជាដើម ដើម្បីដោះដូរជាមួយភាគីថៃយកគ្រឿងយន្តធ្វើកសិកម្ម ដូចជា គ្រឿងម៉ាស៊ីន, គ្រឿងដែក និងគ្រឿងបន្លាស់ត្រាក់ទ័រ ជាដើម ។

លី ចាន់ថា មានឈ្មោះបដិវត្តន៍ ធឿន និងមានស្រុកកំណើតនៅស្រុកបារាយណ៍ ខេត្តកំពង់ធំ ហើយជាអតីតយុទ្ធនារីដែលត្រូវខ្មែរក្រហមបញ្ជូនឲ្យទៅលក់ដូរទំនិញនៅប៉ោយប៉ែតនៅឆ្នាំ១៩៧៦ ចាន់ថា រៀបរាប់ថាគាត់បានស្ម័គ្រចិត្តចូលបម្រើចលនាខ្មែរក្រហមតាមរយៈឈ្មោះ លី នៅឆ្នាំ១៩៧៤ ។ នៅពេលខ្មែរក្រហមវាយចូលទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ អង្គការបញ្ជូនគាត់ឲ្យមកធ្វើការនៅភ្នំពេញ ក្នុងក្រសួងពាណិជ្ជកម្មរដ្ឋ ។ ខណៈពេលនោះ គាត់និងយុទ្ធនារី ប្រហែលជា៣០ទៅ៤០នាក់ផ្សេងទៀតត្រូវបានអង្គការចាត់តាំងឲ្យដើរបោសសម្អាតផ្ទះសម្បែង និងប្រមូលយកអីវ៉ាន់ល្អៗមកដាក់ឃ្លាំងនៅមុំធនាគារជាតិនៃកម្ពុជា ។ ចាន់ថា បានឃើញទិដ្ឋភាពទីក្រុងភ្នំពេញនៅពេលនោះមានសភាពស្ងាត់ជ្រងំ ដោយមានផ្ទះតែគ្មានមនុស្សរស់នៅ ។ ផ្ទះភាគច្រើនត្រូវចាក់សោ ហើយក្រុមអ្នកដើរបោសសម្អាតនាំគ្នាវាយសោចោល ដើម្បីប្រមូលយកអីវ៉ាន់ដែលមាននៅក្នុងផ្ទះទាំងនោះ ។

នៅខែវិច្ឆិកា ឆ្នាំ១៩៧៦ ចាន់ថា ត្រូវបានអង្គភាពពាណិជ្ជកម្មរដ្ឋបញ្ជូនឲ្យមកធ្វើការងារលក់ដូរនៅប៉ោយប៉ែតជាប់នឹងព្រំដែនប្រទេសថៃ ។ ចាន់ថា បានឲ្យដឹងថា ខ្មែរក្រហមដឹកផលិតផលតាមរថភ្លើង ពីភ្នំពេញយកទៅលក់នៅផ្សារប៉ោយប៉ែតជាច្រើនតោនក្នុងមួយថ្ងៃៗ ។ ទំនិញទាំងនោះ រួមមាន ជ័រកៅស៊ូកក, កាហ្វេ, គ្រាប់ឈូក, សម្រង់, ត្រី, បន្លែ ជាដើម ។ ផ្សារនេះចាប់ផ្ដើមបើកលក់ឲ្យភ្ញៀវថៃចូលទិញទំនិញចាប់ពីម៉ោង៨ព្រឹក រហូតដល់ម៉ោង៥ល្ងាចទើបបិទទ្វារ ។ អង្គភាពរបស់ ចាន់ថា ក៏បានដោះដូរវត្ថុបុរាណជាមួយភាគីថៃ រួមមាន ៖ រូបបដិមាធ្វើអំពីសំរិទ្ធ ដូចជាព្រះអង្គតូច ព្រះអង្គធំ រហូតដល់មានរូបព្រះអង្គបញ្ឈរថែមទៀតផង ។

ចាន់ថា មិនចេះភាសាថៃ ឬភាសាបរទេសទេ រាល់ការទិញដូរទាំងអស់មានអ្នកបកប្រែដែលជាកម្មាភិបាលខ្មែរក្រហមនៅក្នុងក្រសួងពាណិជ្ជកម្មរដ្ឋ ។ ចាន់ថា បានត្រឹមជាអ្នកចាំមើលភ្ញៀវទិញនិងចាំថ្លឹងរបស់របរប៉ុណ្ណោះ ។ ភ្ញៀវមកទិញគ្មានសិទ្ធិដើរសេរីចេញពីបរិវេណលក់ដូរឡើយ ។ យោធាខ្មែរក្រហមបានកាន់កាំភ្លើងឈរចាំមើលភ្ញៀវ ។ ចំណែកយុវជន, យុវនារីដែលលក់ដូរនៅក្នុងផ្សារជាប់ព្រំដែនថៃ ក៏មិនអាចចូលទៅលេងក្នុងទឹកដីថៃបានដែរ ព្រោះអង្គការមានវិន័យតឹងតែងណាស់ សូម្បីតែនិយាយលេងជាមួយទាហានថៃដែលឈរយាមការពារព្រំដែននៅទីនោះក៏ត្រូវហាមឃាត់ដែរ ។ បើហ៊ានតែដើរទៅនិយាយលេង ហើយអង្គការដឹងប្រាកដជាយកទៅរៀនសូត្រមិនខាន ហើយនៅក្នុងសម័យខ្មែរក្រហមឲ្យតែអង្គការហៅយកទៅរៀនសូត្រពិបាកនឹងបានរួចខ្លួនវិញណាស់ ។

ចាន់ថា មិនដឹងថាអង្គការខ្មែរក្រហមដោះដូរទំនិញរបៀបយ៉ាងម៉េចទេ ប៉ុន្តែគ្រាន់តែបានដឹងថា នៅពេលថៅកែថៃ ឬក្រុមហ៊ុនរបស់ថៃមកដឹកទំនិញរបស់ខ្មែរក្រហមទៅ ថ្ងៃបន្ទាប់មកឃើញមានរថយន្តធំៗជាច្រើនគ្រឿងរបស់ថៅកែថៃបានដឹកគ្រឿងម៉ាស៊ីន ឬគ្រឿងដែក, ត្រាក់ទ័រ និងគ្រឿងបន្លាស់ត្រាក់ទ័រមកឲ្យខ្មែរក្រហមវិញ ។ ចាន់ថា មិនដែលឃើញភាគីថៃ និងភាគីខ្មែរក្រហមមានទំនាស់រឿងតម្លៃ និងទំនិញឡើយ ។

នៅពាក់កណ្តាលឆ្នាំ១៩៧៧ ចាន់ថា ត្រូវបានអង្គការបញ្ជូនឲ្យមកធ្វើការនៅក្នុងក្រសួងពាណិជ្ជកម្មរដ្ឋ នៅភ្នំពេញវិញ ។ ចាន់ថា ធ្វើការងារជាកម្មករលីសែង និងបកគរប្រេកបាវគ្រឹបរក្សាទុកសម្រាប់នាំចេញ ។ ផលិតផលទាំងអស់នោះភាគច្រើននាំទៅប្រទេសចិន ។ តារិទ្ធ ជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មរដ្ឋ ។ កម្មករនៅក្នុងក្រសួងមានរាប់រយនាក់ តែកម្មករទាំងនោះត្រូវបានផ្លាស់ប្តូរកន្លែងធ្វើការជាញឹកញាប់ ។ របបអាហារមានពីរពេលក្នុងមួយថ្ងៃ ជួនណាបានឆ្អែត ជួនណាមិនឆ្អែតទេ ក៏ប៉ុន្តែការងារមិនសូវពិបាកខ្លាំងទេ ។ ចាន់ថា ភ័យតែម្យ៉ាង គឺខ្លាចអង្គការហៅយកទៅរៀនសូត្រ ។

នៅឆ្នាំ១៩៧៨ ចាន់ថា ត្រូវបានអង្គការឲ្យធ្វើការនៅក្នុងក្រសួងពាណិជ្ជកម្មដដែល តែចាត់តាំងឲ្យមើលថែទាំកុមារតូចៗដែលឪពុកម្តាយទៅធ្វើការតាមផ្នែកផ្សេងៗក្នុងក្រសួង និងមានកុមារខ្លះជាក្មេងកំព្រា ។ ចាន់ថា មើលថែទាំក្មេងៗប្រហែលជា ៤០នាក់ ព្រឹកឡើងត្រូវឲ្យក្មេងៗហូបបបរ និងដឹកនាំធ្វើការងារបន្តិចបន្តួច ដូចជា ជម្រះស្មៅ និងធ្វើការងារស្រាលៗនៅមន្ទីរកុមារ ជិតទួលទំពូង ។

នៅឆ្នាំ១៩៧៩ នៅពេលកងទ័ពវៀតណាមវាយចូលដល់ប្រទេសកម្ពុជា ចាន់ថា និងកម្មាភិបាលខ្មែរក្រហមទាំងកុមារតូចៗមួយចំនួនបានឡើងជិះរថភ្លើងទៅដល់ខេត្តបាត់ដំបង ។ នៅពេលចុះពីរថភ្លើង ចាន់ថា និងអ្នកទាំងនោះបានបន្តទៅដំណើរទៅមុខទៀត ហើយអ្នកខ្លះក៏រត់បែកគ្នាចូលព្រៃរៀងៗខ្លួន ។ ចាន់ថា បានឃើញ មនុស្សជាច្រើនបានស្លាប់នៅតាមផ្លូវ និងក្នុងព្រៃបណ្តាលមកពីគ្មានអាហារហូបគ្រប់គ្រាន់ ។ ដោយយល់ឃើញថា ការបន្តរត់ចូលព្រៃកាន់តែលំបាក និងខ្លាចស្លាប់ខានបាន ឃើញមុខឪពុកម្តាយបងប្អូន ចាន់ថា ក៏សម្រេចចិត្តត្រឡប់មកស្រុកកំណើតវិញ ។

**សុខ ខណ្ណៈ**



រូបចម្លាក់ និងបដិមា បាក់បែកដែលគរចោល និងគ្មានការថែទាំ ក្នុងអំឡុងពេលសង្គ្រាម

# អដ្ឋិធាតុមួយ បានជួបជុំគ្រួសារ



អដ្ឋិធាតុមួយក្នុងចំណោមអដ្ឋិធាតុ៤៦៤ ដែលបានប្រទះឃើញកាលពីខែកុម្ភៈ ឆ្នាំ២០១៥ នៅក្រោមបល្ល័ង្កព្រះ វត្តលង្កាបានជួបជុំក្រុមគ្រួសារវិញហើយ ។ គ្មានអ្វីដែលសប្បាយជាងជួបជុំក្រុមគ្រួសារនារដូវបុណ្យទាននោះទេ ។ រដូវបុណ្យភ្ជុំបិណ្ឌទើបកន្លងផុត បាននាំមកនូវភាពរីករាយដែលប្រជាជនខ្មែរមានឱកាសបានជួបជុំក្រុមគ្រួសារ និងបានធ្វើបុណ្យឧទ្ទិសកុសលដល់បុព្វការីជន ឪពុកម្ដាយ សាច់ញាតិ ដែលបានចាកឋានទៅកាន់លោកខាងមុខ ។ ក្នុងឱកាសជួបជុំគ្នានាបិណ្ឌទី១៣ នៃពិធីបុណ្យបិណ្ឌភ្ជុំនេះ ក៏នាំមកនូវភាពរីករាយដល់គ្រួសាររបស់ ប៊ុទុមរស្មី ដែលទើបតែរកឃើញអដ្ឋិធាតុរបស់ម្ដាយ ពេជ្ជ បណ្ឌិត ដែលបាត់ទៅកាលពី៣៥ឆ្នាំមុន នៅវត្តលង្កា ។ អត្ថន័យនៃការរកឃើញអដ្ឋិធាតុរបស់ម្ដាយ ប៊ុទុមរស្មី គឺជាការបំពេញខ្លឹមសារនៃការជួបជុំគ្រួសារ ដែលបានបាត់បង់ជាច្រើនឆ្នាំកន្លងមកហើយ តាំងពី ប៊ុទុមរស្មី នៅក្មេងៗម្ល៉េះ ។ ប៊ុទុមរស្មី បានជឿថា ការជួបជុំនេះនឹងជួយឲ្យកូនចៅរស់នៅប្រកបដោយក្ដីសុខសប្បាយ និងមានភាពត្រជាក់ត្រជុំក្នុងគ្រួសារ ។ «គ្រប់គ្នានៅក្នុងគ្រួសារខ្ញុំសប្បាយចិត្តខ្លាំងណាស់ និងមានអារម្មណ៍ធូរស្រាល ដែលបានរកឃើញអដ្ឋិធាតុរបស់ម្ដាយខ្ញុំវិញ ។ ដូចនេះ ខ្ញុំបានយកអដ្ឋិធាតុម្ដាយទៅតម្កល់ជិតគ្នានឹងឪពុកខ្ញុំ» ។

ម្ដាយរបស់ ប៊ុទុមរស្មី បានទទួលអនិច្ចកម្មទៅកាលពីឆ្នាំ ១៩៨៥ ហើយបានបូជា ដោយធាតុមួយផ្នែក បានយកទៅបណ្ដែតទឹក ដើម្បីឲ្យមានភាពត្រជាក់ជុំ និងមួយផ្នែកទៀតដាក់តម្កល់ក្នុងកោដ្ឋ ក្នុងវត្តលង្កា ។ កាលណោះ ដោយពុំទាន់មានចេតិយរៀបចំតម្កល់នៅឡើយ ទើបបានយកទៅតម្កល់នៅជិតព្រះពុទ្ធបដិមាធំ ។ ពីរឆ្នាំក្រោយមក អដ្ឋិធាតុនោះក៏មិនដឹងបាត់ទៅទីណា ។ ប៊ុទុមរស្មី និងក្រុមគ្រួសារបានតាមរកអដ្ឋិធាតុ ដែលបាត់ពីទីតាំងដើម គ្រប់ទីកន្លែងនៅវត្ត រួមទាំងក្រោមបល្ល័ង្កព្រះ ប៉ុន្តែពុំបានជួបប្រទះឡើយ ។ ជារៀងរាល់ឆ្នាំ ពេលមានពិធីបុណ្យទាន ប៊ុទុមរស្មី តែងតែមកធ្វើបុណ្យឧទ្ទិសកុសលជូនដល់អ្នកម្ដាយ ដោយដឹងថា លោកប្រាកដជានៅកន្លែងណាមួយក្នុងវត្តលង្កា ហើយតែងតែបុណ្យស្រន់ថា សូមឲ្យជួយរកឃើញអដ្ឋិធាតុ ។ ជាច្រើនឆ្នាំកន្លងមក ប៊ុទុមរស្មី តែងតែមានអារម្មណ៍ថា «បាត់ធាតុ» និងពុំមានអារម្មណ៍ស្ងប់ឡើយ ។ បើដឹងអដ្ឋិធាតុនៅកន្លែងណាមួយច្បាស់លាស់ កូនចៅអាចទុកធ្វើបុណ្យ និងឧទ្ទិសកុសលដល់លោកបាន ។ គាត់បានមានប្រសាសន៍ទៀតថា «ដោយសារគ្មានជម្រើសអ្វី ខ្ញុំត្រូវតែទុកចិត្តដល់ទេវតា ហើយបើនរណាពុំជឿខ្ញុំក៏មិនដឹងដែរ តែបើមិនជឿ សូមកុំប្រមាថ» ។ ប៊ុទុមរស្មី ពិតជាមានក្ដីសង្ឃឹមថា នៅថ្ងៃណាមួយនឹងបានរកឃើញអដ្ឋិធាតុរបស់អ្នកម្ដាយជាមិនខាន ។

បុណ្យកុសលពិតជាកើតមានមែន ។ ទើបពេលភ្ជុំបិណ្ឌនេះ ប៊ុទុមរស្មី បានឮថាមានការរៀបចំអដ្ឋិធាតុសារជាថ្មី ដោយក្រុមការងារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយគាត់ក៏បានមករកក៏បានជួបនឹងអដ្ឋិធាតុដូចបំណងមែន ។ គាត់ពិតជាមានសេចក្ដីត្រេកអរ និងបានថ្លែងអំណរគុណ ឧទ្ទិសកុសលផលបុណ្យដល់លោកអ្នកដែលបានជួយរៀបចំតម្កល់អដ្ឋិធាតុនេះ នាយកនៃមជ្ឈមណ្ឌល និងក្រុមការងារ ។

ការជួបជុំគ្រួសារ ការកសាងកុសលផលបុណ្យ និងបំពេញទានដើម្បីឧទ្ទិសដល់អ្នកជាទីស្រលាញ់ទៅកាន់សុគតិភព និងដែលជាប្រយោជន៍សង្គម និងជំនឿសាសនា បានជួយឲ្យមានភាពពេញនៃខ្លឹមសារជីវិត និងនាំមកនូវសេចក្ដីស្ងប់ ដែលជាមូលដ្ឋានគ្រឹះសំខាន់ក្នុងការជួយឲ្យបានសម្រេចផលផ្សេងៗនៃទិសដៅជីវិត ។ មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា នឹងមានក្រុមគ្រួសារផ្សេងទៀតអាចរកឃើញអដ្ឋិធាតុរបស់សាច់ញាតិរបស់ខ្លួន ដែលមានតម្កល់ក្នុងចំណោមអដ្ឋិធាតុ៤៦៣ នៅវត្តលង្កា ។ **សេង គន្ធី**

# ចាប់ពីរបបខ្មែរក្រហម ដល់ឧប្បត្តិហេតុ ហាំបាលី : អត្តសញ្ញាណជនជាតិចាម នៅក្នុងយុគសម័យសកលភាវូបនីយកម្ម

*(តពីលេខមុន)*

### *៣) ស្ថាប័ននានាសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា និងគោលនយោបាយអនុវត្តចំពោះជនជាតិចាម*

*ភ្លាមៗ ក្រោយពីបានកាន់កាប់ទីក្រុងភ្នំពេញ និងឆ្លើយតបតាមការទាមទាររបស់ស្ថាប័នអន្តរជាតិ ប្រឆាំងនឹង "ការឈ្លានពានក្រុមកុម្មុយនីស្ត" នៅថ្ងៃទី៨ ខែមករា ឆ្នាំ១៩៧៩ ចលនារំដោះចាប់ផ្តើមបង្ហាញនូវក្រុមប្រឹក្សាបដិវត្តន៍ប្រជាជនកម្ពុជា ដើរតួនាទីជាអន្តររាជរដ្ឋាភិបាល ដែលក្រោយមកបានបង្កើតគណៈកម្មាធិការស្ម័យរៀបចំក្នុងប្រទេស ។ ជាដំបូងក្រុមប្រឹក្សាបដិវត្តន៍ប្រជាជនកម្ពុជាដឹកនាំដោយ ហេង សំរិន កាន់អំណាចក្នុងប្រទេសកម្ពុជារហូតដល់ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១ ទើបរដ្ឋធម្មនុញ្ញថ្មីបានបង្កើតឡើងដើម្បីជំនួសក្រុមប្រឹក្សារដ្ឋមន្ត្រី ។*

*គ្រានោះ ប៉ែន សុវណ្ណ ត្រូវបានតែងតាំងជារដ្ឋមន្ត្រី រួមទាំងឧបនាយករដ្ឋមន្ត្រីពីររូបទៀតគឺ ហ៊ុន សែន, ចាន់ ស៊ី និង ជា សុទ្ធ ។ តែក្រោយមក ប៉ែន សុវណ្ណ ត្រូវបានដកហូតតំណែង ហើយប្រគល់ឲ្យ ចាន់ ស៊ី ឡើងជំនួសវិញ ។ ប៉ែន សុវណ្ណ អះអាងថា រូបគាត់ធ្លាប់បានរិះគន់អំពីរឿងតួនាទីរបស់វៀតណាមលើទឹកកម្ពុជាថា មានរយៈពេលវែង ហើយវត្តមានជ្រកកោនរបស់ជនជាតិវៀតណាមលើទឹកដីកម្ពុជាក៏មានចំនួនច្រើនហួសហេតុ ។ ដោយឡែកក្រុមប្រឹក្សាបដិវត្តន៍ប្រជាជនកម្ពុជាបង្កើតតុលាការបដិវត្តន៍ប្រជាជន*



*ជនជាតិចាមជួបជុំគ្នា បន្ទាប់ពីធ្វើពិធីសំពះយ៉ាំងនៅវិហារ*

កាត់ទោសចំពោះ ប៉ុល ពត និង អៀង សារី សម្រាប់ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ព្រមទាំងករណីរឿងរបស់ ម៉ាត់ លី ដែលជាដើមបណ្តឹងរដ្ឋប្បវេណី ។ ពាក់កណ្តាល ឆ្នាំ១៩៧៩ ម៉ាត់ លី គឺជារដ្ឋលេខាធិការនៃក្រសួងការពារជាតិ ។

រដ្ឋធម្មនុញ្ញក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា បានតាក់តែងឡើងក្នុងខែមិថុនា ឆ្នាំ១៩៨១ ភ្លាមៗក្រោយពីរដ្ឋសភាជាតិត្រូវបានបង្កើតឡើង ។ ជារឿងមិនធម្មតាមួយដែលរដ្ឋធម្មនុញ្ញនេះបង្ហាញគោលការនយោបាយចម្បងរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា អត្ថន័យប្រឆាំងនឹងជំហរប្រទេសចិន និងសហរដ្ឋអាមេរិកមានដូចជា របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ប្រឆាំងនឹង “ចិនឈ្លានពាន និងអនុត្តរជនក្នុងព្រឹត្តការណ៍ទីក្រុងប៉េកាំង ក្រុមឃុបឃិត និងក្រុមចក្រពត្តិសហរដ្ឋអាមេរិក និងប្រទេសមហាអំណាចផ្សេងៗទៀត” ។ រដ្ឋធម្មនុញ្ញត្រូវបានពង្រាងដោយក្រុមប្រឹក្សាដែលដឹកនាំដោយ រស់ សាម័យ ប៉ុន្តែសេចក្តីព្រាងនោះត្រូវបានកែប្រែជាច្រើនចំណុចក្រោយមក ។ ស្ថិតក្រោមបរិបទរដ្ឋធម្មនុញ្ញបែបនេះ មានតែបក្សប្រជាជនបដិវត្តន៍ដែលក្រោយមកក្លាយជាបក្សប្រជាជនកម្ពុជា ដែលមានសិទ្ធិ និងសុពលភាពអនុវត្តតាម ។ រដ្ឋធម្មនុញ្ញនេះត្រូវបានធ្វើកំណែទម្រង់នៅឆ្នាំ១៩៨៩ ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរបរិយាកាសនយោបាយក្រោយការបញ្ចប់សង្គ្រាម ។

នៅពេលនោះសរីរាង្គដឹកនាំថ្នាក់កំពូលរបស់រដ្ឋាភិបាលមានក្រុមប្រឹក្សារដ្ឋមន្ត្រី ឬគណៈរដ្ឋមន្ត្រី ដែលដឹកនាំមុខដោយ ហ៊ុន សែន ឆ្នាំ១៩៨៧ ។ ដែលនេះ ទ្រទ្រង់ជាស្នូលនៃប្រព័ន្ធរដ្ឋបាលសម្រាប់រាជរដ្ឋាភិបាល ក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ តួនាទីចម្បងនៃប្រព័ន្ធនេះគឺ “រៀបចំ សម្របសម្រួល បង្រួបបង្រួម ព្រមទាំងដឹកនាំរាល់គ្រប់សកម្មភាពទូទៅនៃក្រសួងពាក់ព័ន្ធ និងអាជ្ញាធរក្នុងតំបន់ ។ ដោយឡែក ក្រុមប្រឹក្សារដ្ឋមន្ត្រីមាន នាយករដ្ឋមន្ត្រីមួយរូប ដើរតួជាគណៈអធិបតី និងជាអ្នកដឹកនាំ មានគណៈអធិបតីរង៧រូប ជាឧបនាយករដ្ឋមន្ត្រី រួមទាំងរដ្ឋមន្ត្រីទាំង២០រូបទៀត គឺជាសមាជិក ។ រដ្ឋសភាជាតិជាអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារដ្ឋមន្ត្រីក្នុងរយៈពេលមួយអាណត្តិប្រាំឆ្នាំ ។ ខណៈពេលដែលគ្មានវត្តមានក្រុមប្រឹក្សារដ្ឋមន្ត្រីត្រូវរាយការណ៍ទៅដល់ក្រុមប្រឹក្សារដ្ឋ ។ បន្ថែមលើនេះ មានប្រធានគ្រប់គ្រងបុគ្គលិក ដែលជារដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការការិយាល័យនៃក្រុមប្រឹក្សារដ្ឋមន្ត្រី មានលេខាធិការទូទៅ ប្រធានអធិការកិច្ច ទេសាភិបាលនៃធនាគារជាតិប្រជាជនកម្ពុជា ។ ប្រធានអធិការកិច្ចទទួលបន្ទុកពិនិត្យ និងតាមដានគ្រប់ចំណូលចំណាយសារពើពន្ធរបស់ស្ថាប័នសាធារណៈ ។ ក្រុមប្រឹក្សារដ្ឋមន្ត្រីចូលរួមកិច្ចប្រជុំប្រតិបត្តិជារៀងរាល់សប្តាហ៍ ព្រមទាំងកិច្ចប្រជុំពេញអង្គជាទៀងទាត់ ។ ក្រុមប្រឹក្សារដ្ឋមន្ត្រីជាអ្នកបង្កើតផែនការ “ក-៥” ។

ជាក់ស្តែង ការបង្កើតកម្លាំងចោរព្រៃរបស់រាជរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យប្រឆាំងនឹងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ជំរុញឲ្យរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាបង្កើតផែនការយក្ស “ក-៥” ព្រមទាំងត្រូវសម្រេចឲ្យបានចន្លោះឆ្នាំ១៩៨៥ដល់១៩៨៩ ។ ផែនការនេះទាមទារឲ្យមានលេណដ្ឋានសាងសង់ហ៊ុមព័ទ្ធដោយខ្សែលួសជារបង និងបង្កប់មីនតាមព្រំដែនខ្មែរ-ថៃ មានប្រវែង៨០០គីឡូម៉ែត្រ និងទំហំ៥០០ម៉ែត្រ ។ នៅតាមតំបន់ព្រំដែនជាប់នឹងប្រទេសថៃ ជាកន្លែងគ្មានមនុស្សរស់នៅព្រោះសម្បូរទៅដោយព្រៃភ្នំ ។

ដើម្បីសម្រេចបានផែនការនេះ យើងត្រូវប្រើអស់កម្មកររាប់រយពាន់នាក់ តែជាក់ស្តែង ផែនការនេះគ្មានប្រសិទ្ធភាព ព្រោះថាចុងក្រោយកម្លាំងចោរព្រៃអាចបង្វែររកផ្លូវវាងតាមព្រំដែន ។ ផ្ទុយទៅវិញ ផែនការនេះបានបង្កបញ្ហាបរិស្ថានដោយសាររុក្ខជាតិព្រៃឈើដ៏សន្ធឹកសន្ធាប់ត្រូវបានកាប់បំផ្លាញទាំងឬសគល់ អំឡុងពេលដំណើរការ ។ ស្ថិតក្នុងតំបន់ត្រូពិច ការកាប់ជម្រះទាមទារឲ្យមានការថែរក្សាឲ្យបានត្រឹមត្រូវ ព្រោះរុក្ខជាតិតូចធំនឹងដុះមកវិញយ៉ាងឆាប់រហ័ស ជាពិសេសអំឡុងរដូវវស្សា ។ ការថែរក្សាតំបន់នេះទៀតសោតទាមទារកម្លាំងកម្មករច្រើនសន្ធឹកសន្ធាប់ដែលកម្លាំងទាំងនោះត្រូវចាកចេញពីដីស្រែមកចូលក្នុងទប់ស្កាត់ ។ សម្រាប់ប្រជាជនកម្ពុជាដែលធ្លាប់ឆ្លងកាត់សម័យខ្មែរក្រហមហាក់ដូចជាខ្លាចរអាក្នុងរឿងនេះ ។ ជាលទ្ធផល ប្រជាជនជាច្រើនស្លាប់ដោយសារជំងឺគ្រុនចាញ់ និងបាក់កម្លាំង ដោយសារគ្មានស្បៀងអាហារ និងសម្ភារគ្រប់គ្រាន់ គ្មានថ្នាំព្យាបាលត្រឹមត្រូវ ហើយកន្លែងស្នាក់នៅតាមតំបន់ដាច់ស្រយាល ។ អ្នកមួយចំនួនទៀត ក៏បានស្លាប់ដោយ

សារការវាយប្រហាររបស់កម្លាំងទ័ពរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។ ជនជាតិចាមលើទឹកដីកម្ពុជា ក៏បានចូលរួមក្នុងផែនការនេះដែរ ។ ក្រៅពីស្តាបនាសង្គមរបស់ខ្លួន និងអនុវត្តសាសនាខ្លួនហើយនោះ ជនជាតិចាមបានចូលរួមចំណែកយ៉ាងសកម្មក្នុងសង្គមនិយមថ្មីមួយទៀត ។ ការចងចាំ និងបទពិសោធន៍របស់ជនជាតិចាមសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា មិនមានអ្វីគួរឲ្យកត់សម្គាល់ទេ ។

សម័យខ្មែរក្រហម ធ្វើឲ្យអ្នកដឹកនាំសាសនាបាត់បង់ជីវិតស្ទើរតែគ្មានសេសសល់ទាំងសាសនាព្រះពុទ្ធ និង អ៊ីស្លាម ។ របបក្រោយនេះ ការប្រណិប័តន៍សាសនា ត្រូវបានស្តាបនាឡើងវិញភ្លាមៗ ក្រោយបានអំណាចមកវិញ ។ អ្នកទាំងនោះកសាងជំនឿលើព្រះពុទ្ធសាសនា និងបើកឲ្យប្រើប្រាស់ឡើងវិញនូវទីវត្តអារាម ។ នៅដើមឆ្នាំ១៩៧៩ ព្រះសង្ឃចាស់ៗត្រូវបានឲ្យបំបួសម្តងទៀតក្នុងទីក្រុងភ្នំពេញ ។ អ្នកទាំងនោះកសាងទីវត្តអារាមនានា ព្រមទាំងសហគមន៍ពុទ្ធសាសនិកជនពាសពេញប្រទេសកម្ពុជា ។ ឆ្នាំ១៩៨០ ពិធីបុណ្យនានាតាមបែបព្រះពុទ្ធសាសនាត្រូវបានធ្វើឡើងវិញ ដូចជាបុណ្យភ្ជុំបិណ្ឌ និង កឋិនទាន ។

សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា មានការព្យាយាមតម្រែតម្រង់ឲ្យមានគ្រប់ជាតិសាសន៍ចម្រុះលើទឹកដីកម្ពុជា ។ ក្នុងរបបនេះ អ្នកដែលរងគ្រោះជាងគេនោះគឺជនជាតិចិន ដោយសារអ្នកទាំងនោះត្រូវបានចាត់ទុកថា ជាខ្សែស្រឡាយចិន ដែលជាគូបដិបក្ខរបស់វៀតណាម ក៏ជាសត្រូវរបស់ខ្មែរដែរ ។ ភាសាចិនកុកងឺ និងចិនទាជីវ ត្រូវបានហាមប្រាម ។ ចំណុចនេះជនជាតិចាមត្រូវបានផ្តល់តម្លៃឲ្យច្រើនក្នុងសម័យនោះ ។ ជនជាតិចាមត្រូវបានអនុញ្ញាតឲ្យមានការឃោសនាដោយសេរី ដរាបណាស្ថិតក្រោមដួងព្រលឹងជាតិ មិនបង្កអំពើហិង្សា បំផ្លិចបំផ្លាញកិច្ចការរដ្ឋ និងមិនទាញយកផលចំណេញខាងនយោបាយ ។ វិហារអ៊ីស្លាមនានាត្រូវបានជួសជុលតាមគ្រប់មធ្យោបាយ ។ នៅចុងទសវត្សរ៍ឆ្នាំ១៩៨០ មានវិហារអ៊ីស្លាមចំនួន២០០ និងស៊ូរ៉ាវចំនួន១០០ ត្រូវបានកសាង និងជួសជុល ។ ដោយសារ ប្រទេសកាន់សាសនាអ៊ីស្លាមភាគច្រើនមិនបានចាប់អារម្មណ៍សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ទើបមានការខ្វះខាតទាំងជំនួយសកល និងអន្តរជាតិទៅកាន់សហគមន៍មួយនេះ ។ ជាទូទៅ គោលនយោបាយអនុវត្តមកលើក្រុមមូស្លីមនៅពេលនោះ គឺបានរួមបញ្ចូលរួចស្រេចទៅហើយ គ្មានការរើសអើងពូជសាសន៍នោះទេ ។ ក្នុងការខិតខំប្រឹងប្រែងកសាងសង្គម លើគ្រប់វិស័យឡើងវិញ ហាក់ដូចជាជួបការលំបាកចំពោះសហគមន៍មូស្លីមដោយសារកង្វះការគាំទ្រជាសាធារណៈពីប្រទេសមូស្លីមធំៗដែលប្រឆាំងនឹងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលមានវៀតណាមជាបង្អែក ។ ការយល់ដឹងពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម នៅមានកម្រិតសម្រាប់បស្ចិមប្រទេសនានា ។ ប៉ុន្តែជាក់ស្តែង គោលនយោបាយជាឧបសគ្គដល់ការឈានជើងចូលរបស់ប្រទេសទាំងនោះ ។ ប្រទេសជាច្រើនដូចជា គុយវ៉ែត ម៉ាឡេស៊ីអារ៉ាប៊ីសាអូឌីដ គួរតែជាម្ចាស់ជំនួយមូលនិធិធំ ជួយដល់ការរស់រានឡើងវិញរបស់សហគមន៍អ៊ីស្លាមក្រោយសង្គ្រាមស៊ីវិលតែបែរជាប្រឆាំងនឹងរបបនេះទៅវិញ ។ តែទោះជាយ៉ាងនេះក្តីប្រទេសទាំងនោះនៅតែផ្តល់ជំនួយដល់អ្នកទាំងនោះពិតប្រាកដនៅតាមព្រំដែន ។ នៅតាមព្រំដែនថៃការអាណិតអាសូរដល់ជនភៀសខ្លួនមូស្លីមធ្វើឡើងតាមរូបភាពជំនួយតាំងលំនៅសាជាថ្មី និងជំនួយមនុស្សធម៌ផ្សេងៗ ។

ជនជាតិចាមផ្ទាល់ ប្រឹងប្រែងដោយខ្លួនឯងផង ក្នុងការកសាងវិហារអ៊ីស្លាម និងស៊ូរ៉ាវឡើងវិញ ក្នុងប្រទេសកម្ពុជា ។ អ្នកទាំងនោះជ្រើសរើសអ្នកដឹកនាំសាសនាថ្មី មានអ៊ីមាំ ហាគីម និងទូនជំនួសឲ្យអ្នកដែលបានស្លាប់ក្នុងរបបខ្មែរក្រហម ។ ក្នុងករណីមួយចំនួនសាសនាអ៊ីស្លាមថ្មីជាផ្លូវការនេះ ត្រូវតែមានការបណ្តុះបណ្តាលនិងបង្រៀនពីច្បាប់នានាដែលមានចែង ដោយសារការអនុវត្តតាមសាសនាមួយនេះត្រូវបានលុបបំបាត់ទាំងស្រុងក្នុងរបបខ្មែរក្រហម ។ រហូតមកទល់ឥឡូវនេះ ការទ្រទ្រង់ផ្នែកហេដ្ឋារចនាសម្ព័ន្ធមានតិចតួចបំផុត សម្រាប់សាសនាថ្មីមួយនេះ ។ ជនអន្តោប្រវេសន៍មូស្លីមដែលមកពីវៀតណាម ថៃ និងម៉ាឡេស៊ី បានផ្តល់ជំនួយជាច្រើនដល់សហគមន៍អ៊ីស្លាមកម្ពុជា ។

ការយកចិត្តទុកដាក់ស៊ីជម្រៅចំពោះជនជាតិចាមក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាដើម្បីឆ្លុះបញ្ចាំងអំពីកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីទទួលបានការគាំទ្រ និងទំនុកចិត្តពីជនជាតិចាមក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា យោងតាមសេចក្តី

ថ្លែងការណ៍របស់ ហេង សំរិន បានចង្អុលបង្ហាញពីស្ថានភាពរបស់ជនជាតិចាមក្នុងសម័យ សីហនុ សម័យសង្គមរាស្ត្រនិយម និងសម័យ លន់ នល់ ដូចតទៅ ៖

ជនជាតិចាមត្រូវបានគេផ្សព្វផ្សាយ (sic)

ជនជាតិចាមត្រូវបានគេងប្រវ័ញ្ច និងមាក់ងាយ ។ គ្មានជនណាម្នាក់យកចិត្តទុកដាក់អំពីសិទ្ធិរបស់ជនជាតិចាមលើការសិក្សាភាសាផ្ទាល់ខ្លួន ។ ស្តង់ដារនៃការរស់នៅមិនល្អទាល់តែសោះ ។ អ្នកទាំងនោះគ្មានសិទ្ធិពេញលេញក្នុងការចូលរួមកិច្ចការផ្សេងៗក្នុងប្រទេសកម្ពុជា ។ ជនជាតិចាមគ្មានសិទ្ធិសេរីភាពក្នុងការប្រារព្ធពិធីអបអរសាទរបុណ្យជាតិរបស់ខ្លួន ។ បើចង់ធ្វើដូច្នេះ ត្រូវតែមានសំណូក ។ លើសពីនេះទៅទៀត របបមុននេះបានប្រើប្រាស់សាសនាអ៊ីស្លាមជាឧបករណ៍បំបែកអត្តសញ្ញាណសហគមន៍ជនជាតិចាម ។ របបមុនបែងចែកក្រុមចាស់ និងថ្មីដែលជាមធ្យោបាយងាយស្រួលក្នុងការគ្រប់គ្រង និងជញ្ជក់យកប្រយោជន៍ពីជនជាតិចាម ។ គេប្រើប្រាស់សាសនាអ៊ីស្លាមគឺជាឧបករណ៍ពង្រឹងអំណាចទាញយកផលចំណេញនយោបាយ ព្រមទាំងវណ្ណៈ ។

យោបល់ទាំងនេះបង្ហាញពីការយល់ដឹងរបស់ ហេង សំរិន មកលើជនជាតិចាម ដែលគាត់ធ្លាប់រីតចំណងមិត្តភាពជាមួយសហគមន៍ ដើម្បីទាញយកផលប្រយោជន៍ និងការគាំទ្រ ។ ទោះបីជាយ៉ាងនេះ ការលើកឡើងរបស់គាត់មួយចំនួនស្ថិតក្នុងស្ថានភាពមន្ទិលសង្ស័យ ។ សម័យ សីហនុ មានកម្មវិធីសិក្សាអប់រំដែលទាមទារឲ្យជនជាតិចាមទាំងអស់ត្រូវតែសិក្សាជាភាសាខ្មែរ តែកម្មវិធីសិក្សានោះមានការខ្វះចន្លោះដោយមិនបញ្ចូលភាសាចាម សម្រាប់ជនជាតិចាមក្នុងកម្មវិធីសិក្សា ។ ជនជាតិចាមភាគច្រើនចេះទាំងពីរភាសា ប៉ុន្តែក្មេងៗជំនាន់ក្រោយកម្រនឹងប្រើប្រាស់ភាសារបស់ខ្លួន ជាយានណាស់ ។ ត្រឡប់មកវិញ ជនជាតិចាមអាចទំនាក់ទំនងគ្នាបានយ៉ាងងាយស្រួលដោយប្រើប្រាស់ភាសាខ្មែរជាយាន តែមានសូរសៀងប្លែកដោយការមិនសង្កត់សំឡេង ។ ចំពោះស្តង់ដារនៃការរស់នៅវិញមានសភាពសមរម្យ ការចូលរួមក្នុងកិច្ចការសាធារណៈផ្សេងៗ


កុមារជនជាតិចាមរៀននៅសាលាសាសនាមួយ ស្ថិតក្នុងសង្កាត់គីឡូម៉ែត្រលេខ៧ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ក៏មានការកើនឡើង ។ ការនិយាយភាសាខ្មែរមានសារប្រយោជន៍ខ្លាំង ជាពិសេសសម្រាប់ជនជាតិចាមមួយចំនួននៅតាមជនបទ ។ករណីពិសេសក្នុងទីក្រុងភ្នំពេញ ជនជាតិចាមមួយចំនួនដែលរស់នៅក្នុងឃុំជ្រោយចង្វារច្រើនតែមានលក្ខណៈរស់នៅល្អ និងមានតួនាទីល្អៗក្នុងជួររដ្ឋាភិបាល មុនពេលដែលមានរបបខ្មែរក្រហម ។ចំពោះសេចក្តីថ្លែងការណ៍របស់ ហេង សំរិន ប្រហែលជាការជំរុញឲ្យកើនឡើងនូវចំនួននៃអ្នកចូលរួមដែលជាជនជាតិចាមក្នុងជួររដ្ឋាភិបាលក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ សព្វថ្ងៃនេះយើងអាចមើលឃើញថាចំនួននៃការចូលក្នុងស្ថាប័នរដ្ឋាភិបាលកើនឡើងច្រើនជាងមុន ។

សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ក៏បានបង្កើតនូវឯកសារយោង ដែលមានអត្ថន័យថា «ក្រុមសាសនាចាស់ និងថ្មី» ឬក្រុមចាស់ និងក្រុមថ្មី ដែលជាបញ្ហាចម្រូងចម្រាសមួយក្នុងសម័យមួយក្នុងសម័យ សីហនុ ទសវត្សរ៍ឆ្នាំ៦០ ដែលបានលើកឡើងក្នុងជំពូកទី៣ ។ ទោះបីជាសម័យ សីហនុ ព្យាយាមបញ្ចប់នូវជម្លោះរវាងក្រុមចាស់ និងថ្មី យើងនៅតែឃើញជម្លោះបន្តដល់សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ការព្យាយាមបែងចែក និងគ្រប់គ្រងលើជនជាតិចាមបន្តពីសម័យ សីហនុ ។ ចាមទទួលយកឥទ្ធិពលពីសកល តែមានកម្រិត ។ ដូច្នេះ ការបែងចែកសាសនានៅមានទំហំតូច ប៉ុន្តែលក្ខណៈសព្វថ្ងៃនេះ ឥទ្ធិពលពីសកលរលូនទៅមុខឥតឈប់ឈរ ភាពខុសប្លែកគ្នានៅក្នុងវង្វង់សាសនា គឺមិនអាចជៀសវាងបាននោះទេ ។ ជាក់ស្តែង ជម្លោះពិតប្រាកដនាំមកនូវភាពទន់ខ្សោយក្នុងសហគមន៍ ប៉ុន្តែនេះគឺជាតួនាទីរបស់សហគមន៍ចាមដើម្បីរារាំង និងដោះស្រាយជម្លោះផ្ទៃក្នុង ។

ប្រភពមួយផ្សេងទៀតក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាក៏បានធ្វើការរិះគន់គោលនយោបាយរបស់សម្តេច សីហនុ ចំពោះជនជាតិចាម ។

សាសនាអ៊ីស្លាម ស្ថិតក្នុងស្ថានភាពច្របូកច្របល់ ។ ជនជាតិចាមជឿជាក់លើសាសនាទាំងភាពងងឹតងងុល ។ មានបុគ្គលមួយចំនួនព្យាយាមនាំទៅកាន់ផ្លូវខុស ការយល់ដឹងខុសចំពោះសាសនា


វិហារអ៊ីម៉ាំសាន់ នៅស្រុកមោងឫស្សី ខេត្តបាត់ដំបង

អ៊ីស្លាម ។ អ្នកទាំងនោះបង្កើតជាបញ្ហាដោយការបញ្ចុះបញ្ចូលឲ្យជឿលើគ្រូទាយ មន្តអាគមន៍ អាប ធ្មប់ និងព្រលឹង ដែលទាំងនេះមិនមែនជាចំណុចដែលត្រូវរៀននៅក្នុងគម្ពីរគួរអាន ។ អ្នកទាំងនោះបង្កើតក្រុមផ្សេងគ្នា ក្រុមចាស់ និងថ្មី ដែលបង្កើតជម្លោះ ធ្វើឲ្យសហគមន៍ចាមមានការបែងចែក ។ ពួកសក្តិភូមិប្រើប្រាស់ឧបាយកលដើម្បីបំបែកសហគមន៍ចាម និងដឹកនាំអ្នកទាំងនោះ ។

នៅក្នុងឯកសារនេះដដែល រិះគន់ចំណុចមួយទៀតចំពោះការយកចិត្តទុកដាក់របស់សម្តេច សីហនុ មកលើជនជាតិចាម ។ ដោយលើកឡើងការប្រើពាក្យ "ខ្មែរអ៊ីស្លាម" ដែលសម្តេច សីហនុ ច្រើននិយាយក្នុងទសវត្សរ៍ឆ្នាំ៦០ ដែលជាផ្នែកមួយនៃកម្មវិធីបញ្ចូលក្រុមជនជាតិភាគតិចទៅក្នុងសង្គមខ្មែរ ។ តែត្រង់ចំណុចនេះ សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា បែរជាយល់ថា ជាការព្យាយាមដើម្បីបំបាត់អត្តសញ្ញាណរបស់ក្រុមជនជាតិភាគតិច ។ ផ្ទុយពីការពិត នៅក្នុងសម័យនេះពាក្យ "ចាម" "ជនជាតិភាគតិចចាម" ឬ "ចាមមូស្លីម" ក៏ត្រូវបានគេយកមកប្រើប្រាស់ដដែល ។

ទស្សនៈយល់ឃើញរបស់ ជា ស៊ីម និង ហេង សំរិន ចំពោះជនជាតិចាម ភ្លាមៗប្រហែលជាពីរទៅបីខែ មុនពេលចាប់ផ្តើមវាយលុកនារដូវក្តៅពីឆ្នាំ១៩៨៤-១៩៨៥ ប្រឆាំងនឹងបក្សរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យក្នុងអធិបតេយ្យទឹកដីកម្ពុជា នៃសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលមានវៀតណាមនៅពីក្រោយអ្នកដឹកនាំសម័យសាធារណរដ្ឋ រៀបចំកិច្ចប្រជុំមួយដែលមានរយៈពេល៥ថ្ងៃជាមួយនឹងអ្នកដឹកនាំសហគមន៍ មានដូចជាហាកឹម និងទួន នៅក្នុងទីក្រុងភ្នំពេញ ។ ជា ស៊ីម តួនាទីជាប្រធានសភាជាតិ គឺជាគណៈធិបតីក្នុងកិច្ចប្រជុំនេះ ព្រមទាំង ហេង សំរិន ដែលនាយករដ្ឋមន្ត្រីក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ម៉ាត់លី គឺជាអ្នករៀបចំកម្មវិធីដ៏ស្ទិតស្វាញម្នាក់ ។ គាត់ប្រហែលជាត្រូវចាត់តាំងឲ្យគ្រប់គ្រង និងរាយការណ៍រាល់សកម្មភាពក្នុងកិច្ចប្រជុំដែលរៀបរាប់ទាំងចំណុចល្អ និងចំណុចអាក្រក់អំពីសហគមន៍ចាម ព្រមទាំងសកម្មភាពធ្វើឡើងចំពោះសហគមន៍ជនជាតិភាគតិចនេះ ។ កិច្ចប្រជុំនេះបង្ហាញភាពដឹកនាំក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជាចំពោះជនជាតិចាម និងស្វែងរកនូវកិច្ចសហប្រតិបត្តការគាំទ្រ និងណែនាំឲ្យអ្នកទាំងនោះឲ្យមានភាពស្អិតរមួតទៅនឹងបក្សបដិវត្តន៍ប្រជាជនកម្ពុជា និងគោលនយោបាយរដ្ឋ ។ ឯកសារដែលបានមកពីកិច្ចប្រជុំបង្ហាញកម្រិតព័ត៌មានផ្តោតលើគោលនយោបាយទូទៅចំពោះជនជាតិចាមក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ លើសពីនេះទៀត កិច្ចប្រជុំនេះជាព្រឹត្តិការណ៍ចងចាំមួយក្នុងទំនាក់ទំនងជនជាតិចាមអំឡុងពេលដែលត្រូវបានគេចាត់ទុកថា "អន្តរកាលកសាង និងការពារទឹកដីរបស់ខ្លួន" ។

អំឡុងកិច្ចប្រជុំ ជា ស៊ីម ត្រូវតែប្រាកដថា លើកតម្កើនជនជាតិចាម ចំពោះតួនាទីរបស់ខ្លួនក្នុងកិច្ចការបដិវត្តន៍កម្ពុជាដឹកនាំបក្សបដិវត្តន៍ប្រជាជនកម្ពុជា ។ ជា ស៊ីម ពោលថា "បើគិតទៅគឺ៥ឆ្នាំហើយតាំងពីប្រទេសជាតិត្រូវបានរំដោះ ។ ប្រទេសយើងដើរទៅមុខយ៉ាងឆាប់រហ័ស ផ្លាស់ប្តូរមុខមាត់ ហើយជាតិរបស់យើងក៏មានភាពរីកចម្រើនបន្តិចម្តងៗដែរ ។ ដូច្នេះ កេរ្តិ៍ឈ្មោះរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជាក៏បានលូតលាត់នៅលើឆាកអន្តរជាតិទន្ទឹមគ្នានេះដែរ ។ តែទាំងនេះទៅមុខបានដោយសារតែមានការចូលរួមយ៉ាងសកម្មពីជនជាតិចាម" ។

ជា ស៊ីម រៀបរាប់យ៉ាងលម្អិតរាល់ចំណុចដែលជនជាតិចាមបានរួមចំណែក ។ រាល់ការលើកឡើងនេះឆ្លុះបញ្ចាំងពីសកម្មភាពចម្បងក្នុងការកសាងសហគមន៍នានាឡើងវិញ ជាពិសេស គឺជនជាតិចាម សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ គាត់លើកឡើងថា ជនជាតិចាម បានបង្កើតក្រុមសាមគ្គីគ្រប់ផ្នែកទាំងអស់ រួមមាននេសាទ ជលផល ការចិញ្ចឹមសត្វ កសិកម្ម និងសិប្បកម្ម ។ ភាគច្រើនជាអ្នកស្នេហាជាតិ និងមានភាពស្មោះត្រង់ក្នុងការការពារ និងកសាងសង្គមកម្ពុជា ។ ក្រៅពីផ្គត់ផ្គង់ខ្លួនឯង ជនជាតិចាមលក់ស្បៀងទៅឲ្យរដ្ឋលើសពីចំនួនដែលរដ្ឋត្រូវការ ។ យុវជនចាម ចូលរួម ស្ម័គ្រចិត្តចូលរួមក្នុងកងទ័ព កងឈ្លប និងកងពល ផ្សេងៗដើម្បីការពារស្រុកភូមិ ប្រទេសជាតិ ប្រឆាំងនឹងសត្រូវឈ្លានពាន ចង់កម្ទេចរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងស្តាបនាឡើងវិញនូវសហគមន៍ចាមក្រោយរបបប្រល័យពូជសាសន៍ ។

ជា ស៊ីម បន្តថា សត្រូវព្យាយាមប្រើប្រាស់គ្រប់នីតិវិធីដើម្បីបំផ្លាញរាល់សមិទ្ធផល ដែលប្រជាជនកសាង និងសមិទ្ធផលជាតិ ។ អ្នកទាំងនោះបំផ្លិចបំផ្លាញដោយចេតនាបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ ដុតផ្ទះ ជាពិសេសទៅទៀតនោះ គឺជ្រៀតចូលសហគមន៍ជន

ជាតិចាម ដោយក្លែងខ្លួនជាអ៊ីស្លាម ។ អាស្រ័យហេតុដូច្នេះហើយ ជនជាតិចាមតែងមានការប្រុងប្រយ័ត្នគ្រប់ពេលនៅពេលធ្វើបទបង្ហាញពីសាសនារបស់ខ្លួន ។ ជា ស៊ីម លើកឡើងអំពីសេរីភាពខាងសាសនាក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាថា «សព្វថ្ងៃនេះសាសនាអ៊ីស្លាម និងជនជាតិចាមរស់ឡើងវិញហើយ ។ ជនជាតិចាម អាចប្រណិប័តន៍សាសនារបស់ខ្លួនបានម្តងទៀតហើយ ។ ដោយមូស្លីមទាំងអស់មានសិទ្ធិសេរីភាពដូចគ្នានឹងជនជាតិផ្សេងៗទៀតដែរក្នុងប្រទេសកម្ពុជា ។ ជនជាតិចាមត្រូវបានការពារដោយគោលការទាំង១១ របស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងធម្មនុញ្ញក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា» ។

ក្រៅពីរំដោះប្រទេសជាតិចេញផុតពីរបបប្រល័យពូជសាសន៍ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ថ្ងៃដែលរបបសាធារណរដ្ឋប្រជាមានិតកម្ពុជារំព្ញកពីខួប៥ឆ្នាំ ហេង សំរិន និយាយថាស្ថិតក្នុងសម័យសារធារណរដ្ឋអ៊ីៗ បានផ្លាស់ប្តូរទៅរកភាពប្រសើរសម្រាប់ជនជាតិចាមបានច្រើនណាស់ ។ គាត់លើកឡើងថា ៖

ជនជាតិចាមត្រូវបានគេយកចិត្តទុកដាក់ និងចាត់ទុកដូចជាសមាជិកម្នាក់ក្នុងគ្រួសារ ។ គ្មានការរើសអើងពូជសាសន៍ដូចក្នុងរបបមុនទេ មានតែភាពស្មើគ្នារវាងចាម និងជនជាតិផ្សេងៗទៀតចាត់ទុកដូចជាមិត្តភក្តិ ឬក្រុមគ្រួសារតែមួយ ។ សម្លៀកបំពាក់ និងវប្បធម៌របស់ជាជាតិចាមត្រូវបានរក្សាទុក ។ ដូច្នេះ ជនជាតិចាម និងខ្មែរពួតដៃគ្នាប្រឆាំងនឹងសត្រូវទូទៅ ។ សេរីភាពខាងសាសនាមានភាពសម្បូរបែប ។ ស្តង់ដារនៃការរស់នៅក៏មានភាពប្រសើរ ។ នៅក្នុងរបបថ្មីនេះ ជនជាតិចាម មានទឹកន្លែងត្រឹមត្រូវក្នុងការគោរពទីសក្ការរបស់ខ្លួន ។

ចក្ខុវិស័យចំពោះតួនាទីជនជាតិចាមក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ជា ស៊ីម សរុបសេចក្តីថ្លែងការណ៍របស់គាត់ដោយលើកឡើងពីគោលនយោបាយផ្សះផ្សាទៅកាន់ជនជាតិចាម «ដែលវង្វេងផ្លូវ» ។ គាត់និយាយដូចតទៅ ៖

ជនជាតិចាមគួរតែអនុវត្តគោលការអត់ឱន ក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ក្រោម «ចលនាជនវង្វេងផ្លូវ» ទៅកាន់ប្រជាជនដែលវង្វេង ឬខុសផ្លូវ ដោយសារគ្រោះថ្នាក់ណាមួយវង្វេង ឬត្រូវបង្ខំដោយសត្រូវណាមួយ ដែលឥឡូវនេះស្ថិតនៅក្នុងដៃក្រុមសត្រូវគ្រប់ប្រភេទ ហើយព្យាយាមបញ្ចុះបញ្ចូលអ្នកទាំងនោះឲ្យត្រឡប់មកសន្តមខ្លួនវិញព្រមទាំងរួបរួមគ្នាឡើងវិញ ។

គោលការរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ក៏ស្នើសុំជនជាតិចាមដែលរស់នៅតាមព្រំដែនកម្ពុជា-ថៃត្រឡប់មកវិញដោយសម្មាងថា ឆ្នាំ១៩៨៤ មានជនជាតិចាមរាប់ពាន់នាក់ដែលរស់នៅតាមជំរំព្រំដែន ។ ទោះបីជាអ៊ីចឹង ហេង សំរិន ស្នើសុំថាជនជាតិចាម ត្រូវតែថែរក្សាការពារជម្រកព្រៃឈើ អាចកាប់បានតែស្ថិតនៅក្រោមអាជ្ញាធរជាតិ ជៀសវាងការនេសាទត្រីនូវរដូវត្រីពង ។ ត្រូវតែសកម្មលើកាផរព្យាយាមយល់ពីទីតិវិធីនៃចលនានេះ ។ ព្យាយាមសិក្សាពីគោលនយោបាយចលនានេះ ចំពោះជនជាតិមូស្លីម ហើយត្រូវតែជៀសវាងនូវក្រុមចាស់ឬថ្មីទាំងអស់នោះដែលគំរាមកំហែងដល់សហគមន៍ជនជាតិចាម ។ បន្តសិក្សាលើទាំងភាសាខ្មែរ និងភាសាចាមដើម្បីបង្កើនអក្ខរភាពក្នុងចំណោមជនជាតិចាម ។ សហការគ្រប់ផ្នែកទាំងអស់ជាមួយនឹងអាជ្ញាធរក្នុងតំបន់ដើម្បីសាងសង់សាលារៀន និងមន្ទីរពេទ្យ ។

សំខាន់ជាងនេះទៀតនោះ គាត់លើកឡើងថា «ហាកឹម និងទួន ត្រូវតែស្នើសុំឲ្យប្រជាជនចាមចូលរួមកងទ័ព ។ ប្រយុទ្ធប្រឆាំងនឹងសុខុមាលភាពផ្លូវចិត្តរបស់សត្រូវ (ដូចដែលសត្រូវរិះគន់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា) ដោយរិះគន់អ្នកទាំងនោះ និងដាក់ទោសចំពោះអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម ។ សត្រូវទាំងនោះរួមមាន ខ្មែរក្រហម និងក្រុមរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ដែលព្យាយាមបង្អាក់រារាំងការរស់រានឡើងវិញរបស់ជនជាតិចាម» ។ ភ្លាមៗនោះ ហេង សំរិនដាស់តឿនជនជាតិចាមថា «ស្ថិតក្រោមរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា មិនអនុញ្ញាតឲ្យនរណាម្នាក់ ប្រើប្រាស់សាសនាអ៊ីស្លាម ជាឧបករណ៍ដើម្បីបំពេញតម្រូវការផ្ទាល់ខ្លួន ឬយកឈ្នះសត្រូវឡើយ» ។ គាត់សង្កត់ធ្ងន់ថា «មូស្លីមដឹកនាំដោយរដ្ឋ ដូច្នេះហើយត្រូវតែគោរពច្បាប់រដ្ឋ» ។

ឯកសារផ្សេងមួយទៀតនោះ បង្ហាញពីចំណុចដែលជនជាតិចាមគួរតែកែតម្រូវ ។ ដំបូងឯកសារនោះរៀបរាប់ថា ជនជាតិចាមមិនបានអនុវត្តតាមគោលការណ៍របស់បក្សបានត្រឹមត្រូវនោះទេ ។

ជនជាតិចាមនៅតែមានអបិយជំនឿលើអារក្សអ្នកតា ។ ជនជាតិចាមមិនទទួលស្គាល់នូវការបកប្រែគម្ពីរគួរអាន និងអត្ថបទសាសនាផ្សេងៗ ។ ជនជាតិចាមធ្វើឲ្យមានការបែងចែករវាងក្រុមថ្មី និងក្រុមចាស់ ។ ពេលប្រារព្ធពិធីបុណ្យម្តងៗជនជាតិចាមសម្លាប់សត្វច្រើនហួសប្រមាណដែលកាត់បន្ថយបរិមាណនៃកម្លាំងជំនួយការងារស្រែចម្ការ ។ នៅពេលឈឺម្តងៗ ជនជាតិចាមតែងតែជឿលើអបិយជំនឿ និងបន់ស្រន់លើព្រលឹងអារក្សអ្នកតា ។ ជនជាតិចាមមួយចំនួនតូចស្ទាក់ស្ទើរក្នុងការចូលរួមធ្វើទ័ព ។ ស្ត្រីជនជាតិចាមមួយចំនួនមិនទាន់យល់ច្បាស់ពីសកម្មភាពបដិវត្តន៍ ។ ជាពិសេសជាងនេះទៀតនោះគឺឯកសារនេះបែងចែកដាច់រវាងសាសនាប្រៀបធៀបជាមួយរដ្ឋមានដូចតទៅ “ការគោរពសាសនាទាល់តែអាជ្ញាធរអនុញ្ញាត ។ បើគ្មានការអនុញ្ញាតនោះទេ ការគោរពសាសនាក៏មិនអាចប្រព្រឹត្តទៅបាននោះដែរ ។ អាស្រ័យហេតុដូច្នេះហើយរាល់បញ្ហាទាំងអស់ដែលបានកើតឡើង ត្រូវតែយកមកធ្វើការពិភាក្សាប្រជាធិបតេយ្យ និងក្រោមអាជ្ញាធរជាតិ” ។ ទោះបីជាក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា សង្កត់ធ្ងន់លើសិទ្ធិ និងសេរីភាពខាងប្រណិប័តន៍សាសនាក៏ដោយ តែត្រូវស្ថិតនៅក្នុងវិសាលភាពណាមួយ នេះហើយជាបន្ទាប់ព្រំដែននៃវិសាលភាព ។

នៅរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា បង្កើតនូវគោលការណ៍មួយអនុវត្តសម្រាប់ជនជាតិចាមមានដូចតទៅ ៈ

**សម្រាប់សកម្មភាពបដិវត្តន៍ ៈ**

កសាង និងពង្រឹងចលនាបដិវត្តន៍ ដែលនាំការបដិវត្តន៍រំកិលទៅមុខបាន ។

សិក្សាឲ្យបានច្បាស់ និងស៊ីជម្រៅ អំពីគោលនយោបាយការសម្រេចចិត្ត និងប្រព័ន្ធដែលបង្កើតដោយបក្ស និងរដ្ឋ ។

ជនជាតិចាមទាំងអស់ត្រូវតែជំរុញសាច់ញាតិ ដូចជាប្តីប្រពន្ធ និងកូនៗឲ្យចូលរួមបម្រើកងទ័ព ជាពិសេសគឺស្ត្រីចូលរួមក្នុងចលនាបដិវត្តន៍ឲ្យកាន់តែខ្លាំងក្លា ។

ជនជាតិចាមត្រូវតែរឹតចំណង និងពង្រីកវិសាលភាពក្រុមសាមគ្គី ក្នុងវិស័យកសិកម្ម និងនេសាទ ដូច្នេះអ្នកទាំងនោះនឹងមាន



ពិធីបុណ្យម៉ាឡុត នៅភូមិស្រែប្រិយ៍ ឃុំអូរបុស្សី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង

ស្បៀងហូបចុកគ្រប់គ្រាន់ ហើយរស់នៅមានសុភមង្គល ។

ជនជាតិចាមត្រូវតែបង្កើននូវទន្និផលនេសាទ និងការពារជម្រកត្រីទាំងនោះ នេះបង្ហាញថា អ្នកទាំងនោះបានដើរតួនាទីចម្បងក្នុងការពន្លឿនសេដ្ឋកិច្ចជាតិ ។

**ទំនាក់ទំនងជាសកល ៖**

ពង្រឹងចំណងមិត្តភាពរវាងកម្ពុជា វៀតណាម និង ឡាវ ។ ពង្រីង និង ពង្រីកចំណងមិត្តរវាងសហគមន៍ចាម និងក្រុមជនជាតិដទៃទៀតក្នុងប្រទេសកម្ពុជា និងអន្តរជាតិដែលតែងតែជួយគាំទ្រកម្ពុជា និងសហគមន៍ចាម ។

**ប្រពៃណី និងវប្បធម៌ ៖**

ជនជាតិចាមត្រូវតែរៀនអក្សរសាស្ត្រខ្មែរឲ្យបានទូលំទូលាយ ដូច្នេះអ្នកទាំងនោះអាចយល់ដឹងរាល់គោលនយោបាយដែលបានបង្កើតឡើងដោយរដ្ឋ គណបក្ស និងចលនា ។

លុបបំបាត់បន្តិចម្តងៗរាល់ប្រពៃណីដែលមិនបានចារក្នុងគម្ពីរគួរអាន ព្រមទាំងច្បាប់រដ្ឋ ។ ជាពិសេស ត្រូវតែជឿជាក់ថា សាសនាអ៊ីស្លាមត្រូវតែល្អបរិសុទ្ធ ព្រមទាំងបូកផ្សំជាមួយនឹងរូបភាពបដិវត្តន៍ ត្រូវតែមានភាពស៊ីគ្នា រវាងសាសនាអ៊ីស្លាម និងចលនាបដិវត្តន៍ ជាការពិត ជៀសវាងប្រើប្រាស់សាសនាដើម្បីបំពេញប្រយោជន៍ផ្ទាល់ខ្លួន សេដ្ឋកិច្ចផ្ទាល់ខ្លួន ។

**សង្គ្រាម ៖**

ព្យាយាមកម្ចាត់សត្រូវកុំឲ្យសល់សូម្បីតែម្នាក់ ។ ជនជាតិចាមត្រូវប្រយុទ្ធប្រឆាំង និងកម្ចាត់បក្សរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ និងចងកំហឹងជាមួយនឹងក្រុមប្រល័យពូជសាសន៍ ប៉ុល ពត, អៀង សារី និង ខៀវ សំផន ដែលជាអាយ៉ងរបស់ចិន អាមេរិក និងអាស៊ាន ។

ជនជាតិចាមត្រូវតែដឹងពីល្បិចកលរបស់សត្រូវដែលប្រើប្រាស់សាសនាអ៊ីស្លាម និងសុខុមាលភាពផ្លូវចិត្ត ដើម្បីបំផ្លាញបដិវត្តន៍ ។

ជនជាតិចាមត្រូវតែព្យាយាមបញ្ចុះបញ្ចូល "ជនវង្វេងផ្លូវ" ដោយសារការបំពុល ការបញ្ចុះបញ្ចូល និងបង្ខិតបង្ខំពីសត្រូវឲ្យត្រឡប់មករកគ្រួសារ និងប្រទេសជាតិវិញ ។ ត្រូវតែច្បាស់លាស់ថា "ជនវង្វេងផ្លូវ" ទាំងនោះទទួលបាននូវគោលនយោបាយអត់ឱនរបស់បក្ស មានភាពងាយស្រួលត្រឡប់មកវិញ និងសម្របខ្លួនតាមបដិវត្តន៍ ។

## ១) ជនជាតិចាមស្ថិតក្រោមរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា

នៅពេលរបបខ្មែរក្រហមដួលរលំនៅខែមករា ឆ្នាំ១៩៧៩ ជនជាតិចាមទាំងអស់ធ្វើដំណើរពាសពេញប្រទេសកម្ពុជា ដើម្បីស្វែងរកសាច់ញាតិ ធ្វើដំណើរទៅកាន់លំនៅដ្ឋានរបស់ខ្លួនវិញ ស្វែងរកស្បៀង ទីជម្រក និងសុវត្ថិភាព ក៏ដូចជា កសាងសហគមន៍របស់ខ្លួនឡើងវិញ ។ ជនជាតិចាមរាប់ពាន់នាក់ធ្វើដំណើរទៅកាន់ជំរំនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ចំណែកអ្នកផ្សេងទៀតធ្វើដំណើរដោយថ្មើរជើងអស់ជាច្រើនសប្តាហ៍ ទៅកាន់ទីក្រុងភ្នំពេញ មានពាក្យចចាមអារ៉ាមមួយផ្សេងទៀតថា នឹងផ្តល់ឱកាសសម្រាប់ជីវិតថ្មី ។

ពាក់កណ្តាលឆ្នាំ១៩៨០ ការរស់នៅតាមភូមិ ឃុំ និងទីប្រជុំជននានា មានសភាពនឹងនឡើងវិញ នេះក៏ដោយសារជំនួយមនុស្សធម៌នានា មកពីសហភាពសូវៀត វៀតណាម និងខាងបស្ចិមប្រទេសមួយចំនួន ។ ចំនួនជនភៀសខ្លួនតាមជំរំក៏កើនឡើងដល់៣០០.០០០នាក់ ។ ទន្ទឹមគ្នានេះដែរ ភាពអត់ឃ្លាន ដែលជាលទ្ធផល បណ្តាលមកពីសង្គ្រាម និងការដាំដុះមិនបានល្អ ក្នុងឆ្នាំ១៩៧៨នោះគឺជាបញ្ហា ។ ក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានត្រៀមខ្លួនជាស្រេច ក្នុងការគាំទ្រទៅកាន់តំបន់ទីជនបទនានារហូតដល់តាមព្រំដែនបស្ចិមប្រទេស ហើយក៏បានដាក់ការិយាល័យត្រួតពិនិត្យរបស់ខ្លួននៅទីនោះដែរ ។

## កែ ម៉ាត់ ៖ ក្លាយជាគ្រូបង្រៀនសាសនា

កែ ម៉ាត់ គឺជាទូន និងព្រឹទ្ធាចារ្យសាសនានៅក្នុងស្រុកកំពង់ត្រឡាច ។ គាត់បានក្លាយជា អ៊ីមុាំ ប្រចាំស្រុកតាំងពីឆ្នាំ២០០៨ និងបានក្លាយជាសមាជិកក្រុមប្រឹក្សាស្រុកចាប់តាំងពីឆ្នាំ២០០៩ ។ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង គឺជាស្រុកមួយក្នុងចំណោមស្រុកដទៃទៀតដែលមានប្រជាជនមូស្លីមរស់នៅច្រើនជាងគេក្នុងប្រទេសកម្ពុជា ។ ខ្ញុំបានជួប កែ ម៉ាត់ នៅឆ្នាំ២០១០ ពេលមួយដែល គាត់បានចូលរួមការប្រជុំជនជាតិភាគតិចចាមដែលបានរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ឥឡូវនេះ គាត់មានអាយុ៤៨ឆ្នាំហើយ គាត់មានសាលារៀនមួយក្នុងស្រុកកំពង់ត្រឡាចដើម្បីបង្ហាត់បង្រៀន

គម្ពីរគួរអាន និងច្បាប់នានានៃសាសនាអ៊ីស្លាមទៅដល់ក្មេងៗអ៊ីស្លាមជំនាន់ក្រោយ ជាវគ្គសិក្សាបំពេញបន្ថែមលើកម្មវិធីសិក្សានៅតាមសាលារដ្ឋ ។ នៅទីនោះ ក៏មានបង្ហាត់បង្រៀន ភាសាអារ៉ាប់ ម៉ាឡេ និងភាសាអង់គ្លេស ។ សាលារៀននោះមានឈ្មោះថា អង្គនាគមាស ។ សាលារៀននេះបានទទួលការគាំទ្រដោយក្រុមប្រឹក្សាជាន់ខ្ពស់កិច្ចការសាសនាអ៊ីស្លាមក្នុងទីក្រុងភ្នំពេញ ។ ទោះជានាយកសាលាផង និងជាគ្រូបង្ហាត់ផង គាត់ទទួលបានត្រឹមតែ៥០ដុល្លារប៉ុណ្ណោះ ក្នុងមួយខែ ។ កែ ម៉ាត់ ព្យាយាមធ្វើយ៉ាងណាឲ្យសាលារបស់គាត់ដុះដាលទៅមុខរហូត និងសហគមន៍របស់គាត់មានសភាពកាន់តែប្រសើរឡើង ដោយសារគាត់បានធ្វើកិច្ចការជាច្រើនបើគិតតាំងពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមប្រឆាំងនឹងជនជាតិចាម ឆ្នាំ១៩៧៥ ដល់ ១៩៧៩រហូតមកទល់ពេលនេះ ។

ជាការពិត កែ ម៉ាត់ មានស្រុកកំណើតនៅកំពង់ត្រឡាចនេះតែម្តង ។ នៅពេលដែលខ្មែរក្រហម កាន់កាប់បានប្រទេសកម្ពុជា នៅខែមេសា ឆ្នាំ១៩៧៥ គ្រួសាររបស់គាត់ត្រូវបានជម្លៀសចេញពីកំពង់ត្រឡាចនេះទៅកាន់ខេត្តសៀមរាប ។ ពេលនោះគ្រួសាររបស់គាត់ស្នាក់នៅក្នុងភូមិដាច់ស្រយាលមួយក្នុងស្រុកស្វាយលើ ខេត្តសៀមរាប នេះជាបំណងរបស់ខ្មែរក្រហមដើម្បីបំបែកជនជាតិចាមរស់នៅប្រមូលផ្តុំគ្នា និងលាយឡំជនជាតិចាមនឹងខ្មែរ ។ ដោយសារតែខ្វះចំណីអាហារ និងកម្លាំងគ្រប់គ្រាន់ ឪពុកម្តាយរបស់ កែ ម៉ាត់ បានស្លាប់ក្នុងឆ្នាំ១៩៧៧ ។ ចំណែកឯ កែ ម៉ាត់ និងបងប្អូនប្រុសស្រីទាំង៣នាក់ទៀត ព្យាយាមតស៊ូបន្តជីវិតរស់នៅក្នុងភូមិសហករណ៍ ។ ក្រោយមកគាត់ត្រូវបានគេ ហៅថា សឹនមិនមែនកែ ម៉ាត់ ។ ខ្មែរក្រហមយល់ឃើញថា កែ ម៉ាត់ គឺជាក្មេងវ័យឆ្លាតម្នាក់ ហើយអត្តសញ្ញាណស្លូលរបស់ក្មេងនេះបានសាបរលាបទៅហើយ ដូច្នេះក្មេងនេះអាចកែប្រែបានទៅជាជនបដិវត្តន៍ប្រកបដោយភាពវ័យឆ្លាត ។ សំណាង កែ ម៉ាត់ ព្រមទាំងបងប្អូនរួចរស់មានជីវិតពីរបបនេះ ។

នៅខែមករា ឆ្នាំ១៩៧៩ នៅពេលដែលខ្មែរក្រហមចាកចេញពីស្រុកស្វាយលើ កែ ម៉ាត់ និងបងប្អូនប្រុសស្រីទាំងប៉ុន្មានសំណាងបានត្រឡប់ទៅកាន់ស្រុកកំណើតរបស់ខ្លួនវិញនៅកំពង់ត្រឡាច ។ គ្រួសារចាមមួយចំនួនទៀតត្រូវជម្លៀសទៅតាមខ្មែរក្រហម ពេលដែលគេដកថយនៅព្រំដែនកម្ពុជា-ថៃ ។ កែ ម៉ាត់ ជាក់ស្តែងនិយាយប្រាប់ថា ជនជាតិចាមតិចតួចបំផុតដែលចង់ទៅតាមខ្មែរក្រហមនោះ ហើយភាគច្រើនអ្នកទៅតាមត្រូវទៅដោយការបង្ខំទេ ។ កែ ម៉ាត់ បន្តថា ប្រសិនបើអ្នកទាំងនោះមានជម្រើសនោះ គេនឹងត្រឡប់ទៅកាន់ស្រុកកំណើតរបស់ខ្លួនវិញដូចជារូបគាត់ដែរ នៅពេលរំដោះខែមករា ឆ្នាំ១៩៧៩ ។

ជារួម កែ ម៉ាត់ និងបងប្អូនចំណាយពេលអស់ពីសប្តាហ៍ចេញពីខេត្តសៀមរាបទៅកាន់កំពង់ត្រឡាច ។ តាមផ្លូវអ្នកទាំងនោះត្រូវឆ្លងកាត់បឹងទន្លេសាបទម្រាំទៅដល់ស្រុកកំណើតខ្លួន ។ យ៉ាងណាមិញ កែ ម៉ាត់ និងបងប្អូនធ្វើដំណើរជាមួយនឹងហ្វូងអ្នកភូមិផ្សេងទៀត រាប់ពាន់នាក់ ឆ្ពោះទៅកាន់ផ្លូវជាតិលេខ៦ ដើម្បីត្រលប់ទៅកាន់ស្រុកកំណើតវិញ ហើយសង្ឃឹមថា នឹងបានជួបបងប្អូន សាច់ញាតិដែលនៅរស់ ។ សម្រាប់ជនជាតិចាម ស្រុកកំណើតគឺជាទីណាត់ជួបបងប្អូនសាច់ញាតិដែលបានបែកគ្នាឲ្យត្រឡប់មកជួបគ្នាសាជាថ្មីវិញ ។ ចំពោះ កែ ម៉ាត់ វិញ ការបាត់បង់ឪពុកម្តាយ ក្នុងពេលព្រមៗគ្នាគឺជារឿងអាណោចអាធ័ម តែបើប្រៀបធៀបជាមួយគ្រួសារដទៃទៀតឃើញថា ស្ថានភាពរបស់គាត់មានសភាពធូរស្រាលនេះដោយសារតែបងប្អូនទាំងអស់នៅរស់នៅឡើយ ។ គាត់ត្រឡប់ទៅកាន់កំពង់ត្រឡាចវិញ រំពឹងទុកនឹងបានជួបបងប្អូនសាច់ញាតិជិតឆ្ងាយ ដែលអាចជួយផ្គត់ផ្គង់រូបគាត់ ព្រមទាំងក្រុមគ្រួសារផង ។ ក្រោយមក គាត់រកឃើញពូមីងដែលនៅរស់ ហើយបានជួយចិញ្ចឹមបីបាច់គាត់នៅក្នុងគ្រួសារ ។

មិនខុសអ្វីពីសហគមន៍ចាមផ្សេងទៀតក្នុងប្រទេសកម្ពុជា ស្រុកកំពង់ត្រឡាចមិនសូវមានប្រជាប្រិយភាពនោះទេក្រោយរបបខ្មែរក្រហម ។ ស៊ូរ៉ាវ ដែលសង់ឡើងពីឈើត្រូវបានគេបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុង មានតែគ្រោងវិហារអ៊ីស្លាមដែលសល់តែមួយតែប៉ុណ្ណោះដែលបានបន្សល់ទុក ។ គួរបញ្ជាក់ថា ខ្មែរក្រហមធ្លាប់បានប្រើវិហារនេះធ្វើជាកន្លែងឃុំឃាំងមុនគេ ក្រោយមកក្លាយជាមន្ទីរពេទ្យ ។ ក្រោយមកភ្លាមៗនោះ ជនជាតិចាមធ្វើការបោសសម្អាតវិហារនោះ និងជួសជុលឡើងវិញ ។ កែ ម៉ាត់ រៀបរាប់ថា ថ្វីបើយើងបានបាត់បង់បញ្ញវន្តមូស្លីម និងព្រឹទ្ធាចារ្យ និងអ្នកភូមិជាច្រើនក្នុងស្រុកកំពង់ត្រឡាច តែយើងនៅតែមានចាស់ព្រឹទ្ធាចារ្យដែលនៅ

រស់ ដើម្បីស្តាបនាសាសនាដែលជិតត្រូវបាត់បង់ឡើងមកវិញ និង ប្រណិបត័ន៍តាម ។ នៅពេលដែលមានរឿងមួយមិនច្បាស់ គេតែង តែលើកឡើងពិភាក្សារួមគ្នា ដោយពឹងលើគម្ពីរគួរអាន និងកាតាប់ ដែលគេប្រមែប្រមូលបាន ។ ជនជាតិចាមព្យាយាមកសាងវិហារ អ៊ីស្លាម និងស៊ូរ៉ាវ បន្ថែមតាមលទ្ធភាពដែលអាចធ្វើទៅបាន ។ ឧទាហរណ៍ ជនជាតិចាមនាំគ្នារុះរោងបាយសហករណ៍របស់ខ្មែរ ក្រហម ដោយយកឈើរុះទាំងនោះទៅសាងសង់ស៊ូរ៉ាវតូចមួយ ។ ការប្រឹងប្រែងនេះបន្តឲ្យអ្នកទាំងនោះមានឆន្ទៈព្រមទាំងភាពរីករាយ ដែលខ្លួនធ្លាប់មានមុនរបបខ្មែរក្រហម ។

ម្តាយមីង កែ ម៉ាត់ បានចុះឈ្មោះឲ្យគាត់ចូលរៀនអនុវិទ្យាល័យអប់រំបែបវិទ្យាសាស្ត្រ នៅក្នុងឆ្នាំ១៩៨១ ។ តែត្រឡប់មកវិញ ការអប់រំបញ្ចូលសាសនានៅក្នុងកម្មវិធីសិក្សានៅពុំទាន់មានឡើយ ។ ជាក់ស្តែងនៅក្នុងភូមិទ្រា ខេត្តកំពង់ចាម ក៏ពុំទាន់មានសាលាអប់រំសាសនានៅឡើយ ។ បើក្រឡេកមើលទៅសាលារដ្ឋវិញ បែរជាគ្មានថ្នាក់រៀនត្រឹមត្រូវ គ្មានសៀវភៅគោល សៀវភៅសរសេរ និងសម្ភារត្រឹមត្រូវ ។ ពេលនោះ កែ ម៉ាត់ មានក្តារឈ្នួនប្រើដីសតែមួយប៉ុណ្ណោះ ។ តែទោះជាយ៉ាងណាគាត់រៀនចេះអាន និងសរសេរអក្សរខ្មែរ ។

នៅឆ្នាំ១៩៨៦ សាលាអប់រំសាសនា មានតែនៅតំបន់មួយចំនួនក្នុងខេត្តកំពង់ចាម ។ ពេលនោះម្តាយមីងរបស់ កែ ម៉ាត់ បញ្ជូនគាត់ទៅរៀននៅស្រុកពញាក្រែក ខេត្តកំពង់ចាម ។ សុះ កិរី អនាគតមូហ្វទីនៅកម្ពុជាជាអ្នកបង្កើតសាលានេះ ដែលជាសាលាដំបូងក្នុងចំណោមសាលាផ្សេងទៀត បង្រៀនសាសនាក្នុងប្រទេសកម្ពុជាក្រោយរបបខ្មែរក្រហម ។ ជាក់ស្តែង សាលារៀនអ៊ីស្លាមត្រូវបានបន្តជួសជុលរហូតដល់សព្វថ្ងៃនេះ ។ កែ ម៉ាត់ ចំណាយពេលសិក្សានៅទីនោះរយៈពេល៧ឆ្នាំ មុនត្រឡប់មកកំពង់ត្រឡាចវិញដើម្បីបង្រៀនអ៊ីស្លាមដល់អ្នកក្នុងភូមិ ឆ្នាំ១៩៩៣ ។

កែ ម៉ាត់ ប្រាប់ថា អំឡុងពេលសិក្សានៅពញាក្រែក មានគម្ពីរគួរអាន និងស៊ុនណា (អត្ថបទភាគច្រើនរបស់មូស្លីម) តិចតួចតែប៉ុណ្ណោះ ដែលអាចយកមកសិក្សាបាន ។ កែ ម៉ាត់ និងមិត្តភក្តិរបស់គាត់ចម្លងដោយដៃចេញពីគម្ពីរគួរអានព្រោះថានៅពេលនោះមិនទាន់មានម៉ាស៊ីនថតចម្លងនៅឡើយ ។ គាត់ឃើញគម្ពីរគួរអានពីរដែលសរសេរជាភាសាម៉ាឡេថា យើងរត់គេចខ្លួនពីព្រំប្រទល់កម្ពុជា-ថៃ ក្នុងឆ្នាំ១៩៨៣ ។ គាត់ចូលចិត្តសំណេរជាភាសានេះណាស់ ។ តែដោយឡែកគម្ពីរគួរអានដែលដាក់បង្រៀនក្នុងសាលាក្នុងស្រុកពញាក្រែកសរសេរជាភាសាវៀតណាម ។ មានផ្នែកខ្លះទៀតសរសេរជា ភាសាអារ៉ាប់ និងម៉ាឡេ ។ ត្រឡប់មកវិញរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាក្នុងទសវត្សឆ្នាំ១៩៨០ គឺជារបបមិនមានប្រជាប្រិយភាពទាល់តែសោះ ។ ប្រទេសអារ៉ាប់ និងមូស្លីមជាច្រើននៅតំបន់អាស៊ីអាគ្នេយ៍មិនទទួលស្គាល់របបនេះទេដូច្នេះហើយឯកសារដែលប្រើប្រាស់សម្រាប់បង្រៀនគឺមានកំណត់ ។

***(តទៅលេខក្រោយ)***

**អេង កុកថាយ**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬ សៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthbunthorn.s@dccam.org*

*Home page: www.dccam.org*

# សចនាការស្តាប់សក្ខីកម្ម និងការថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សារមឿន



ជុំ សាមឿន កើតនៅថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៦០ នៅភូមិព្រេច ឃុំឈូក ស្រុកឈូក ខេត្តកំពត ។ បច្ចុប្បន្ន សាមឿន រស់នៅភូមិទីខាងត្បូង ឃុំអណ្តូងខ្មែរ ស្រុកកំពង់បាយ ខេត្តកំពត ។ សាមឿន មានឪពុកឈ្មោះ ជុំ ជឿន ម្តាយឈ្មោះ ពៅ អួន និងមានស្វាមីឈ្មោះ រីត ច្រិក ព្រមទាំងកូនចំនួន៥ នាក់ ។

នៅឆ្នាំ១៩៧៣ (អាយុ១៣ឆ្នាំ) ជុំ សាមឿន ចូលធ្វើជាកងទ័ពបដិវត្តន៍នៅកងពលលេខ១១ ស្ថិតនៅស្រុកកោះធំ ខេត្តកណ្តាល ។ ពេលនោះ សាមឿន ទទួលបន្ទុកវែកបាយយកឲ្យកងទ័ពនៅទួលក្រសាំង ។ បងប្អូនជីដូនមួយរបស់ សាមឿន ឈ្មោះ ជុំ ជឿន និង ជុំ សៀប ក៏ចូលធ្វើកងទ័ពបដិវត្តន៍ដែរ ។ ប្អូនប្រុស សាមឿន ឈ្មោះ ជុំ ផុន ត្រូវប្រធានកងវរសេនាធំ នៅស្រុកកំពតសម្លាប់ដោយចោទថា ជាខ្មាំង ។

ក្រោយរំដោះឆ្នាំ១៩៧៥ ខ្មែរក្រហមបញ្ជូន សាមឿន ឲ្យទៅធ្វើស្រែនៅម្តុំវត្តកុល ស្ថិតនៅខាងលិចស្ទឹងមានជ័យ ក្រុងភ្នំពេញ ។ ធ្វើបានមួយរយៈ ខ្មែរក្រហមបញ្ចូល សាមឿន ឲ្យទៅនៅក្នុងកងពល៥០២ ហើយបញ្ជូនឲ្យទៅធ្វើស្រែនៅអូរបែកក្អម ។ ប្រធានកងពល៥០២ ឈ្មោះ ម៉េត ។ ម៉េត បានធ្វើចំណាត់ថ្នាក់ សាមឿន ថា មាននិន្នាការជាប់ពាក់ព័ន្ធនឹងខ្មាំង បន្ទាប់ពីស្រាវជ្រាវរកឃើញថា ឪពុក សាមឿន ធ្លាប់ធ្វើជាប៉ូលីសនៅសម័យសង្គមរាស្ត្រនិយម ហើយឪពុកចុងរបស់គាត់ជាអតីតទាហាន លន់ នល់ ។ បន្ទាប់ពីនោះ សាមឿន ត្រូវប្រធានកងចាត់ឲ្យលើកដីតែម្នាក់ឯងនៅសហករណ៍ ស្ថិតនៅខាងលិចពោធិ៍ចិនតុង ។

នៅពាក់កណ្តាលឆ្នាំ១៩៧៦ ខ្មែរក្រហមបញ្ជូន សាមឿន និងកងពលទាំងអស់ឲ្យទៅធ្វើការនៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ។ ពេលទៅដល់ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង សាមឿន ឃើញកងទ័ពរាប់ពាន់នាក់កំពុងធ្វើការនៅទីនោះហើយ ។ សាមឿន ត្រូវប្រធានកងចាត់ឲ្យវែកដី សែងថ្ម និង បង្ហាប់ដី ។ សាមឿន បញ្ជាក់ថា កងទ័ពដែលបញ្ជូនទៅទីនោះត្រូវធ្វើការបីពេលក្នុងមួយថ្ងៃ គឺពេលព្រឹក ពេលរសៀល (បន្ទាប់ពីបាយថ្ងៃត្រង់) និងពេលយប់ (បន្ទាប់ពីបាយល្ងាច) ។ លក្ខខណ្ឌការងារមានភាពតឹងតែងគ្មានពេលសម្រាកគ្រប់គ្រាន់ និងមិនអាចនិយាយប្រាស្រ័យទាក់ទងគ្នា ឬធ្វើដំណើរដោយសេរីបានឡើយ ពោលគឺម្នាក់ៗត្រូវខិតខំប្រឹងប្រែងសម្រុកធ្វើការងារឲ្យបានរហ័ស ។ របបអាហារមានការខ្វះខាត ។ គ្មានអាហារពេលព្រឹក ហើយអាហារពេលថ្ងៃត្រង់ និងពេលល្ងាចត្រូវបរិភោគលាយជាមួយពោត ។ ជាងនេះទៅទៀត អ្នកធ្វើការនៅទីនោះប្រឈមយ៉ាងខ្លាំងចំពោះបញ្ហាអនាម័យ កង្វះទឹកស្អាត បណ្តាលឲ្យកើតជំងឺពេញខ្លួន ។ ពេលយប់ ខ្មែរក្រហមរៀបចំឲ្យកងនីមួយៗសម្រាកនៅក្នុងរោង ដោយតម្រូវឲ្យដេកតម្រៀបគ្នា គ្មានមុង គ្មានកន្ទេល គឺមានតែរនាប ។ សាមឿន បញ្ជាក់ទៀតថា ទោះបីរូបគាត់ធ្លាក់ខ្លួនឈឺ (កើតពិសដៃ) ក៏ខ្មែរក្រហមនៅតែបង្ខំឲ្យគាត់ធ្វើការដែរ ។ ធ្វើការនៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំបានរយៈពេលប្រហែល៥ខែ ខ្មែរក្រហមបញ្ជូន សាមឿន មកភ្នំពេញវិញ ឲ្យមកធ្វើការជញ្ជូនឥដ្ឋដាក់បារ៉ុងរទេះភ្លើង ដើម្បីដឹកយកមកការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ។ ការងារនេះធ្វើឲ្យ សាមឿន ពងដៃ និងរបួសដៃបែកដើង ។

នៅចុងឆ្នាំ១៩៧៨ ម៉េត ប្រធានកងពល ៥០២ បង្ខំឲ្យ សាមឿន រៀបការជាមួយបុរសម្នាក់ ដែលមិនធ្លាប់ស្គាល់គ្នាពីមុនមក ។ ពិធីរៀបការពេលនោះមានចំនួន៥គូ ដែលគូនីមួយៗត្រូវ



ប្រជាជន គ្រូបង្រៀន និងសិស្សានុសិស្ស នៅភ្នំវល្លិ៍ ខេត្តកំពត ចូលរួម និងសួរសំណួរទាក់ទងនឹងសាលាក្តីខ្មែរក្រហម

ធ្វើការប្តេជ្ញានៅចំពោះមុខកម្មាភិបាលដែលចូលរួមនោះថា នឹងយកគ្នាជាប្តីប្រពន្ធ ។ ក្រោយរៀបការ ខ្មែរក្រហមអនុញ្ញាតឲ្យស្វាមីភរិយានោះរស់នៅជាមួយគ្នាចំនួនបីថ្ងៃ បន្ទាប់មកបំបែកឲ្យទៅធ្វើការរៀងៗខ្លួន ។ សាមឿន បញ្ជាក់ថា ក្នុងរយៈពេលនោះ គាត់ធ្លាប់ឮសម្រឹបដើងកងឈ្លបខ្មែរក្រហមមកស៊ើបយកការណ៍ថាតើគាត់ចុះសម្រុងជាមួយស្វាមីគាត់ដែរឬអត់ ។

បន្ទាប់ពីបញ្ចប់ការសួរដេញដោលរបស់ភាគី អង្គជំនុំជម្រះអនុញ្ញាតឲ្យ ជុំ សាមឿន ធ្វើការរៀបរាប់ទុក្ខសោក និងព្យសនកម្មដែលគាត់ទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្នុងឱកាសនោះ ជុំ សាមឿន ថ្លែងថា ៖

«តាំងពីខ្ញុំចូលបម្រើទ័ពនៅកម្ពុជាប្រជាធិបតេយ្យ គឺខ្ញុំមានប៉ះពាល់អារម្មណ៍របស់ខ្ញុំ ដូចជាខ្ញុំ ត្រូវគេឲ្យធ្វើការជាទម្ងន់ ។ ពេលខ្ញុំឈឺ កើតពិសដែក៏គេប្រើខ្ញុំ ។ ដល់ពេលខ្ញុំសុំឈប់សម្រាក ក៏គេមិនឲ្យសម្រាក ។ ហេតុដូច្នេះ អារម្មណ៍របស់ខ្ញុំរាល់ថ្ងៃ គឺ ខ្លួនខ្ញុំគឺខ្សោយបេះដូង ហើយនិងខូចតម្រងនោម ដោយការធ្វើការជាទម្ងន់ ។ ចំណែកឪពុកម្តាយ បងប្អូនខ្ញុំក៏ត្រូវគេសម្លាប់ចោល ។ ផ្ទះសម្បែងខ្ញុំត្រូវខូចខាតទាំងអស់ ខ្ញុំគ្មានដីធ្លីទាំងអស់ ។ ដល់ខ្ញុំរត់មកវិញ គឺមានតែខ្លួនខ្ញុំម្នាក់គត់ គឺនៅកំព្រាឯកា គ្មានអ្នកណាទីពឹងទាំងអស់ ។ ហេតុដូច្នេះ គឺក្នុងអារម្មណ៍របស់ខ្ញុំ គឺក្តុកក្តួលក្នុងចិត្តតាំងពីនោះរហូតដល់សព្វថ្ងៃ គឺគ្មានឪពុកម្តាយហៅ ឬបងប្អូនទាំងអស់សាច់ញាតិក៏គ្មាន ។ ហេតុដូច្នេះ អារម្មណ៍របស់ ខ្ញុំគឺក្តុកក្តួល ក្នុងអារម្មណ៍របស់ខ្ញុំ គឺមានជំងឺរហូតដល់សព្វថ្ងៃ គឺខ្ញុំរស់នៅជាមួយឪពុកម្តាយខ្ញុំ គេមិនដែលប្រើប្រាស់ខ្ញុំយ៉ាងដូច្នេះ ។ ខ្ញុំសុខចិត្តលះបង់ខ្លួនតាំងពីកុមារភាព១០ឆ្នាំ ខ្ញុំទៅបម្រើទ័ពដោយគិតថា ខ្ញុំសុខស្រួល បែរមិនសុខស្រួល ។ ប្រើខ្ញុំដូចគោ ដូចក្របី ។ អ៊ីចឹងខ្ញុំមានអារម្មណ៍ឈឺចាប់ខ្លោចផ្សានៅក្នុងចិត្តរបស់ខ្ញុំ ។ ពេលខ្ញុំរាំងរដូវ គេចោទខ្ញុំថាខ្ញុំពោះធំ ប្រើធ្វើការធ្ងន់ គឺខ្ញុំមានអារម្មណ៍ខូចខាតក្នុងខ្លួនរបស់ខ្ញុំ ។ ខ្ញុំកំព្រាម៉ែកំព្រា បងប្អូនក៏គ្មាន ។ តែឥឡូវខ្ញុំចង់សួរទៅលោក ក្រោយពីតុលាការបានរកការខុសត្រូវរបស់លោកអស់ហើយ តើលោកហ៊ានលើកដៃសំពះសូមទោសជនដែលពលីជីវិតទៅ និងអ្នកនៅរស់ដែរឬអត់? ដូចជាលោក ឌុច ដែរឬអត់? ខ្ញុំសូមតែប៉ុណ្ណឹង គឺខ្ញុំអស់ចិត្ត ទាំងបងប្អូនប្រជាជនទូទាំងប្រទេសក៏អស់ចិត្តដែរ ។ ជាសំណាង ខ្ញុំចង់ថា ឲ្យខ្ញុំបានធ្វើជាសំណាងឯកជនដូចជាអ្នកកោះពេជ្របានដែរឬទេ? គឺខ្ញុំសូមសួរតែប៉ុណ្ណឹង ។ ខ្ញុំសូមចប់ហើយ» ។

ជាការឆ្លើយតប ប្រធានអង្គជំនុំជម្រះបានជម្រាបជូនដើមបណ្តឹងរដ្ឋប្បវេណីថា ជនជាប់ចោទ ទាំងពីររូប នៅតែរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប ។ **ឌិន ជួនចន្ទ្រារ៉ែកខលក្សិនារីរតន៍**

# សវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឡាង

កាលពីខែកញ្ញា ឆ្នាំ២០១៥ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការដើម្បីស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឡាង ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្ម ទំនប់១មករា ។

## ១) ប្រវត្តិសាវតាសង្ខេបដើមបណ្តឹងរដ្ឋប្បវេណី

នៅមុនពេលប្រគល់វេទិកាជូនភាគីទាំងអស់សួរដេញដោលចំពោះសាក្សី ប្រធានអង្គជំនុំជម្រះបានសាកសួរអំពីជីវប្រវត្តិសង្ខេបរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឡាង បានរៀបរាប់ពីប្រវត្តិសាវតារជូនអង្គជំនុំជម្រះថា លោកស្រីកើតនៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៥១ នៅសង្កាត់ប្រាំងចម្រេះ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្ននៅ ភូមិកោះខ្សង ឃុំអូរជ្រៅ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។ គាត់មានឪពុកឈ្មោះ ចៅ សាង ម្តាយឈ្មោះ ស៊ីម សុខុម ស្វាមីឈ្មោះ ខៀម ខុម មានកូនចំនួនបីនាក់ ។ សព្វថ្ងៃ ដើមបណ្តឹងរដ្ឋប្បវេណីរស់នៅជាស្ត្រីមេម៉ាយ ដោយបានលែងលះជាមួយស្វាមីអស់រយៈពេលជិត ៣០ឆ្នាំ ។

នៅមុនពេលចាប់ផ្តើមសវនាការ ប្រធានអង្គជំនុំជម្រះបានជម្រាបប្រាប់នូវសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងរៀបរាប់ពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម ដែលដើមបណ្តឹងរដ្ឋប្បវេណីធ្លាប់បានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ចៅ ឡាង សម្រេចឲ្យមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសាកសួរសំណួរមកកាន់ខ្លួនដើម្បីផ្តើការថ្លែងរៀបរាប់



រណ្តៅសាកសពនៅបរិវេណមន្ទីរសន្តិសុខក្រាំងតាចាន់ ក្នុងខេត្តតាកែវ ត្រូវបានគាស់ក្រោយរបបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩

ទុក្ខសោកវេទនា និង ស្ថានភាពព្យសនកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានសាកសួរដើមបណ្តឹងរដ្ឋប្បវេណីអំពីប្រវត្តិសាវតារ និងស្ថានភាពរស់នៅរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា នៅឆ្នាំ១៩៧៥ មួយខែមុនចូលឆ្នាំខ្មែរ គាត់ធ្វើការនៅមន្ទីរពេទ្យ៤០៤ នៅខេត្តសៀមរាប ។ នៅពេលនោះ មាននារីជាវរសេនីយ៍ឯកជនជាតិហ្វីលីពីនម្នាក់បានប្រាប់ឲ្យ គាត់សុំអនុញ្ញាតពីមន្ទីរពេទ្យដើម្បីបានទៅរស់នៅជាមួយឪពុកម្តាយនៅភ្នំពេញ និងលាក់ប្រវត្តិរូបដែលធ្លាប់ធ្វើការនៅមន្ទីរពេទ្យ ព្រោះជនជាតិហ្វីលីពីនរូបនេះបានដឹងថា ទាហានខ្មែរក្រហមនឹងទទួលជ័យជំនះលើទាហាន លន់ នល់ បន្ទាប់មកខ្មែរក្រហមនឹងស្វែងរកចាប់ខ្លួនមនុស្សដែលធ្លាប់ធ្វើការនៅក្នុងរបបចាស់ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានមករស់នៅជួបជុំឪពុកម្តាយនៅសង្កាត់លេខ៤ ក្រុងភ្នំពេញ រំលងបាន១៥ថ្ងៃ នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៥ គាត់ និងមិត្តភក្តិបានទៅលេងល្បែងប្រជាប្រិយនៅកៀនស្វាយ ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលកំពុងលេងសប្បាយនឹងល្បែងប្រជាប្រិយ គាត់បានឮសំឡេងកាំភ្លើងនៃការវាយប្រយុទ្ធគ្នារវាងទាហាន លន់ នល់ និង យោធាខ្មែរក្រហម ។ គាត់បានរត់គេចខ្លួនទៅ កោះដុស ហើយរំលងបានមួយថ្ងៃក៏ត្រឡប់មកស្នាក់នៅដីឥដ្ឋ បានរយៈពេល២ខែ ។

ដើមបណ្តឹងរដ្ឋប្បវេណីបានរស់នៅបែកពីឪពុកម្តាយបន្ទាប់ពីខ្មែរក្រហមវាយរំដោះទីក្រុងភ្នំពេញ ។ គាត់បានព្យាយាមធ្វើដំណើរទៅរកឪពុកម្តាយនៅខេត្តស្វាយរៀង ព្រោះឪពុករបស់ខ្លួនធ្លាប់ធ្វើជាទាហាន ប្រចាំនៅខេត្តនោះ ។ ការធ្វើដំណើររបស់គាត់ឆ្លងកាត់ការលំបាកជាខ្លាំង ដោយត្រូវរត់គេចគ្រាប់កាំភ្លើងពីការវាយប្រយុទ្ធគ្នារវាងទាហានទាំងសងខាង ។ នៅក្នុងការវាយប្រយុទ្ធគ្នា គាត់បានឃើញប្រជាជនត្រូវគ្រាប់កាំភ្លើងដេកដួលលើដី និងទាហាន លន់ នល់ ត្រូវបានសម្លាប់ព្រោះពួកគេមិនព្រមដោះសម្លៀកបំពាក់ជាទាហានរបស់ខ្លួនចេញ ។ គាត់បានព្យាយាមឡើងលាក់ខ្លួនលើរថយន្តរបស់ខ្មែរក្រហម ដែលចម្លងតាមស្រឡាងអ្នកលឿង ដើម្បីបានធ្វើដំណើរទៅកាន់ខេត្តស្វាយរៀង ។ ពេលទៅដល់ខេត្តស្វាយរៀង ចៅ ឡាង មិនបានជួបឪពុកម្តាយទេ ដោយបានជួបគ្រួសាររបស់បងស្រីខ្លួននៅភូមិពោះព្រីង ។ បន្ទាប់មកគាត់ និងក្រុមគ្រួសារ បងស្រីរបស់គាត់ រួមទាំងប្រជាជន១៧មេសា ត្រូវបានខ្មែរក្រហមបញ្ជូនមករស់នៅភូមិអូរកន្សែងដើម្បីធ្វើកសិកម្ម ដោយស្នាក់នៅផ្ទះប្រជាជននៅមូលដ្ឋាន ។ នៅភូមិអូរកន្សែង ដោយមិនទទួលបានអាហារបរិភោគ គាត់ក៏បានដើរចាប់ក្តាមយកមកបរិភោគជាមួយបាយដែលផ្តល់ដោយប្រជាជនមូលដ្ឋាន ។

### ២) ជីវិតនៅការដ្ឋានទំនប់១មករា

ចៅ ឡាង ត្រូវបានចាត់ចូលជាកងចល័ត ទៅធ្វើការនៅការដ្ឋានទំនប់១មករា ដែលស្ថិតនៅក្បែរថ្នល់ជាតិ ។ នៅការដ្ឋានគាត់ត្រូវបានខ្មែរក្រហមបង្ខំឲ្យធ្វើការរែកដីទាំងថ្ងៃទាំងយប់ ។ គាត់ត្រូវបង្ខំឲ្យធ្វើការហួសកម្លាំងដើម្បីបានរួចផុតពីសេចក្តីស្លាប់ ព្រោះនៅរៀងរាល់បីថ្ងៃ ឬមួយសប្តាហ៍ម្តង មានការប្រជុំដើម្បីពង្រឹងការងារ និងឲ្យកងចល័តទាំងអស់ប្តេជ្ញាខិតខំធ្វើការងារឲ្យបានសម្រេចជោគជ័យ ។ មានថ្ងៃមួយ គាត់បានសុំអនុញ្ញាតមេកងសម្រាកមួយថ្ងៃ ដើម្បីទៅលេងបងស្រីនៅភូមិអូរកន្សែង ។ ពេលមកដល់ភូមិអូរកន្សែង ប្រជាជនមូលដ្ឋានបានប្រាប់គាត់ថា បងស្រីបងថ្លៃ និងក្មួយប្រុសអាយុ៣ឆ្នាំ របស់គាត់ត្រូវយោធាខ្មែរក្រហមដាក់ច្រវាក់អូសតាមរទេះគោនាំយកទៅសម្លាប់នៅក្នុងព្រៃហើយ ។ ខ្មែរក្រហមចោទប្រកាន់ក្រុមគ្រួសារបងស្រីគាត់ថា ជាខ្មែរសដោយគ្រាន់តែឃើញគ្រួសារគាត់មានអំបិលទុកបរិភោគ ។ គាត់ពិតជាមានអារម្មណ៍តក់ស្លុត និងសោកសង្រេងជាខ្លាំងចំពោះដំណឹងមរណភាពនេះ ។ ដោយសេចក្តីអាណិតស្រឡាញ់ ប្រជាជនមូលដ្ឋានបានប្រាប់ឲ្យគាត់ប្រញាប់ចាកចេញពីភូមិអូរកន្សែងដើម្បីកុំឲ្យខ្មែរក្រហមចាប់ខ្លួន ។ នៅពេលមកដល់ការដ្ឋាន គាត់ខិតខំធ្វើការកាន់តែខ្លាំងជាងពីមុនដើម្បីកុំឲ្យខ្មែរក្រហមមានការសង្ស័យ និងមានហេតុផលសម្លាប់ខ្លួនបាន ។ គាត់ធ្លាក់ខ្លួនគ្រុនក្តៅជាទម្ងន់ និងបានសម្រាកនៅមន្ទីរពេទ្យ រហូតបានជាធូរស្រាលបន្តិច ក៏ត្រឡប់មករែកដីនៅការដ្ឋានដូចដើម ។

នៅការដ្ឋានទំនប់ ១ មករា គាត់ពិតជាមានការឈឺចាប់ជាខ្លាំង ព្រោះពេល គាត់ឈឺគ្រុន គ្មានសាច់ញាតិនៅក្បែរ ហើយក៏មិន

ដែលសង្ឃឹមថាបានរស់រានមានជីវិតដែរ ។ គាត់មិនដែលបានទទួលអាហារបរិភោគគ្រប់គ្រាន់ទេ ធ្វើឲ្យខ្លួនប្រាណស្គមស្គាំង ស្បែកស្រអាប់ និងធ្វើការរហូតដល់ម៉ោង១០ ឬ១១យប់ ជារៀងរាល់ថ្ងៃ ។

នៅពេលដែល គាត់សម្រាកព្យាបាលនៅមន្ទីរពេទ្យ គាត់បានសង្កេតឃើញថា នៅមន្ទីរពេទ្យមិនមានថ្នាំដែលមានប្រសិទ្ធភាពសម្រាប់ព្យាបាល ហើយបុគ្គលិកពេទ្យក៏គ្មានជំនាញ និងវិជ្ជាជីវៈគ្រប់គ្រាន់ក្នុងការព្យាបាលអ្នកជំងឺដែរ ។ គាត់នៅចាំបានថា នៅថ្ងៃមួយខ្លួនបានជួយចាក់ម្ជុលចូលសរសៃឈាមអ្នកជំងឺដើម្បីបន្តោកសេរ៉ូម ព្រោះពេទ្យទាំងអស់គ្មានលទ្ធភាពធ្វើបាន ។

នៅការដ្ឋាន គាត់បានដឹងថា មានមនុស្សបាត់ខ្លួនជាបន្តបន្ទាប់ បន្ទាប់ពីការចូលរួមប្រជុំស្វ័យទិតៀន ចំពោះមនុស្សណាដែលមិនសកម្មក្នុងការងារ នឹងត្រូវបញ្ជូនទៅអប់រំកែប្រែ ហើយគាត់មិនដែលបានឃើញអ្នកដែលត្រូវបញ្ជូនទៅទាំងនោះត្រឡប់មកវិញឡើយ ។

### ៣) ការងារក្រោមកម្តៅថ្ងៃ នៅវាលស្រែ១០០

នៅពេលរដូវប្រមូលផលចូលមកដល់ គាត់ត្រូវបានចាត់ឲ្យទៅធ្វើស្រែ នៅវាលស្រែ១០០ ។ នៅវាលស្រែ មានអាកាសធាតុក្តៅខ្លាំង មិនមានទឹក និងអាហារបរិភោគគ្រប់គ្រាន់ ។ បន្ទាប់ពីបញ្ចប់ការប្រមូលផល គាត់ និងកងចល័តដទៃទៀត ទទួលបានការអនុញ្ញាតឲ្យមកសម្រាកនៅសហករណ៍ ដោយអង្គការផ្តល់ឲ្យកងចល័តទាំងអស់នូវបបរសណ្តែកខៀវ និងស្ករស បន្តិចបន្តួចសម្រាប់ចម្អិនបរិភោគ ។ នៅពេលដល់ថ្ងៃដែលកងចល័តទាំងអស់ត្រូវបញ្ជូនត្រឡប់ទៅ វាលស្រែ១០០ គាត់ និងមិត្តជានារីៗចំនួន៩នាក់ បានបដិសេធមិនព្រមត្រឡប់ទៅវិញដោយប្រាប់មេកងថា ពួកគាត់សុខចិត្តស្លាប់នៅសហករណ៍ ។ គាត់ និងនារីៗទាំង៩នាក់ ត្រូវបានប្រធានសហករណ៍ហៅឲ្យទៅប្រជុំនៅពេលយប់ និងបានដាក់ច្រវាក់ពួកគាត់ ហើយនាំខ្លួនបញ្ជូនទៅវាលស្រែ១០០ ។

ពេលមកដល់ការដ្ឋានវាលស្រែ១០០ ចុងភៅបានចម្អិនអាហារឲ្យក្រុមរបស់ គាត់បរិភោគ ។ គាត់គិតថា នេះជាអាហារចុងក្រោយក្នុងជីវិតរបស់ខ្លួន ព្រោះពួកគាត់មុខជាត្រូវខ្មែរក្រហមសម្លាប់ជាមិនខាន ។ ផ្ទុយទៅវិញ ខ្មែរក្រហមបានប្រាប់ ពួកគាត់ថាពួកគាត់ត្រូវបញ្ជូនទៅដាំដើមគរ និងដើមកប្បាស នៅបុស្សខ្នុរ ។

### ៤) អាពាហ៍ពិពាហ៍ដោយបង្ខំ

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់ត្រូវបានខ្មែរក្រហមបង្ខំឲ្យរៀបការជាមួយបុរសដែលមិនធ្លាប់ស្គាល់ពីមុនមក ។ មេកងថែមទាំងបានប្រាប់មិនឲ្យ គាត់បដិសេធចំពោះការរៀបចំគូស្រករដោយអង្គការ បើមិនដូច្នោះប្រាកដជាមានគ្រោះថ្នាក់ដល់ខ្លួនជាមិនខាន ។ បន្ទាប់ពីការរៀបការ គាត់ និងស្វាមីរួមរស់នៅជាមួយគ្នាបីថ្ងៃ និងមានឈ្លបខ្មែរក្រហមរង់ចាំតាមដាននៅខាងក្រោមផ្ទះ ។ រំលងបានបីថ្ងៃគាត់ និងស្វាមី ត្រូវបានបញ្ជូនចេញទៅធ្វើការនៅកន្លែងផ្សេងពីគ្នា ។

ក្រោយរបបខ្មែរក្រហមដួលរលំ គាត់បានបន្តរួមរស់ជាមួយស្វាមី និងទទួលបានកូនចំនួនបីនាក់ ។ នៅឆ្នាំ១៩៨៨ ឬ ១៩៨៩ នៅពេលដែលស្វាមីរបស់គាត់បានជួបជុំជាមួយឪពុកម្តាយរបស់ខ្លួន គាត់ក៏បានលែងលះជាមួយស្វាមី ព្រោះការរស់នៅមិនចុះសម្រុងជាមួយឪពុកម្តាយក្មេក ។ គាត់ក៏បានជម្រាបជូនអង្គជំនុំជម្រះថា មូលហេតុនៃការលែងលះនេះ ក៏បណ្តាលមកពីការរៀបការដោយបង្ខំនៅក្នុងសម័យខ្មែរក្រហម ។

ឆ្លងកាត់នូវរបបកម្ពុជាប្រជាធិបតេយ្យ បានធ្វើឲ្យគាត់បាត់បង់ញាតិសន្តានជាច្រើននាក់ រួមមាន ៖ បងស្រី ប្អូនប្រុសពីរនាក់ ម្តាយ និងឪពុក ធ្វើឲ្យគាត់រស់នៅកំសត់កំព្រារហូតមកដល់សព្វថ្ងៃនេះ ។

**ឌិន ដួងចន្ទ្រាកែវលក្ស្មីនារីរតន៍**

## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm . ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។

# សំណល់សង្គ្រាមនៅប្រទេសកម្ពុជា និងកេរដំណែល របស់ ខេត វេប :

## សង្គ្រាមនៅប្រទេសកម្ពុជា អំពើប្រល័យពូជសាសន៍ និងសន្តិភាពដែលផុយស្រួយ

ខ្ញុំបានអានរឿងរ៉ាវផ្ទាល់ខ្លួនរបស់អ្នករាយការណ៍អំពីសង្គ្រាមនៅប្រទេសវៀតណាមឈ្មោះ ខេត វេប ។ នៅឆ្នាំ១៩៧១ ទាហានវៀតកុង ដែលជាទាហានវៀតណាមខាងជើង បានចាប់ខ្លួនអ្នកស្រី ខេត វេប នៅក្នុងទឹកដីនៃប្រទេសកម្ពុជា ។ គាត់បានរៀបរាប់យ៉ាងលម្អិតអំពីព្រឹត្តិការណ៍នៃការចាប់ខ្លួន ការឃុំខ្លួន និងអារម្មណ៍ផ្ទាល់ខ្លួនរបស់គាត់ពាក់ព័ន្ធនឹងរឿងរ៉ាវដែលបានកើតឡើង ។ ការបរិយាយរបស់គាត់ទាក់ទងនឹងស្ថានភាពចលាចលនៅ



ខេត វេប

ក្នុងប្រទេសកម្ពុជា និងវៀតណាម បានធ្វើឲ្យខ្ញុំនឹកឃើញនូវបទពិសោធន៍របស់ប្រជាជនកម្ពុជាដែលធ្លាប់ឆ្លងកាត់សង្គ្រាមកម្ពុជា (១៩៧០-១៩៧៥) និងរបបប្រល័យពូជសាសន៍ខ្មែរក្រហម (១៩៧៥-១៩៧៩) ។ ខ្ញុំយល់ឃើញថា នៅក្នុងរឿងរ៉ាវដែលបានលើកឡើងមានភាពស្រដៀងគ្នាមួយនោះ គឺ សង្គ្រាម និងអំពើប្រល័យពូជសាសន៍អាចកើតឡើងទៅលើមនុស្សគ្រប់រូប មិនថាអ្នកជាកងទ័ពដែលបង្កសង្គ្រាម ឬជាប្រជាជនស៊ីវិលដែលរត់គេចពីសង្គ្រាមទេ ។ អំពើសាហាវយង់ឃ្នងអាចកើតឡើងលើជនទាំងនោះដោយមិនរើសមុខ ។ សង្គ្រាមនឹងតាមលងដួងវិញ្ញាណរបស់យើង ។ មិនតែប៉ុណ្ណោះ សង្គ្រាមអាចនឹងឆក់យកជីវិតរបស់យើងបានគ្រប់ពេលវេលា ។

សង្គ្រាម និងអំពើប្រល័យពូជសាសន៍នៅប្រទេសកម្ពុជា និងនៅប្រទេសផ្សេងទៀត តែងតែនាំមកនូវភាពវិនាសអន្តរាយ ។ ជាងនេះទៅទៀត កេរដំណែលនៃសង្គ្រាម និងអំពើប្រល័យពូជសាសន៍ នៅតែបន្តតាមយាយីយើងដែលធ្លាប់ហែលឆ្លងព្រឹត្តិការណ៍នោះ ។ សង្គ្រាម និងអំពើប្រល័យពូជសាសន៍ មិនត្រឹមតែបន្សល់នូវស្លាកស្នាមរបួសជាអចិន្ត្រៃយ៍ដល់អ្នកដែលរស់រានមានជីវិតតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបន្តប៉ះពាល់ដល់សង្គមជាតិទាំងមូល និងកូនចៅជំនាន់ក្រោយជាច្រើនជំនាន់ថែមទៀត ។

ទោះបីជាខ្ញុំមិនធ្លាប់ឆ្លងកាត់នូវបទពិសោធន៍សង្គ្រាម និងអំពើប្រល័យពូជសាសន៍ទាំងនោះដោយខ្លួនឯងផ្ទាល់ក៏ដោយ ក៏បទពិសោធន៍របស់អ្នកដែលរស់រានមានជីវិតពីសង្គ្រាម និងអំពើប្រល័យពូជសាសន៍ ប្រជាជនដែលរស់នៅប្រទេសកំពុងមាន

សង្គ្រាម ជនបរទេសដែលធ្លាក់ចូលអន្ទង់នៃភ្លើងសង្គ្រាម អ្នករាយការណ៍ព័ត៌មានអំពីសង្គ្រាមបានធ្វើឲ្យខ្ញុំរន្ធត់ជាខ្លាំង ។ ខ្ញុំអាចយល់អំពីអារម្មណ៍នៃការភ័យខ្លាចចំពោះការស្លាប់ ការតស៊ូរបស់អ្នកទាំងអស់នោះដើម្បីរស់ និងភាពអង់អាចរបស់អ្នកទាំងអស់នោះក្នុងការជាសះស្បើយពីបញ្ហាផ្លូវចិត្ត ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំមានសំណាងដែលជីវិតរបស់ខ្ញុំមិនបានជិតដាមដោយសារសង្គ្រាម និងអំពើប្រល័យពូជសាសន៍ ។ ប៉ុន្តែ ដោយសារតែផលប៉ះពាល់យូរអង្វែងនៃសង្គ្រាម និងអំពើប្រល័យពូជសាសន៍ សន្តិភាពពិតប្រាកដមួយ ការសន្យានៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីសកាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដែលបានបញ្ចប់ជម្លោះប្រដាប់អាវុធ នៅក្នុងប្រទេសកម្ពុជា ហាក់ដូចជាពិបាកនឹងសម្រេចបាន ។ ខួបលើកទី២៤នៃកិច្ចព្រមព្រៀងនេះធ្វើឲ្យខ្ញុំគិតអំពីបញ្ហាប្រឈមដែលប្រទេសកម្ពុជាកំពុងជួបប្រទះសព្វថ្ងៃ ពោលគឺ បញ្ហាប្រឈមដ៏ធ្ងន់ដែលបន្សល់ពីសង្គ្រាម និងអំពើប្រល័យពូជសាសន៍ ។

ខ្ញុំបានចាប់កំណើតនៅក្នុងគ្រួសារមួយដែលរស់រានមានជីវិតពីសង្គ្រាម និងអំពើប្រល័យពូជសាសន៍ ។ គ្រួសាររបស់ខ្ញុំបានប្រឹងប្រែងរស់បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំទៅ ។ ឪពុកម្តាយខ្ញុំខិតខំធ្វើយ៉ាងណាឲ្យខ្ញុំមានអាហារគ្រប់គ្រាន់បរិភោគ និងទទួលបានការអប់រំត្រឹមត្រូវ ។ ឪពុកម្តាយរបស់ខ្ញុំបានលះបង់ជាច្រើនដើម្បីឲ្យខ្ញុំអាចធំលូតលាស់ ។ ជាអកុសល មិនមែនក្មេងជំនាន់ក្រោយទាំងអស់សុទ្ធតែសំណាងដូចរូបខ្ញុំនោះទេ ។ ប៉ុន្តែ ក្មេងជំនាន់ក្រោយទាំងអស់នោះដែលមានអាយុស្រករនឹងខ្ញុំធំដឹងក្តីនៅក្នុងស្ថានភាពដូចខ្ញុំ ពោលគឺគ្រួសាររបស់យើងទាំងអស់គ្នាបានកសាងជីវិតសាឡើងវិញពីបាតដៃទទេបន្ទាប់ពីរបបខ្មែរក្រហម ។ យើងធំលូតលាស់នៅក្នុងពេលវេលាមួយដែលប្រទេសកម្ពុជាកំពុងប្រឹងងើបពីសង្គ្រាម និងអំពើប្រល័យពូជសាសន៍ដែលបានញាំញីប្រទេសកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំ ។ មិនខុសអំពីគ្រួសាររបស់ខ្ញុំ គ្រួសារកម្ពុជាដទៃបានប្រឹងប្រែងកសាងជីវិត



ខេត រៀប (រូបអង្គុយនៅកណ្តាល)

របស់ខ្លួនឡើងវិញ ។ ជាលទ្ធផល ប្រជាជនកម្ពុជាបានកសាងជីវិតប្រសើរជាងមុន ។ បើទោះបីជាមិនបានល្អខ្លាំងយ៉ាងណាក៏ដោយ ក៏យើងបានចាកផុតអំពីសេចក្តីស្រេកឃ្លាន ។

រហូតមកដល់សព្វថ្ងៃនេះ ការតស៊ូរបស់ប្រជាជនកម្ពុជានៅតែបន្តមានជារៀងរាល់ថ្ងៃ ។ ខ្ញុំតែងតែសង្ឃឹមថា ខ្ញុំជាបុគ្គលមួយរូបក្នុងចំណោមបុគ្គលដទៃទៀតដែលទទួលបទពិសោធន៍នៃការតស៊ូរបស់អ្នកដែលរស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍ ។ ប៉ុន្តែ ក្មេងជំនាន់ក្រោយដែលបានចាប់កំណើតនៅតែបន្តរងផលប៉ះពាល់ ។ ខ្ញុំបានឃើញក្មេងៗមួយចំនួនជួបប្រទះនូវភាពអត់ឃ្លាន មិនមានឱកាសទៅសាលារៀន ទទួលរងនូវអំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពាន ការរើសអើង និងការកេងប្រវ័ញ្ច ។ រឿងរ៉ាវទាំងអស់នេះបានកើតឡើងជាក់ស្តែងទៅលើអ្នកដែលរស់នៅក្បែរផ្ទះរបស់ខ្ញុំ សាច់ញាតិរបស់ខ្ញុំ និងនៅចំពោះមុខរបស់ខ្ញុំ ។ នៅតាមដងផ្លូវ នៅពេលដែលខ្ញុំងាកមើលក្រោយ ខ្ញុំឃើញក្មេងកំពុងសុំទាន និងកំពុងស្រេកឃ្លាន ។ ខ្ញុំឆ្ងល់ថា ហេតុអ្វីបានជាប្រជាជនកម្ពុជាមួយចំនួននៅតែមិនអាចបំពេញតម្រូវការរស់នៅប្រចាំថ្ងៃរបស់ខ្លួនបាន បើទោះបីជាជំនាន់របស់ខ្ញុំបានកន្លងហួសទៅហើយ? ហេតុអ្វីបានជាប្រជាជនកម្ពុជានៅតែប្រឈមមុខនឹងបញ្ហាកង្វះអាហារ និងមិនមានលទ្ធភាពទៅរៀន? តើកិច្ចព្រមព្រៀងសន្តិភាពបានជួយអ្វីខ្លះដល់ប្រជាជនកម្ពុជា?

ជាក់ស្តែង វិនាសកម្មដែលបង្កឡើងដោយសារសង្គ្រាម និងអំពើប្រល័យពូជសាសន៍មិនបានបញ្ចប់ទៅតាមកិច្ចព្រមព្រៀងបញ្ចប់ជម្លោះ កិច្ចព្រមព្រៀងសន្តិភាព និងការបោះឆ្នោតជាតិនោះទេ ។ ប្រសិនបើឫសគល់នៃបញ្ហាមិនបានដោះស្រាយ ផលប៉ះពាល់នឹងនៅតែបន្តជះឥទ្ធិពលមកដល់សព្វថ្ងៃ ។ កេរដំណែលនៃសង្គ្រាម និងអំពើប្រល័យពូជសាសន៍នៅតែបន្តមានទៅលើការរស់នៅរបស់ប្រជាជនសព្វថ្ងៃ ព្រមទាំងបានបង្កជាអំពើហិង្សាផ្សេងៗ រួមទាំងអំពើហិង្សាដោយផ្ទាល់ និងអំពើហិង្សាជាប្រព័ន្ធ ។ កេរដំណែល



ខេត រេប និង ឈីម សារ៉េត មុនពេលចាប់ខ្លួនឃុំឃាំង និងសម្លាប់ចោល

ទាំងអស់នោះ មិនត្រឹមតែប៉ះពាល់ទៅលើភាពថ្លៃថ្នូររបស់បុគ្គល និងសង្គមតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបន្តប៉ះពាល់ដល់ក្មេងជំនាន់ក្រោយពីមួយជំនាន់ទៅមួយជំនាន់ ។ បើទោះបីជាអំពើហិង្សាដោយផ្ទាល់បានសាបទៅវិញបន្តិចម្តងៗក៏ដោយ ក៏អំពើហិង្សាជាប្រព័ន្ធនៅតែបន្តចាក់ឫសយ៉ាងជ្រៅនៅក្នុងសង្គមកម្ពុជា ដែលពិបាកនឹងដោះស្រាយបាន ។ បច្ចុប្បន្ន យើងនៅតែបន្តរងគ្រោះអំពីភាពមិនស្មើគ្នាក្នុងការទទួលបានការអប់រំ ការជួញដូរមនុស្ស កម្មករកុមារ ទុព្វលភាពបរិស្ថាន និងវដ្តនៃភាពក្រីក្រដែលប្រជាជនកម្ពុជាភាគច្រើនជួបប្រទះ ។ បញ្ហាទាំងអស់នេះហាក់ដូចជាបានបាំងភ្នែករបស់យើងដែលធ្វើឲ្យយើងរកពុំឃើញនូវដំណោះស្រាយ ។ ប៉ុន្តែ យើងគួរចងចាំថា បញ្ហាទាំងអស់នេះមិនត្រឹមតែធ្វើឲ្យយើងមើលមិនឃើញនោះទេ ប៉ុន្តែថែមទាំងបានចាក់យ៉ាងជ្រៅនៅគ្រប់ស្រទាប់វណ្ណៈសង្គម តាំងពីបុគ្គលម្នាក់ៗរហូតដល់ស្ថាប័នទាំងមូល ។

យើងគ្រប់គ្នាដឹងហើយថា សង្គ្រាមមិនមានសេចក្តីមេត្តាករុណាចំពោះបុគ្គលណាម្នាក់ឡើយ ។ ផ្ទុយទៅវិញ សង្គ្រាមបានឆក់យកជីវិតមនុស្ស និងបានបន្សល់សេចក្តីឈឺចាប់ និងការព្រាត់ប្រាស់ ។ ជាងនេះទៅទៀត បើទោះបីជាសង្គ្រាមបានបញ្ចប់ ហើយកិច្ចព្រមព្រៀងសន្តិភាពបានបង្កើត ក៏នេះមិនបានបញ្ជាក់ថា យើងទទួលបានសន្តិភាពពិតប្រាកដនោះដែរ ។ ជាវិបាក អំពើហិង្សានៅតែបន្តកើតមាននៅក្នុងសង្គមរបស់យើង ។ យើងអាចនឹងមើលមិនឃើញនូវបញ្ហាទាំងនោះនឹងភ្នែកទទេ ប៉ុន្តែបញ្ហាទាំងនោះបានដក់ជាប់យ៉ាងជ្រៅនៅក្នុងការរស់នៅប្រចាំថ្ងៃរបស់យើង ។ អំពើហិង្សាជាប្រព័ន្ធដែលយើងជួបប្រទះ សព្វថ្ងៃគឺជាបញ្ហាប្រឈមពិតប្រាកដដែលបានកើតឡើងនៅពេលដែលប្រទេសយើងដែលមើលទៅហាក់ដូចជាកំពុងមានសន្តិភាព ។ ជាក់ស្តែង ការបញ្ចប់នៃជម្លោះប្រដាប់អាវុធ គឺជាការចាប់ផ្តើមនៃដំណើរដ៏វែងឆ្ងាយរបស់កម្ពុជាក្នុងការដោះស្រាយកេរដំណែលដែលជម្លោះប្រដាប់អាវុធបានបន្សល់ ។ ដូច្នេះ យើងម្នាក់ៗមានភារកិច្ចក្នុងការលុបបំបាត់នូវវដ្តនៃអំពើហិង្សានេះ ។ ដំណើរការនៃការដោះស្រាយបញ្ហាទាំងអស់នេះមិនអាចសម្រេចបានត្រឹមតែបុគ្គលក្នុងជំនាន់របស់ខ្ញុំនោះទេ ប៉ុន្តែទាមទារនូវការចូលរួមពីយុវជនជំនាន់ក្រោយផ្សេងៗ ទៀត ។

ខេត វេប បាននិយាយនៅក្នុងអវសានកថានៅក្នុងសៀវភៅរបស់គាត់ថា ប្រសិនបើអាច គាត់ចង់ជួបបុគ្គលដែលបានចាប់ខ្លួនគាត់ម្តងទៀតនៅក្នុងកាលៈទេសៈផ្សេង ។ បទពិសោធន៍របស់ខេត វេប បានកើតឡើងនៅក្នុងពេលសង្គ្រាម ។ ខេត វេប សង្ឃឹមថា នឹងបានជួបទាហានដែលបានចាប់ខ្លួនគាត់ម្តងទៀត ប្រសិនបើទាហានរូបនោះនៅរស់រានមានជីវិតបន្ទាប់ពីសង្គ្រាមបានបញ្ចប់ ។ ប្រសិនបើរឿងនេះអាចកើតឡើងពិតមែន នោះបំណងប្រាថ្នារបស់គាត់នឹងក្លាយទៅជាការពិត ។ ប៉ុន្តែ សម្រាប់ប្រទេសកម្ពុជាវិញ បើទោះបីជាសង្គ្រាម និងអំពើប្រល័យពូជសាសន៍បានបញ្ចប់អស់រយៈពេលជាង៣០ឆ្នាំ ព្រមទាំងកិច្ចព្រមព្រៀងសន្តិភាពបានបង្កើតអស់រយៈពេលជាង២៤ឆ្នាំយ៉ាងណាក៏ដោយ ក៏សន្តិភាពពិតប្រាកដហាក់ដូចជានៅឆ្ងាយសឹងនឹងមិនអាចសម្រេចបាន ។

**ស៊ុំ សាវីណា**

# ដំណឹងស្វែងរកប្អូនស្រី

ខ្ញុំបាទឈ្មោះ ហង់ ខេត ភេទប្រុស អាយុ៦០ឆ្នាំ បច្ចុប្បន្នរស់នៅភូមិជ្រៃ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ សូមប្រកាសស្វែងរក ហង់ សាម៉ូត ភេទស្រី ត្រូវជាប្អូនស្រីពៅ (បច្ចុប្បន្ន អាយុប្រហែល៥៤-៥៥ឆ្នាំ) មានស្រុកកំណើតនៅភូមិត្រពាំងអណ្តើក ឃុំបឹងស្រងែ ស្រុកត្រាំកក់ ខេត្តតាកែវ ។ កាលពីសម័យខ្មែរក្រហម សាម៉ូត ធ្វើជាកងនារីតំបន់ ស្រុកត្រាំកក់ មានឪពុកឈ្មោះ ជ័យ ឃុន និងម្តាយ ឈឹម ណេង ។ មានបងប្អូនបង្កើត៧នាក់ (ប្រុស២ ស្រី៥នាក់) ។

បងប្អូនណាបានឮសូមទាក់ទងមេភូមិជ្រៃ ទូរស័ព្ទលេខ ០៩៧ ៣ ១៧៤ ៩៦៧ ឬ ទំនាក់ទំនងមកមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦, មហាវិថីព្រះសីហនុ, រាជធានី ភ្នំពេញ ឬ តាមរយៈទូរស័ព្ទ ០២៣ ២១១ ៨៧៥ ។

***សូមអរគុណ!***

# និស្សិតខ្មែររៀននៅសកលវិទ្យាល័យ អុកស៍ហ្វើដ តាមរយៈការសិក្សារៀនសូត្រពីរបបខ្មែរក្រហម

កញ្ញា ជា ផល្លា គឺជាយុវតីខ្មែរតែម្នាក់គត់ដែលកំពុងសិក្សាថ្នាក់អនុបណ្ឌិតផ្នែកគោលនយោបាយសាធារណៈ នៅសកលវិទ្យាល័យ អុកស៍ហ្វើដ (University of Oxford) ចក្រភពអង់គ្លេស នាពេលបច្ចុប្បន្ន ក្រោមជំនួយអាហារូបករណ៍ពីមូលនិធិ ចាឌីន (Jardine Foundation) ជាមូលនិធិដ៏ធំមួយគ្រប់គ្រងជំនួញ និងមានសាខាជាច្រើនប្រទេស រួមទាំងប្រទេសកម្ពុជាផង ។ នៅចក្រភពអង់គ្លេស មូលនិធិ ចាឌីន ផ្តល់អាហាររូបករណ៍ដល់និស្សិតដែលមានបំណងសិក្សានៅសកលវិទ្យាល័យចំនួនពីរតែប៉ុណ្ណោះគឺ សកលវិទ្យាល័យ អុកស៍ហ្វើដ និងសកលវិទ្យាល័យ ខេមប្រ៊ីច ។ ផល្លា គឺជានិស្សិតខ្មែរដំបូងគេបង្អស់ដែលទទួលបានអាហាររូបករណ៍នេះ និងជានិស្សិតស្រីដំបូងគេមកពីប្រទេសកម្ពុជា ឆ្លងកាត់ការបណ្តុះបណ្តាលពីប្រព័ន្ធអប់រំក្នុងស្រុក ដែលមានសមត្ថភាពចូលមកសិក្សានៅសកលវិទ្យាល័យ អុកស៍ហ្វើដ ជាសកលវិទ្យាល័យដ៏ធំមួយនៅលើពិភពលោក ។ ជានិស្សិតម្នាក់ក្នុងចំណោមនិស្សិត១១៩នាក់ មកពី៥៥ប្រទេស ដែលកំពុងសិក្សានៅសាលា ប្លាវ៉ាតនីក នៃរដ្ឋាភិបាល (Blavatnik School of Government) នៃសកលវិទ្យាល័យ អុកស៍ហ្វើដ ផល្លា មានទំនុកចិត្តខ្លួនឯង និងខិតខំប្រឹងប្រែងរៀនសូត្រដើម្បីជាប្រយោជន៍ និងលើកស្ទួយដល់កិត្តិយសប្រទេសកម្ពុជា និងដើម្បីលើកទឹកចិត្តដល់យុវតីខ្មែរទាំងឡាយឲ្យធ្វើជាម្ចាស់លើខ្លួនឯងក្នុងការធ្វើដំណើរវែងឆ្ងាយទៅមុខដើម្បីយកចំណេះដឹងមកជួយប្រទេសជាតិវិញ ។

ពេលសួរថា តើហេតុអ្វីបានចង់មកសិក្សានៅសកលវិទ្យាល័យ អុកស៍ហ្វើដ ផល្លា បាននិយាយថា គាត់ធ្លាប់ស្រមើស្រមៃចង់ស្គាល់ និងមករៀននៅសកលវិទ្យាល័យនេះតាំងពីអាយុ១២-


កញ្ញា ជា ផល្លា ទទួលអាហារូបករណ៍ពីមូលនិធិ ចាឌីន (Jardine Foundation) ទៅសិក្សានៅសាកលវិទ្យាល័យ អុកស៍ហ្វើដ ចក្រភពអង់គ្លេស

១៣ឆ្នាំមកម៉្លេះ ព្រោះពេលនោះ គាត់បានឃើញវចនានុក្រមភាសាអង់គ្លេស អកស៍ហ្វ៊ដ (Oxford English Dictionary) ហើយគិតថាសកលវិទ្យាល័យនេះមានគុណភាពខ្ពស់ខាងការបណ្ដុះបណ្ដាលភាសាអង់គ្លេស ។ ផល្លា បន្តទៀតថា កាលនោះគាត់មិនដឹងថាសកលវិទ្យាល័យ អកស៍ហ្វ៊ដ នោះមានរូបរាងយ៉ាងដូចម្ដេចទេ តែគាត់ស្រមៃឃើញថា អកស៍ហ្វ៊ដ គឺជាសកលវិទ្យាល័យដ៏មានវ័យចំណាស់មួយលើលោក ហើយគាត់តែងតែប៉ងប្រាថ្នាថា ថ្ងៃណាមួយ និងបានមកទស្សនាឬមករៀននៅសាលានេះជាមិនខាន ។ ផល្លា បានពោលថា «ពេលខ្ញុំនឹកឃើញដល់ឈ្មោះសកលវិទ្យាល័យ អកស៍ហ្វ៊ដ ខ្ញុំតែងតែគិតថា សកលវិទ្យាល័យនេះគឺជាសាលាចាស់មានកំពូលស្រួចៗ ធ្វើឡើងពីឥដ្ឋ និងថ្ម ស្រដៀងគ្នាទៅនឹងវិហារគ្រឹស្ដសាសនា មានក្បូរក្បាច់រចនារស់រវើកតាមបែបសិល្បៈបស្ចិមប្រទេស» ។

សេចក្ដីប៉ងប្រាថ្នាបានចេញជារូបរាងឡើងនៅខែឧសភា ឆ្នាំ២០១៥ នៅពេលដែល ផល្លា បានឈានជើងលើទឹកដីសកលវិទ្យាល័យ អកស៍ហ្វ៊ដ នៅពេលដែលគាត់ត្រូវបានអញ្ជើញដោយមូលនិធិ ចាឌីន ដើម្បីទៅទស្សនាចក្រភពអង់គ្លេស ។ នៅពេលនោះដែរ ផល្លា ត្រូវបានជូនដំណឹងថា ទទួលបានអាហាររូបករណ៍ពីមូលនិធិ ចាឌីន ដើម្បីសិក្សានៅសកលវិទ្យាល័យ អកហ្វ៊ដ ហើយក្រោយពីទទួលបានដំណឹងនេះភ្លាមក៏សម្រេចចិត្តធ្វើដំណើរទៅទីនោះ ។ ពេលជិះរថភ្លើងពីទីក្រុងឡុងដ៍ ទៅទីក្រុងអកស៍ហ្វ៊ដ ផល្លា មើលឃើញទេសភាពស្រស់ត្រកាលនារដូវផ្ការីក និងនឹកភ្នកដល់រូបរាងសកលវិទ្យាល័យ អកស៍ហ្វ៊ដ ដូចដែលគាត់ធ្លាប់ស្រមើស្រមៃកាលពីគាត់នៅក្មេងថា សកលវិទ្យាល័យនេះលម្អទៅដោយសួនច្បារចម្រុះពណ៌ និងរុក្ខជាតិពណ៌បៃតងខ្ចី ព័ទ្ធជុំវិញដោយវាលស្មៅខៀវស្រងាត់ ។ ផល្លា បានរៀបរាប់ថា នៅពេលខ្ញុំទៅឃើញអកស៍ហ្វ៊ដដំបូង ខ្ញុំមានអារម្មណ៍ថា ក្ដីសុបិនរបស់ខ្ញុំក្លាយជាការពិត ព្រោះខ្ញុំធ្លាប់ចង់មករៀនភាសាអង់គ្លេសនៅទីនេះយូរមកហើយ ។ អកស៍ហ្វ៊ដ គឺជាទីក្រុងបុរាណមួយ សំបូរអគារចាស់ៗ និងផ្កាចម្រុះពណ៌ដូចខ្ញុំធ្លាប់ស្រមៃ ។ ក្រោយមក គ្រូរបស់ខ្ញុំបានប្រាប់ខ្ញុំថា «ខ្ញុំនឹងទៅរៀនមហាវិទ្យាល័យមួយក្នុងសកលវិទ្យាល័យ អកស៍ហ្វ៊ដ ដែលសាងសង់តាំងពីសតវត្សរ៍ទី១៨មកម៉្លេះ ហើយសាលានេះទើបតែប្រារព្ធខួបគម្រប់អាយុ៧០០ឆ្នាំ កាលពីឆ្នាំមុននេះតែប៉ុណ្ណោះ» ។

ក្រឡេកមើលស្ថានភាពនៅប្រទេសកម្ពុជាឯណេះវិញ ផល្លា មិនខុសពីយុវជន-យុវតីខ្មែរឯទៀតប៉ុន្មានទេដែលឆ្លងកាត់ការតស៊ូក្នុងការរៀនសូត្រខណៈពេលដែលប្រទេសជាតិទើបតែរួចផុតពីរបបខ្មែរក្រហម ។ មានឪពុកម្ដាយជាប់ខ្សែស្រឡាយចិន ឆ្លងកាត់របបខ្មែរក្រហម និងចាប់កំណើតឡើងនៅទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៨៧ ផល្លា បានចូលរៀននៅសាលាបាក់ទូកហើយប្រលងយកសញ្ញាបត្រទុតិយភូមិ (បាក់ឌុប) ក្នុងឆ្នាំ២០០៦ ។ ដោយសារតែទទួលបានលទ្ធផលទិន្នេសល្អ ផល្លា ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាផ្ដល់អាហាររូបករណ៍ឲ្យចូលសិក្សានៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកសេដ្ឋកិច្ចព័ត៌មាន ។ នៅចុងឆ្នាំ២០០៧ នៅពេលដែលគាត់ជានិស្សិតឆ្នាំទីមួយ ផល្លា បានចូលធ្វើការជាអ្នកស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីស្វែងរកបទពិសោធន៍ការងារ និងដើម្បីរៀនសូត្រពីប្រវត្តិសាស្ត្រខ្មែរក្រហម ។ ប្រាំមួយខែក្រោយមក ផល្លា ត្រូវបានផ្ដល់ការងារពាក់កណ្ដាលម៉ោងជាអ្នកបកប្រែភាសាអង់គ្លេស-ខ្មែរ និងជាអ្នកសរសេរទស្សនាវដ្ដីស្វែងរកការពិត ។

ពេលកំពុងបម្រើការងារជាអ្នកបកប្រែ ផល្លា បានរៀនសូត្រយ៉ាងច្រើនតាមរយៈឯកសារប្រវត្តិសាស្ត្រ ការរំលោភសិទ្ធិមនុស្ស និងអត្ថបទពិភាក្សានានាស្ដីពីការកាត់ទោសមេដឹកនាំខ្មែរក្រហម និងការកាត់ទោសបទឧក្រិដ្ឋធំៗផ្សេងៗ ។ ផល្លា បានរៀបរាប់ថា «ខ្ញុំរៀនសូត្របានច្រើនទាក់ទងទៅនឹងរបបខ្មែរក្រហមតាមរយៈការបកប្រែឯកសារ កាលពីមុនខ្ញុំធ្លាប់តែឮពីឪពុកម្ដាយប្រាប់តែប៉ុណ្ណោះ ។ កាលនោះ ខ្ញុំមានចិត្តរំភើបនិងមានការតាំងចិត្តខ្ពស់ចំពោះការងារ ដោយបានបកប្រែទាំងយប់ទាំងថ្ងៃព្រោះតែការចង់ដឹងចង់ឮពីរឿងរ៉ាវទាក់ទងនិងខ្មែរក្រហម» ។ ពេលជាមួយគ្នានោះដែរ ផល្លា គិតឃើញថា គាត់ចង់ឲ្យក្មេងជំនាន់ក្រោយរៀនសូត្រពីប្រវត្តិសាស្ត្រខ្មែរក្រហមឲ្យបានច្រើនដើម្បីបន្ថែមទៅនឹងការស្ដាប់រឿងរ៉ាវប្រវត្តិសាស្ត្រនេះពីឪពុកម្ដាយ ។

ក្នុងខែមិថុនា ឆ្នាំ២០១១ ផល្លា ទទួលបានអាហាររូបករណ៍ទៅសិក្សាថ្នាក់អនុបណ្ឌិតផ្នែកសិក្សាពីសហគមន៍អឺរ៉ុប នៅសកល

វិទ្យាល័យជូឡាឡុងកន ប្រទេសថៃ ។ ក្រោយពីបញ្ចប់ការសិក្សាក្នុងខែមិថុនា ឆ្នាំ២០១២ ផល្លា បានត្រឡប់មកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាវិញដោយធ្វើការជាអ្នកមើលការខុសត្រូវគម្រោងតាមដានសាលាក្ដីខ្មែរក្រហម ដោយបានធ្វើកិច្ចការជាច្រើនទាក់ទងនិងការលើកកម្ពស់ការយល់ដឹងក្នុងសហគមន៍ទាក់ទងនឹងការរំលោភបំពានសិទ្ធិមនុស្សកាលពីអតីតកាល ប្រវត្តិសាស្ត្រខ្មែរក្រហម និងច្បាប់អន្តរជាតិនានាទាក់ទងនឹងការកាត់ទោសបទឧក្រិដ្ឋក្នុងពិភពលោក តាមរយៈការចុះទៅមហាវិទ្យាល័យនានាទូទាំងប្រទេសដើម្បីធ្វើបទបង្ហាញដល់និស្សិត ។ ផល្លា បានរៀបរាប់ថា «ខ្ញុំយល់ថាការស្ដាប់រឿងរ៉ាវប្រវត្តិខ្មែរក្រហមតាមរយៈឪពុកម្ដាយមិនទាន់គ្រប់គ្រាន់នៅឡើយទេ ហើយក៏មាននិស្សិតខ្លះនៅតែមិនជឿថាមានរបបខ្មែរក្រហមដែរ ដូច្នេះ យើងជាមនុស្សជំនាន់ក្រោយត្រូវអាន និងស្រាវជ្រាវបន្ថែមទៀតពីប្រវត្តិសាស្ត្រដ៏ឈឺចាប់របស់ប្រទេសយើង» ។

គម្រោងរបស់ ផល្លា គឺផ្ដល់ឱកាសដល់និស្សិតខ្មែរដែលជាអនាគតអ្នកដឹកនាំប្រទេសឲ្យយល់ដឹងពីសារៈប្រយោជន៍នៃប្រវត្តិសាស្ត្រ និងសិទ្ធិមនុស្ស ។ ផល្លា បានបន្ថែមទៀតថា «គ្មានមនុស្សណាម្នាក់អាចគេចផុតពីការចង់ចេះចង់ដឹងពីប្រវត្តិសាស្ត្ររបស់ប្រទេសខ្លួនបានទេ ។ បើយើងមិនរៀនពីប្រវត្តិសាស្ត្រ នោះអនាគតរបស់យើងនឹងដើរជាន់លើប្រវត្តិសាស្ត្រនោះដាក់ជាមិនខាន» ។

ក្រៅពីកិច្ចការបង្រៀនដល់និស្សិតជំនាន់ក្រោយពីប្រវត្តិសាស្ត្រខ្មែរក្រហម ផល្លា មានការទទួលខុសត្រូវមួយទៀតគឺត្រួតពិនិត្យ និងស្វែងរកថវិកាពីម្ចាស់ជំនួយដើម្បីយកមកទ្រទ្រង់កិច្ចប្រតិបត្តិការក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជាទាំងមូល ដែលជាស្ថាប័នស្រាវជ្រាវនាំមុខគេស្ដីពីប្រវត្តិសាស្ត្រខ្មែរក្រហម ដើម្បីលើកកម្ពស់ការចងចាំពីប្រវត្តិសាស្ត្រ និងស្វែងរកយុត្តិធម៌សម្រាប់មនុស្សជាតិ ។

ក្នុងខែកក្កដា ឆ្នាំ២០១៥ ផល្លា បានចាកចេញពីប្រទេសកម្ពុជាទៅសកលវិទ្យាល័យ អកស៍ហ្វឺដ ដើម្បីចូលរៀនថ្នាក់អនុបណ្ឌិតផ្នែកគោលនយោបាយសាធារណៈ ដោយផ្ដោតទៅលើការអភិវឌ្ឍក្នុងការគិត វិភាគ និងការត្រិះរិះពិចារណាដើម្បីយល់ដឹងអំពីផលលំបាកនៃគោលនយោបាយសាធារណៈ និងការអនុវត្ត និងដើម្បីរកមើលពីប្រសិទ្ធភាពពីការអនុវត្តគោលនយោបាយ ។ ផល្លា បានរៀបរាប់ថា «សាលានេះមានកម្មវិធីដែលត្រូវរៀនច្រើនណាស់ ហើយក៏មានកម្មវិធីធ្វើបទបង្ហាញ និងការពិភាក្សាដេញដោលច្រើនដែរ បន្ថែមទៅនឹងកម្មវិធីពេញម៉ោងជារៀងរាល់ថ្ងៃ» ។

ជារៀងរាល់ថ្ងៃ ក្រោយពីស្រស់ស្រូបអាហារពេលព្រឹកដែលភាគច្រើនជានំប៉័ង និងដំណាប់ផ្លែឈើ ផល្លា ត្រូវដើររយៈពេលប្រមាណជាកន្លះម៉ោងដើម្បីធ្វើដំណើរពីផ្ទះទៅសាលារៀន ហើយត្រឡប់មកផ្ទះវិញនៅពេលល្ងាច ។ ពេលសួរថា តើការរស់នៅ និងការសិក្សានៅចក្រភពអង់គ្លេស ជាពិសេសនៅសកលវិទ្យាល័យ អកស៍ហ្វ៊ដ មានសភាពយ៉ាងដូចម្ដេច ផល្លា បានឆ្លើយថា ក្រៅពីក្ដីស្រលាញ់ផ្ទាល់ខ្លួនចំពោះរាជវង្សានុវង្សរបស់ចក្រភពអង់គ្លេស ជាពិសេសព្រះមហាក្សត្រិយ អេលីហ្សាប៉ែត អង់គ្លេសជាប្រទេសមួយដែលបានផ្ដល់នូវភាពងាយស្រួលខ្លាំងដល់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាជន ដោយហាងលក់ទំនិញ និងម្ហូបអាហារសុទ្ធតែអាចរកបាននៅក្បែរផ្ទះ លើសពីនេះទៅទៀត ការធ្វើដំណើរពីតំបន់មួយទៅតំបន់មួយមានភាពងាយស្រួលច្រើន ដោយសារតែមានសេវាកម្មសាធារណៈល្អ និងមានសុវត្ថិភាពខ្ពស់ក្នុងការរស់នៅការធ្វើដំណើរ ។

រៀននៅសកលវិទ្យាល័យដ៏ធំមួយក្នុងពិភពលោក ផល្លា បាននិយាយថា អកស៍ហ្វ៊ដ មានធនធានច្រើនដែលផ្ដល់អំណោយផលល្អដល់ការស្រាវជ្រាវរបស់និស្សិតព្រោះទីនេះមានបណ្ណាល័យច្រើន និងមានអ្នកជំនាញច្រើនសម្រាប់ពិគ្រោះយោបល់ ។ ផល្លា បានបន្ថែមថា «ខ្ញុំយល់ថា អកស៍ហ្វ៊ដ មានសៀវភៅ និងឯកសារស្ទើរគ្រប់ប្រភេទដែលនិស្សិតម្នាក់ៗចង់បាន» ។

ទីបញ្ចប់ នៅពេលសួរថាតើពេលត្រឡប់ទៅប្រទេសកម្ពុជាវិញគាត់មានបំណងនិងធ្វើអ្វីទៀតដើម្បីជួយលើកកម្ពស់ការអប់រំក្នុងប្រទេសកម្ពុជា ផល្លា បានឆ្លើយថា «ខ្ញុំចង់រួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័នឯកជនក្នុងការរៀបចំគោលនយោបាយសម្រាប់ប្រទេសជាតិ និងស្វែងរកវិធីសាស្ត្រដើម្បីអនុវត្តគោលនយោបាយនោះឲ្យមានប្រសិទ្ធភាព ខណៈពេលដែលអាស៊ានក្លាយជាសហគមន៍តែមួយនាពេលឆាប់ៗខាងមុខនេះ

**ញាណ សុជាតិ**

# រសាត់តាមខ្យល់

**(តពីលេខមុន)**



មកដល់ត្រើយម្ខាងពាមជីកងរថយន្ត ហេង.អ៊ឹម.សេ របស់កងយោធាប្រមាណជិតម្ភៃគ្រឿងចតតម្រៀបជាជួរបន្តកន្ទុយគ្នាលើផ្លូវជាតិរង់ចាំជាស្រេច ដែលមានពួកមិត្តយោធាជាច្រើននាក់ប្រដាប់ដោយអាវុធ កំពុងតែឈរដដែកផ្តិគ្នាជាក្រុមៗ ដែលពេលនោះហាក់ដូចជាធ្វើឲ្យខ្ញុំនឹកឃើញដល់ទិដ្ឋភាពពេលជម្លៀសចេញពីភ្នំពេញជាថ្មីម្តងទៀត ។

ខ្ញុំឃើញបងប្អូនអ្នកជម្លៀសរាប់សិបគ្រួសារដែលបានឆ្លងមកដល់ត្រើយម្ខាងនេះមុនខ្ញុំមិនទាន់មានគ្រួសារណាមួយត្រូវបានពួកមិត្តហៅឲ្យឡើងឡាននៅឡើយទេ នៅជ្រកក្រោមម្លប់ឈើ សំណាក់តាមចិញ្ចើមផ្លូវទាំងសងខាង ។

រហូតដល់ពេលថ្ងៃជិតត្រង់ ទើបមានពួកមិត្តដើរមកប្រាប់ឲ្យពួកយើងដណ្តាំបាយថ្ងៃត្រង់ហូបឲ្យហើយទៅ ប្រហែលជាដល់ថ្ងៃរសៀលទើបបានចេញដំណើរ ។ ខ្ញុំចេញដើរទៅរកខស ពូជន រកដុំថ្មមកកល់ធ្វើជាជើងក្រាន ទាំងអស់គ្នាញាប់ដៃញាប់ជើងបង្កាត់ភ្លើងដណ្តាំស្លឡើងហុយទ្រលោមមួយរំពេច រួចនាំគ្នាប្រញាប់ប្រញាល់ហូបសឹងតែមិនត្រង់មាត់ ហើយរៀបចំអីវ៉ាន់សាជាថ្មី ត្រៀមខ្លួនរង់ចាំបញ្ជាពីពួកមិត្ត ។

រសៀលថ្ងៃនេះ ផ្ទៃមេឃប្រែជាងងឹត មានពពកខ្មៅដេរដាសបន្តិចក្រោយមកក៏ស្រាប់តែមានភ្លៀងធ្លាក់មកយ៉ាងខ្លាំង ម្នាក់ៗនាំគ្នាជញ្ជូនអីវ៉ាន់រត់ប្រសាចរកកន្លែងជ្រករៀងៗខ្លួន ។ ក្រោយពេលភ្លៀងរាំង ខ្ញុំឃើញមិត្តយោធាម្នាក់ដើរពីឡានមួយទៅឡានមួយហាក់ដូចជានាំដំណឹងអ្វីមួយប្រាប់តៗគ្នា ហើយនៅពេលដែលមិត្តយោធានោះដើរមកក្បែរ ពូជន បានសួរទៅសួរ មិត្តនោះបានតបមកវិញថា រង់ចាំបញ្ជាពីអង្គការថ្នាក់លើ មិនទាន់ដឹងថាត្រូវចេញដំណើរនៅពេលថ្មើណាទេ ព្រោះផែនការរបស់អង្គការមិនទៀងទាត់ ពេលណាអង្គការបញ្ជាឲ្យចេញគឺចេញភ្លាម ។

ពេញមួយរសៀលថ្ងៃនោះ ម្នាក់ៗរង់ចាំផែនការចេញដំណើររបស់អង្គការដោយក្តីអន្ទះអន្ទែងបំផុត ។ ថ្ងៃកាន់តែទាបណាស់ទៅហើយ នៅតែបន្តិចទៀតទេ ស្បែងងឹងនៃរាត្រីកាលនឹងចូលមកដល់តែនៅមិនទាន់មានផែនការចេញដំណើរនៅឡើយ ។

ដោយតប់ប្រមល់ក្នុងចិត្តខ្លាំងពេក ពូជន ដើរចុះដើរឡើង ជួនគាត់ដើរហួសទៅរហូតដល់មាត់ទន្លេឈរសម្លឹងមើលទៅត្រើយម្ខាង ពេលដែលគាត់ត្រឡប់មកវិញ គាត់បាននិយាយរអ៊ូតិចៗមកកាន់ខ្ញុំថា ផែនការរបស់អង្គការមិនខុសពីផែនស្ករទេ ។

រហូតមកដល់ពេលព្រលប់ មើលគ្នាសឹងតែពុំស្គាល់ ទើបឃើញមានមិត្តយោធាម្នាក់ដើរមកប្រាប់ឲ្យបងប្អូនពុកម៉ែដណ្តាំបាយហូបពេលល្ងាចឲ្យហើយទៅ ព្រោះមិនទាន់មានបញ្ជាពីអង្គការឲ្យចេញដំណើរនៅឡើយទេ ។ ល្ងាចនោះយើងនាំគ្នាដណ្តាំស្ល រួចនាំគ្នាហូបបាយទាំងងងឹតពពើម យូរៗម្តងឃើញពន្លឺភ្លើងពិលរបស់ពួកមិត្តបាំងឆ្វាត់រកគ្នាពីឡានមួយទៅឡានមួយ ។

ប្រមាណជិតពីរម៉ោងក្រោយមក ទើបពួកមិត្តយោធាបានមកហៅឈ្មោះតាមគ្រួសារឲ្យឡើងឡានបន្តបន្ទាប់គ្នា ។ ឡាននីមួយៗដែលផ្ទុកទាំងមនុស្ស និងអីវ៉ាន់ផង ខ្លះអង្គុយខ្លះឈរយ៉ាងប្រជ្រៀតគ្នា បានរហូតជិតដប់គ្រួសារ ហើយមុនពេលចេញដំណើរពួកមិត្តយោធាបានមកទម្លាក់របាំងក្រណាត់ពីក្រោយឡានបិទយ៉ាងជិត

ឡើងងងឹតស្លុប ។ រថយន្តចាប់ផ្ដើមចេញដំណើរបន្តបន្ទាប់គ្នាដោយបើកក្នុងល្បឿនយឺតៗ តាមបណ្ដោយផ្លូវដែលមានស្ថានភាពរដិបរដុបរលាក់យ៉ាងខ្លាំង ពីពាមជីកងឆ្ពោះទៅព្រៃទទឹង ។

មកដល់ព្រៃទទឹងពេលដែលរថយន្តបន្ថយល្បឿនបត់ឆ្វេងឆ្ពោះទៅស្គន់ ខ្ញុំឃើញ ពូផន លួចបង្ហើបរបាំងក្រណាត់មើលទៅក្រៅ ។ ក្នុងកំណាត់ផ្លូវពីព្រៃទទឹងទៅស្គន់ ស្រាប់តែមានធ្លាក់ភ្លៀងមួយមេយ៉ាងធំ ស្នូរផ្គរលាន់ឮយ៉ាងទ្រហឹង ផ្លេកបន្ទោរភ្លឺរន្ទាល ខ្យល់បក់បោកមកយ៉ាងខ្លាំងបក់នាំដំណក់ទឹកភ្លៀងមកសាចប៉ះនឹងរបាំងក្រណាត់ឮសូរប្រាវៗ ទាំងអស់គ្នាក្នុងរថយន្ត គ្មានអ្នកណាម្នាក់បានដឹងថា យើងកំពុងតែធ្វើដំណើរទៅកាន់ទីណាឡើយ ។ ពេលដែលរថយន្តបានបើកមកដល់ត្រង់ចំណុចមួយ ខ្ញុំបានឮសូរ ពូផន ខ្សឹបប្រាប់មីងណារុង ថា យើងកំពុងតែធ្វើដំណើរលើផ្លូវជាតិលេខប្រាំមួយមកដល់ម្ដុំតាំងគោក ។

សម្រឹបភ្លៀងធ្លាក់ឮសូរកាន់តែខ្សោយទៅៗ រថយន្តលូនទៅមុខឥតឈប់ឈរ ខ្ញុំលួចសម្លឹងមើលទៅក្រៅ កាត់ស្បែងងងឹតនៃរាត្រីកាលក្នុងលំហមេឃដ៏ធំធេង ខ្ញុំឃើញដួងខែមូលក្រឡង់រះសែនឆ្ងាយខ្ពស់សន្ធឹមបោលពន្លឺព្រឿងៗយ៉ាងស្រទន់មកលើរុក្ខជាតិតូចធំដុះអមប្រឡាយទឹកទាំងសងខាងថ្នល់ ពេលខ្លះ ខ្ញុំបានឃើញព្រៃរំចេកដុះយ៉ាងក្រាស់ឈរជាជួរ ដែលមានស្លឹកពណ៌បៃតងខ្ចីសើមជោគដោយដំណក់ទឹកភ្លៀង ។

ជាងមួយម៉ោងក្រោយមក ពេលរថយន្តបន្ថយល្បឿនបើកកាត់ស្ពានឈើមួយ ពូផន បានលួចបង្ហើបរបាំងមើលចេញទៅក្រៅជាថ្មីម្ដងទៀត ។ ឆ្លងផុតស្ពានឈើនោះបន្តិចមក ពូផន ស្គាល់ភូមិសាស្ត្រម្ដុំនោះយ៉ាងច្បាស់លាស់ ថ្វីត្បិតតែមេឃងងឹងបន្តិចមែន ពូផន បានប្រាប់បងប្អូនដែលរួមដំណើរជាមួយគ្នាថា យើងកំពុងតែបានមកដល់កំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ ។

ក្នុងល្បឿនយ៉ាងយឺតៗ រថយន្តបត់ស្ដាំចុះពីថ្នល់ជាតិបើកតាមផ្លូវលំមួយកំណាត់ប្រមាណពីររយម៉ែត្រ ហើយឈប់ស្ងៀមនៅមួយកន្លែង ។ យប់កាន់តែជ្រៅណាស់ទៅហើយ ពួកមិត្តយោធាបានមកស្រាយបើករបាំងពីក្រោយ ហើយបានប្រាប់ឲ្យពួកយើងជញ្ជូនអីវ៉ាន់ចុះពីលើរថយន្ត ។ ពេលនោះទើបពួកយើងបានដឹងថា រថយន្តកំពុងតែឈប់សំចតនៅក្នុងបរិវេណវត្តមួយ ។ បន្តិចក្រោយមក មានឡានដឹកអ្នកជម្លៀសពីរគ្រឿងផ្សេងទៀត ក៏បានមកដល់ទីធ្លាវត្តនោះដែរ ។

ក្នុងចំណោមប្រជាជនទាំងអស់ប្រមាណសាមសិបគ្រួសារដែលបានមកដល់ទីនេះ គ្មានអ្នកណាម្នាក់បានដឹងថា តើក្រុមគ្រួសារញាតិមិត្តខ្លួនដែលជិះរថយន្តផ្សេងទៀតបានទៅដល់ទីណាឡើយ ហើយមុនពេលដែលពួកមិត្តយោធាបើកឡានត្រឡប់ទៅវិញ ពួកមិត្តបានប្រាប់ឲ្យពួកយើងរកកន្លែងសម្រាករៀងៗខ្លួន រង់ចាំដល់ព្រឹកថ្ងៃស្អែក រដ្ឋអំណាចតំណាងអង្គការភូមិឃុំនឹងមកទទួលបងប្អូនឲ្យទៅរស់នៅតាមភូមិ សូមបងប្អូនកុំព្រួយបារម្ភឲ្យសោះ ។

យប់នោះ បងប្អូនដែលបានរួមដំណើរមកជាមួយខ្ញុំ និង ពូផន ជិតដប់គ្រួសារ បាននាំគ្នាមកសម្រាកលើកុដិឈើតូចមួយនៅប្របមាត់ស្ទឹង ។ ពេញមួយយប់នោះខ្ញុំដេកមិនលក់ទេ ក្រៅពីសម្ងំស្ដាប់ស្នូរទឹកហូរ ខ្ញុំនៅបានឮសូរសម្រឹបមាត់ត្រីមិនដាច់ទល់ភ្លឺ ។ ពូផន បានប្រាប់ខ្ញុំថា យើងកំពុងតែដេកក្នុងវត្តកំពង់ថ្ម ហើយស្ទឹងនៅពីក្រោយកុដិឈើនេះគឺស្ទឹងជីនិត ។ ដោយចម្ងល់ ខ្ញុំក៏បានសួរទៅគាត់វិញថា ម៉េចបានជាពូស្គាល់ភូមិសាស្ត្រម្ដុំអស់នេះបានច្បាស់ម្ល៉េះ? ពូផន បានខ្សិបតិចៗតបមកខ្ញុំវិញថា ប្រតិបត្តិការសឹកចេនឡាទីពីរ សមរភូមិស្គន់ តាំងគោក បារាយណ៍ កំពង់ថ្ម សន្ទុក រហូតដល់កំពង់ធំ សុទ្ធតែជាសមរភូមិដែលក្ដៅបំផុត ។ នៅសមរភូមិបារាយណ៍ព្រំប្រទល់ជាប់នឹងស្រុកសន្ទុកនេះ គាត់ធ្លាប់បានពើបប្រយុទ្ធបាញ់ប្រហារគ្នាជាមួយកងទ័ពខ្មែរក្រហមយ៉ាងឆ្ងាញ់ដៃ ។

ស្អែកឡើងតាំងពីព្រឹកព្រហាម ខ្ញុំបានដើរមើលជុំវិញបរិវេណវត្តកំពង់ថ្ម ដែលមានព្រះវិហារធំខ្ពស់ដល់ទៅពីរជាន់រំលេចដោយក្បាច់រចនាយ៉ាងល្អប្រណិត ។ នៅក្នុងព្រះវិហារមានព្រះអង្គមួយយ៉ាងធំខ្ពស់ គង់ភ្នែន ព្រះកេសទល់ដល់ដំបូល មានព្រះភក្ត្រយ៉ាងស្រស់ញញឹម ហើយដែលនៅក្បែរៗនោះ មានព្រះពុទ្ធបដិមាតូចធំជាច្រើនអង្គដួលរលំរណ្ដូករណែល ។

ខ្ញុំពុំមានប្រទះភ្នែកឃើញព្រះសង្ឃមួយអង្គណាឡើយ ក្នុងចំណោមកុដិតូចធំ មានកុដិជាច្រើនត្រូវបានកំពុងតែរុះរើ ។ នៅនឹងជញ្ជាំងព្រះវិហារមួយជ្រុងធំ ខ្ញុំឃើញនៅមានស្នាមផ្សែងឆេះខ្លោចរោលរាលដេរដាស តាំងពីខឿនវិហាររហូតដល់ដំបូល ដែលទំនងក្នុងពេលសង្គ្រាមរងការទម្លាក់គ្រាប់បែករបស់កងទ័ពអាកាសនៃ

រដ្ឋាភិបាល លន់ នល់ ។

ខ្ញុំឈរទ្រឹងនៅនឹងជណ្តើរដាន់ទីមួយខាងកើតព្រះវិហារ ឈរមើលទេសភាពដ៏ស្រស់ត្រកាលរំលេចដោយដើមត្នោតខ្ពស់ៗដុះជុំគ្នាយ៉ាងច្រូងច្រាង ដែលនៅឆ្ងាយពីទីនេះបន្តិច មានដើមគគីរជាច្រើនដើមជាំតម្រៀបគ្នាជាជួរ ចោលម្លប់យ៉ាងត្រឈឹងត្រឈៃ ។

អាកាសធាតុពេលព្រឹកព្រលឹម នៅត្រជាក់ស្រិបស្រិកឈើនិងវាលស្មៅជុំវិញនៅសើមជោគដោយទឹកសន្សើមនាពេលរាត្រី ហើយពេលដែលខ្ញុំក្រឡេកភ្នែកទៅប្រទះឃើញបងប្រុសម្នាក់កំពុងតែតោងបង្អោងឡើងត្នោតបានដល់ពាក់កណ្តាលដើមលាយឡំនឹងស្នូរបំពង់ទឹកត្នោតទង្គិចរណ្តំគ្នាឮសូរដូចភ្លេងយ៉ាងពិរោះ ពេលនោះខ្ញុំហាក់ដូចជាបានទទួលអារម្មណ៍យ៉ាងរំភើបរីករាយ ។ មិនបង្អង់ឲ្យខាតពេលខ្ញុំក៏ប្រញាប់ដើរត្រឡប់មករកអ្នកម៉ែវិញ រួចយកថ្នាំជក់ចងនឹងជាយក្រមាមួយថ្នក់យ៉ាងណែនមកសុំដូរទឹកត្នោតផ្អែម ។

ក្នុងភាពយុវវ័យ បងប្រុសម្ចាស់ទឹកត្នោតមានអាយុប្រមាណម្ភៃពីរ ម្ភៃបីឆ្នាំ សម្បុរខ្មៅស្រអែម មាឌក្រអាញទាបបន្តិច ស្លៀកខោខ្មៅត្រឹមភ្លៅលែងខ្លួនទទេបញ្ចេញសាច់ដុំកន្ត្រាក់បន្តិច ហើយក៏ឡើងត្នោតបានយ៉ាងរហ័ស ... 

ខ្មៅត្រឹមភ្លៅលែងខ្លួនទទេបញ្ចេញសាច់ដុំកង្កែបទាំងកង់ៗ នៅនឹងចង្កេះមានពាក់ខ្សែក្រវ៉ាត់របស់ទាហានអាមេរិកកាំង មានសៀតកាំបិតត្នោតមួយយ៉ាងសង្ហា ។ ដោយទឹកមុខញញឹមស្រស់ស្រាយពេលដែលគាត់ចុះពីបង្អោងមកដល់ដី ហើយបានឃើញខ្ញុំរង់ចាំគាត់ជាស្រេចនៅនឹងគល់ត្នោត ។ ខ្ញុំក៏ចាប់ផ្តើមពោលទៅកាន់គាត់ថា ខ្ញុំជាអ្នកជម្លៀសមកពីស្រុកស្រីសន្ធរដែលបានមកដល់ទីនេះកាលពីយប់មិញ នៅឯស្រុកទន្លេអត់មានទឹកត្នោតផ្អែមហូបទេ ខ្ញុំមានថ្នាំជក់មួយថ្នក់នេះមកសុំដូរទឹកត្នោតពីមិត្តបងយកទៅចែកគ្នាហូប ។

ខ្ញុំហុចថ្នាំជក់ទាំងថ្នក់ជូនទៅគាត់ បងប្រុសអ្នកឡើងត្នោតហាក់មិនរវល់អើពើនឹងជំនូនរបស់ខ្ញុំ គាត់ងាកទៅរើបំពង់ទឹកត្នោតដែលទើបតែនឹងដាក់ចុះពីលើដើមព្យួរផ្តុំគ្នានៅនឹងគល់ត្នោតមួយដើមក្បែរនោះ រួចគាត់បានហុចទឹកត្នោតមួយបំពង់ធំពេញថ្លាយង់មកឲ្យខ្ញុំ ហើយគាត់និយាយដោយទឹកមុខញញឹមមកកាន់ខ្ញុំថា ប្អូនឯងយកទឹកត្នោតនេះទៅចែកគ្នាហូបចុះ មិនចាំបាច់ដូរដោះអីទេ ហូបរួចប្អូនឯងយកបំពង់ទទេមកពាក់ទុកឲ្យបងនៅនឹងបង្អោងគល់ត្នោតនេះចុះ ។

ខ្ញុំលើកដៃសំពះអរគុណគាត់ គ្រាដែលគាត់បដិសេធហើយបដិសេធទៀតមិនព្រមទទួលយកថ្នាំជក់របស់ខ្ញុំ ខ្ញុំសែនរំភើបក្នុងចិត្តគ្រាដែលបានមកជួបនឹងមនុស្សដែលមានសណ្តានចិត្តយ៉ាងល្អដូច្នេះ ។ មុនពេលដែលគាត់បែកពីខ្ញុំទៅ គាត់បានចង្អុលប្រាប់ខ្ញុំពីភូមិដែលគាត់រស់នៅជាប់នឹងរបងខាងជើងវត្ត មើលទៅឃើញយ៉ាងជិតបង្កើយ ឈ្មោះភូមិឈើទាល ហើយឈ្មោះរបស់គាត់គឺមិត្ត ហឿង ។

ព្រឹកនោះយើងជុំគ្នាហូបបាយកក ស្របនឹងទឹកត្នោតផ្អែមដែលមានរស់ជាតិយ៉ាងផ្អែមត្រជាក់លាយនឹងក្លិនអប់បំពង់យ៉ាងឈ្ងុយឈប់ ហូបបណ្តើរ ពូផន លាន់មាត់បណ្តើរថា ឆ្ងាញ់ណាស់ ឆ្ងាញ់រកអ្វីមកប្រៀបផ្ទឹង ពុំបានឡើយ ។

រហូតដល់ម៉ោងប្រមាណជិតដប់ព្រឹក ទើបឃើញមានមនុស្សមួយក្រុមក្នុងសម្លៀកបំពាក់ពណ៌ខ្មៅ ជិះកង់ចូលមកក្នុងបរិវេណវត្តដោយមានអ្នកខ្លះស្ពាយកាំភ្លើងការ៉ាប៊ីន និងកាំភ្លើងអាកា-៤៧ នៅនឹងស្មាផង ។ ក្នុងចំណោមនោះខ្ញុំសម្គាល់ឃើញមាននារីម្នាក់រាងទាបស្តើងបន្តិច បង់កក្រមាក្រហមទម្លាក់ជាយទៅក្រោយ និងបុរសម្នាក់ទៀតស្លៀកខោខ្មៅជើងវែង ដែលជើងខោម្ខាងមូរនៅត្រឹមក្បាលជង្គង់ ដូតក្បាលក្រមាខ្មៅ មានទាំងសៀតបារីស្លឹកសង្កែមួយដើមនៅនឹងត្រចៀកខាងស្តាំផង ។ ពួកអ្នកដែលមានស្ពាយកាំភ្លើង ខ្ញុំមើលទៅដូចជាកងការពាររបស់បុរសនោះ មួយស្របក់ក្រោយមក ពួកយើងទាំងអស់ដែលមកពីស្រុកទន្លេ ត្រូវបានពួកមិត្តដែលស្ពាយកាំភ្លើងនៅនឹងស្មាដើរហៅប្រមូលឲ្យមកជួបប្រជុំគ្នានៅនឹងកណ្តាលធ្លាវត្ត ។

បុរសដែលមូរជើងខោម្ខាងត្រឹមក្បាលជង្គង់ បានប្រកាសណែនាំខ្លួនគាត់ឲ្យបងប្អូនមកពីស្រុកទន្លេស្គាល់ គាត់ឈ្មោះមិត្ត ពឹន ប្រធានឃុំកំពង់ថ្ម ។ ក្រោយពីមិត្ត ពឹន បានប្រកាសទទួលស្វាគមន៍យ៉ាងកក់ក្តៅរាក់ទាក់រួចមក គាត់បានប្រាប់ពួកយើងឲ្យបានដឹងថាអង្គការធ្វើការបែងចែកបងប្អូនឲ្យទៅរស់នៅតាមភូមិនានា ក្នុងឃុំកំពង់ថ្មទាំងមូល ចំនួនប៉ុន្មានគ្រួសារមួយភូមិនោះ គឺអាស្រ័យទៅតាមភូមិតូច ភូមិធំ ដល់ពេលបែងចែករួច អ្នកភូមិនឹងបររទេះ មកទទួលបងប្អូនពីទីនេះ ។

ខ្ញុំ និងអ្នកម៉ែត្រូវបានរាប់បញ្ចូលជាគ្រួសារតែមួយជាមួយនឹងគ្រួសារ ពូផន រួមជាមួយគ្រួសារអ្នកទន្លេចំនួនប្រាំមួយគ្រួសារទៀតត្រូវបានមិត្ត ពឹន បែងចែកឲ្យទៅរស់នៅភូមិមួយឈ្មោះភូមិទួលសង្កែ ។ មិត្តពឹន នៅបានណែនាំពួកខ្ញុំឲ្យស្គាល់មិត្តនារីដែលរួមដំណើរមកជាមួយ

គាត់ឈ្មោះមិត្ត រីន ជាប្រធានសហករណ៍ភូមិទួលសង្កែ និងត្រូវជាគ្រួសាររបស់គាត់ផង ក្នុងសង្គមបដិវត្តន៍ គេមិនប្រើពាក្យ "ប្ដីប្រពន្ធ" ទេ គេប្រើពាក្យ "គ្រួសារ" ជំនួសវិញ ។ ពេលដែលមិត្ត រីន បានមកសួរសុខទុក្ខក្រុមគ្រួសារដែលត្រូវទៅរស់នៅភូមិទួលសង្កែ ដោយភាសាបដិវត្តន៍យ៉ាងសុភាពទន់ភ្លន់នោះរទេះគោបីគ្រឿងពីភូមិទួលសង្កែក៏បានបរមកដល់ល្ងម មកឈប់តម្រៀបគ្នានៅក្រោមម្លប់ដើមអំពិលបារាំងមួយដើមធំក្បែរនោះ ។ ពេលដែលយើងកំពុងតែនាំគ្នាជញ្ជូនអីវ៉ាន់ដាក់ក្នុងរទេះគោ បងប្អូនអ្នកជម្លៀសជាច្រើនគ្រួសារផ្សេងទៀតក៏បាន និងកំពុងតែចាកចេញពីបរិវេណវត្តឆ្ពោះទៅកាន់ភូមិនានាក្នុងឃុំកំពង់ថ្ម តាមការបែងចែករបស់មិត្ត ពឹន ជាបន្តបន្ទាប់ដែរ ។

យើងនាំគ្នាដើរពីក្រោយរទេះគោដែលបរចេញតាមក្លោងទ្វារខាងលិចវត្តកំពង់ថ្មតម្រង់មកផ្លូវជាតិ រួចបរឆ្លងកាត់ថ្នល់ជាតិឆ្ពោះទៅកាន់ភូមិទួលសង្កែដែលស្ថិតនៅជាប់ខាងលិចថ្នល់ ។ ទេសភាពនៅកំពង់ថ្មខុសស្រឡះពីទេសភាពនៅឯស្រុកទន្លេតាមដងផ្លូវវាលស្រែល្វឹងល្វើយ ក្នុងស្រែ ស្រូវទាំងគុម្ពៗកំពុងតែឱនដាក់គ្រាប់ ស្រែខ្លះស្រូវកំពុងតែប្រែពណ៌ជិតទុំ ស្រែខ្លះទៀតទើបតែនិងច្រូតកាត់ហើយថ្មីៗ តាមភ្លឺស្រែលំអដោយដើមត្នោតទាបខ្ពស់ជាច្រើនដើម ខ្យល់ជំនោររដូវរំហើយបក់មកត្រសៀកៗសព្វទីឋានទាំងអស់ មើលទៅគួរជាទីមនោរម្យ ។

រទេះបរមកដល់ពាក់កណ្ដាលភូមិ បានឈប់នៅចំពីមុខផ្ទះឈើខ្ពស់ផុតពីដីប្រក់ស្លឹក ជញ្ជាំងបាំងធាងដូងមួយខ្នង នៅប្របនឹងមាត់ផ្លូវខាងស្ដាំដៃ អ្នករួមដំណើរជាមួយខ្ញុំចំនួនបីគ្រួសារ ត្រូវបានមិត្ត រីន ប្រាប់ឲ្យរើអីវ៉ាន់ចូលទៅនៅក្នុងផ្ទះនោះ មួយគ្រួសារនៅផ្ទាល់នឹងដី ហើយពីរគ្រួសារទៀតនៅខាងលើផ្ទះ ។ ចំណែកបួនគ្រួសារដែលនៅសល់ ត្រូវបន្តដំណើរទៅមុខទៀត ។

ដើរមកដល់ចុងភូមិឃើញមានសាលាសំណាក់តូចមួយនៅនឹងកណ្ដាលវាលស្រែខាងឆ្វេងដៃ ។ មិត្ត រីន ក៏បានប្រាប់ឲ្យពួកយើងចូលទៅសំណាក់នៅទីនោះសិន ។ សាលាសំណាក់ដែលព័ទ្ធជុំវិញដោយគុម្ពស្រូវកំពុងតែទុំលឿងឆ្អៅដូចមាសរកតែចន្លោះឈានជើងដើរចូលសឹងតែពុំរួច យើងនាំគ្នាដណ្ដាំស្លហូបបាយថ្ងៃត្រង់នៅទីនោះ ។ រហូតដល់ថ្ងៃរសៀលទើបឃើញមិត្ត រីន ត្រឡប់មកវិញ ។ ហួសពីសាលាសំណាក់នោះបន្តិច ខ្ញុំ និងគ្រួសារ ពូផន ត្រូវបានមិត្តរីនឲ្យទៅរស់នៅនឹងកូនខ្ទមស្លឹកតូចមួយដែលគេបោះបង់ចោល ដំបូល និងជញ្ជាំងធ្លុះធ្លាយ នៅពីមុខខ្ទមមានកូនត្នោតពីរដើមឈរទ្រឹងប្រកៀកគ្នាកម្ពស់ត្រឹមចង្កេះ ។ គ្រួសារបង សំអាន មានកូនប្រាំនាក់ ដែលប្រពន្ធគាត់ត្រូវជាបងប្អូនជីដូនមួយ និងបង សារុំ ក៏ត្រូវបានមករស់នៅនឹងកូនខ្ទមតូចមួយជិតខ្ញុំនោះដែរ ។ ចំណែកពីរគ្រួសារផ្សេងទៀត មានគ្រួសារបង សំអាត និងគ្រួសារ ពូគ្រីន មិត្តរីន ដោះស្រាយឲ្យទៅរស់នៅជ្រកតាមផ្ទះបងប្អូនអ្នកមូលដ្ឋានចាស់សិនទំរាំរដ្ឋអំណាចភូមិដោះស្រាយសង់ "ផ្ទះរបប" ឲ្យនៅ ។

នៅពីក្រោយខ្ទមដែលខ្ញុំរស់នៅមានដើមស្វាយព្រៃមួយដើមក្បែរនោះមានអណ្ដូងដៃមួយដែលមានទឹកថ្លាយង់ មានកង្កែបធំៗជាច្រើនលាក់ខ្លួននៅតាមចន្លោះខ្នោះឈើដែលគងបន្តបបន្តបន្ទាប់គ្នា ហើយរាល់ពេលដែលខ្ញុំបានដើរទៅក្បែរនោះ កង្កែបជាច្រើនផ្អើលលោតប្រូងៗចូលទឹកព្រមៗគ្នា ទំនងញញើតញញើមនឹងខ្ញុំដែលជាអ្នកចំណូលថ្មី ។ ឆ្ងាយពីនោះបន្តិចមានវាលស្មៅមួយ វាលធំពណ៌បៃតងខ្ចីរាបស្មើដូចកម្រាលព្រំ ហើយនៅនឹងដីចំហៀងខាងកើតខ្ទមមានដើមរំចេកខ្ពស់ៗដុះមួយជួរយ៉ាងវែង ។

មួយថ្ងៃបន្ទាប់មក ដោយមានការជួយជ្រោមជ្រែងពីគ្រួសារអ្នកភូមិដែលរស់នៅក្បែរខាងនោះ ខ្ញុំ និង ពូផន បងសំអាន ក៏បាននាំគ្នាជួសជុលប្រក់ដំបូលប៉ះជញ្ជាំងខ្ទម គ្រាន់បានគត់នឹងទឹកភ្លៀង បើមិនដូច្នោះទេ ដល់ពេលធ្លាក់ភ្លៀងច្បាស់ជាត្រូវនាំគ្នាអង្គុយគោរពភ្លៀងរហូតទល់ភ្លឺជាមិនខាន ។

ក្រោយមក យាយណៃ ប្រធានឃ្លាំងភូមិទួលសង្កែ ដែលកាលពីសម័យតស៊ូប្រឆាំងនឹងចក្រពត្តិអាមេរិក និងបរិវារ លន់ នល់ គាត់បានលះបង់កូនប្រុសពីរនាក់ ឲ្យចូលបម្រើក្នុងជួរកងទ័ពបដិវត្តន៍ ហើយត្រូវបានស្លាប់ទាំងពីរក្នុងសមរភូមិ សព្វថ្ងៃគាត់រស់នៅតែម្នាក់ឯងជាមួយក្មួយៗ ហៅគ្រួសារទាំងអស់ដែលទើបតែនឹងមកដល់ឲ្យទៅបើករបបស្រូវអង្ករ និងស្ករត្នោត ។ បន្ទាប់ពីនោះមក មានការបែងចែកកម្លាំងពលកម្មចុះធ្វើការងារក្នុងភូមិ ។ ពូៗ មីងៗ ដែលមានគ្រួសារហើយ ត្រូវបានបញ្ចូលទៅក្នុងកងវ័យកណ្ដាល ចំណែកអ្នកដែលនៅលីវ បញ្ចូលទៅក្នុងកងយុវជន យុវនារីភូមិ ។

ថ្ងៃដំបូងដែលខ្ញុំត្រូវបានគេហៅឲ្យទៅប្រជុំរួមជាមួយយុវជន

យុវនារីទាំងអស់នៅឯរោងគុកស្តុកកណ្តាលភូមិ ដើម្បីទទួលផែនការចុះប្រយុទ្ធការងារនៅថ្ងៃបន្ទាប់ ខ្ញុំសម្គាល់ឃើញមិនសូវមានយុវជនយុវនារីដែលជាអ្នកមូលដ្ឋានចាស់ទេ ភាគច្រើនជា អ្នក១៧មេសា ហើយក្នុងចំណោមអ្នកថ្មីនោះទៀត ច្រើនជាអ្នកដែលមានស្រុកកំណើតនៅទីនេះ ។

បន្ទាប់ពីបើកអង្គប្រជុំរួចមក "មិត្តនួក" ប្រធានយុវជនភូមិក៏បានធ្វើការបែងចែកកម្លាំងយុវជន យុវនារី ជាកង១ ហើយបានប្រកាសពីផែនការ និងមុខសញ្ញាចុះច្រូតប្រមូលផលស្រូវនៅព្រឹកថ្ងៃស្អែក ។ កន្លែងជួបជុំគ្នា នៅនឹងគុកស្តុកនេះដដែល ហើយត្រូវយកបាយកញ្ចប់តាមរៀងៗខ្លួនផង ។

ស្អែកឡើងយុវជន យុវនារីទូទាំងភូមិប្រមាណជាង៥០នាក់ បានមកជួបជុំគ្នាតាមការកំណត់បន្ទាប់ពីព្រួដូរជួងពីរដងជាសញ្ញា ។ មិត្តនួក ក្នុងសម្លៀកបំពាក់ខោអាវខ្មៅ ពាក់ស្បែកជើងកង់ឡាន បង់កក្រមា ពាក់មួកស្លឹកត្នោត ពាក់វ៉ែនតាសម្រាប់ការពារកម្តៅព្រះអាទិត្យ វ៉ែនតា *Rayband* ដែលមានកញ្ចក់ទាំងគូរពណ៌ខៀវក្រម៉ៅងងឹតស្លុប មើលភ្នែកពុំយល់ បានដើរនាំមុខពួកខ្ញុំឆ្ពោះទៅវាលស្រែខាងលិចភូមិ និងនៅដៃម្ខាងមានយួរម៉ាញ៉េតូហ្វូនធំមួយផង ដែលកំពុងតែចាក់ខ្សែអាត់បទចំរៀងបដិវត្តន៍លាន់ឮសូរយ៉ាងទ្រហឹង ។

ដើរមកដល់ស្រែដែលត្រូវច្រូត មិត្តនួក បានដាក់ម៉ាញ៉េតូហ្វូនទៅលើភ្លឺស្រែ ហើយបើកសំឡេងបន្ថែម ឲ្យឮកាន់តែខ្លាំងថែមទៀត រួចបញ្ជាពួកយើងឲ្យរាយគ្នាចុះច្រូត ។ មិត្តនួក ច្រូតស្រូវបានលឿនល្អណាស់ ច្រូតផង ចាប់ចងជាកណ្តាប់ផង មានទាំងយុវនារីបីបួននាក់ច្រូតអមឆ្វេងស្តាំ ច្រូតបណ្តើរពួកមិត្តៗនារីលូកលាន់ប្រឡែងលេងសើចសប្បាយយ៉ាងក្អាកក្អាយជាមួយមិត្តប្រធានបណ្តើរ ។

ពេលសម្រាកហូបបាយថ្ងៃត្រង់ ពួកយុវនារីបាននាំគ្នាទៅហូបជុំគ្នាជាមួយ មិត្តនួក ក្រោមម្លប់ដើមសង្កែមួយដើមលើភ្លឺស្រែ ហើយខ្ញុំចេះតែតាមសម្គាល់មើលមិនឃើញ មិត្តនួក ដោះវ៉ែនតាចេញពីភ្នែកទាល់តែសោះ ។

ដោយក្តីមន្ទិលសង្ស័យតាំងពីពេលដែលខ្ញុំបានជួប មិត្តនួក នៅថ្ងៃប្រជុំដំបូងម្ល៉េះ ហើយខ្ញុំនេះតែមានអារម្មណ៍នឹកគិតថា ខ្ញុំដូចជាធ្លាប់ស្គាល់ច្បាស់ទៀតមិនមែនស្គាល់លេងៗទេ ។ ខ្ញុំដណ្តឹងសួរខ្លួនឯងហើយសួរទៀតថា បើជា អានួក រៀនថ្នាក់ជាមួយខ្ញុំមែន ទើបតែបែកភ្នំពេញមិនទាន់បានមួយឆ្នាំផង ចុះហេតុអ្វីក៏វាមិនស្គាល់ខ្ញុំ? ឬមួយក៏វាស្គាល់ខ្ញុំហើយវាធ្វើជាមិនស្គាល់? ។ ប្រការមួយដែលខ្ញុំញញើតញញើមមិនហ៊ានចាប់ផ្តើមសួរវា ព្រោះពេលនេះខ្ញុំឃើញវាស្ថិតនៅក្នុងសម្លៀកបំពាក់ខោអាវខ្មៅ បង់កក្រមា ពាក់ស្បែកជើងកង់ឡាន ព្រមទាំងចរិតខុសស្រឡះពីពេលមុន ហើយលើសពីនោះទៅទៀត ពេលនិយាយស្តីម្តងៗ សំដីនិយាយបែរជារដឹងៗមិនដូចអានួក ពីមុនទេ

កាលពីរៀននៅក្នុងថ្នាក់ ខ្ញុំអង្គុយតុមួយតែពីរនាក់ អាចាន់ធរ ព្រោះវាជាមិត្តមួយថ្មើមមួយនឹងខ្ញុំ ហើយវាថែមទាំងជាដៃគូប្រជែងប្រណាំងគ្នាជាមួយខ្ញុំផ្នែកមុខវិជ្ជា "ខ្មែរ" ទៀតផង ។ ញ៉ុក ចាប់ធរ ដោយស្និទ្ធស្នាលខ្ញុំ ហៅឈ្មោះវាថា "អាញ៉ុកថយ" វាជាកូនប្រុសពៅរបស់លោក ញ៉ុក ថែម អ្នកនិពន្ធរឿង កុឡាបប៉ៃលិនដ៏ល្បីល្បាញ ។ លោក ញ៉ុក ថែម បានធ្វើមរណកាលដោយជរាពាធប្រមាណពីបីខែមុនពេលដាច់ភ្នំពេញ នៅគេហដ្ឋានរបស់លោកក្នុងសង្កាត់ទួលស្វាយព្រៃ ខាងក្រោយវិទ្យាល័យទួលស្វាយព្រៃ អតីតវិទ្យាល័យព្រះថោពញាយ៉ាត ក្រុងភ្នំពេញ តុជាប់នឹងស្តាំដៃ អាចាន់ធរ ក្នុងជួរតែមួយគឺតុ អានួក ។ ប្រមាណពីរសប្តាហ៍ក្រោយមក នាល្ងាចថ្ងៃមួយ ពេលដែលខ្ញុំត្រូវទៅចូលរួមប្រជុំសាជាថ្មីនៅឯគុកស្តុរដោយចៃដន្យ ពេលដែលខ្ញុំបានទៅដល់ទីនោះ ពុំទាន់មានវត្តមានអ្នកផ្សេងទៀតឡើយ មានតែខ្ញុំ និង មិត្តនួក ម្នាក់គត់ ។

មិត្តប្រធានបានដើរតម្រង់មករកខ្ញុំ ហើយបាននិយាយរដឹងៗមកកាន់ខ្ញុំថា "មិត្តឯងអត់ស្គាល់ខ្ញុំទេឬ? ...ខ្ញុំគឺ នួក ណា!..." ខ្ញុំធ្វើហាក់ដូចជាភ្ញាក់ផ្អើលយ៉ាងខ្លាំង រួចខ្ញុំបានតបទៅមិត្តប្រធានវិញថា "ជាងកន្លះខែទៅហើយ ដែលខ្ញុំចេះតែសង្ស័យៗនិយាយតាមត្រង់ទៅខ្ញុំមិនហ៊ានសួរ" ។

មិត្តនួក បានប្រាប់ខ្ញុំថា ភូមិទួលសង្កែជាភូមិកំណើតរបស់គេ ដែលមានឪពុកម្តាយមាមីងរស់នៅទីនេះជាអ្នកមូលដ្ឋានចាស់ទាំងអស់ ក្រោយពីភូមិកំណើតត្រូវបានកាន់កាប់ដោយកងទ័ពរំដោះនៅឆ្នាំ១៩៧៣ មក ខ្លួនគេនិងបងប្រុសម្នាក់ទៀតបានភៀសខ្លួន ទៅនៅភ្នំពេញដើម្បីបន្តការរៀនសូត្រ ។ ផ្ទះមិត្ត នួក ជាផ្ទះឈើប្រក់ក្បឿងមួយខ្នងធំណាស់ស្ថិតនៅឯច្រកចូលដើមភូមិ មើលពីថ្នល់ជាតិមកឃើញយ៉ាងស្កឹមស្កៃ មានព្រំប្រទល់ជាប់នឹងផ្ទះគាស្មួង (ផ្ទះ

អង្គការ) ។

នៅទីងដើមភូមិចុះពីថ្នល់ជាតិប្រមាណមួយរយម៉ែត្រ ក្រោមដើមជ្រៃធំមួយដើមចោលម្លប់សាខា គេឃើញមានផ្ទះគៀមផ្ទាល់ដីប្រក់ស្លឹកមួយខ្នង ដែលមានទីធ្លាខាងមុខផ្ទះយ៉ាងធំទូលាយ ។ ប្រជាជនទូទាំងឃុំកំពង់ថ្ម អ្នកណាក៏ស្គាល់ដែរថា ជាផ្ទះ តាសួង ដែលប្រជាជនគ្រប់មាត់តែងតែហៅថា "ផ្ទះអង្គការ" ។ តាមប្រជាជនដែលរស់នៅដើមភូមិក្បែរៗ តាសួង ហើយដែលត្រូវជាសាច់ឈាមកូនក្មួយគាត់ផងបាននិយាយថា តាសួង គាត់មានគុណបំណាច់ខ្លាំងណាស់ចំពោះបដិវត្តន៍តាំងពីមុខសម័យតស៊ូប្រឆាំងចក្រពត្តិមកម្ល៉េះ ។ តាសួង ដែលមានអាយុប្រមាណ៦០ឆ្នាំ ហើយជាកម្មាភិបាលភាគខាងជើង (មកពីហាណូយ) គាត់រស់នៅជាមួយប្រពន្ធគាត់ កូនប្រសារស្រីម្នាក់ និងចៅតូចមួយផង ។ ផ្ទះតាសួង មានអ្នករស់នៅជាមួយផ្សេងទៀតជាច្រើននាក់ដែលភាគច្រើនជាកូនក្មួយរបស់គាត់ ខ្លះទើបតែជម្លៀសមកពីភ្នំពេញ ។ អ្នកភូមិហៅផ្ទះ តាសួង ជាផ្ទះអង្គការ ព្រោះផ្ទះគាត់មានភ្ញៀវអង្គការគ្រប់ជាន់ថ្នាក់តាំងពីថ្នាក់មជ្ឈិម ភូមិភាគ តំបន់ ទៅមកទាំងយប់ទាំងថ្ងៃពុំឈប់ឈរ ជួនកាលគេឃើញមានរថយន្តហ្ស៊ីបពីរបីគ្រឿងចតពេញមុខផ្ទះ ហើយពេលដែលយើងបានដើរកាត់ទីនោះ ក្លិនទឹកស៊ុបគុយទាវភ្នំពេញ នំប៉ាវ នំចាខ្វៃ ដែលកំពុងចៀនក្តៅៗ ចោលក្លិនឈ្ងុយភាយៗគួរឲ្យស្រេចឃ្លាន ។

រដូវចម្រូតចុងឆ្នាំ ប្រជាជនក្នុងភូមិនាំគ្នាសម្រុកច្រូតកាត់យ៉ាងមមាញឹកបំផុត ព្រោះស្រូវក្នុងស្រែទុំបាក់កជាបន្តបន្ទាប់ ច្រូតសឹងពុំទាន់ដល់ច្រូតស្រូវស្រែលើរួចហើយ នៅមានផែនការចុះទៅសម្រុកច្រូតស្រូវឡើងទឹកនៅឯស្រែក្រោមទៀត ។ ពូផន ត្រូវបានចាត់តាំងឲ្យទៅរកត្រីជាមួយអ្នកភូមិពីរបីនាក់ទៀតនៅស្ទឹងជីនិត ។ មីងណារុងចុះច្រូតជាមួយកងវ័យកណ្តាល ទាំងអស់គ្នារវល់ការងារតាំងពីព្រលឹមទល់ព្រលប់ អ្នកម៉ែក៏ដូច្នោះដែរ ទៅត្បាញកន្ទេលរំចេកជាមួយយាយៗនៅទីស្នាក់ការសហករណ៍ភូមិរាល់ថ្ងៃ ចំណែកលោកយាយកំពង់សៀមនៅផ្ទះមើលចៅដែលជួនកាលត្រូវបានយាយៗមកតាមហៅឲ្យទៅជួយត្បាញកន្ទេលនឹងគេដែរ ដោយយក អាធានី កូនស្រីពូផន ទៅជាមួយ ផង ។

បន្ថែមលើផែនការសម្រុកច្រូតកាត់តាមភូមិ កងកម្លាំងយុវជន យុវនារីត្រូវបានគេប្រមូលផ្តុំឲ្យចុះជួយច្រូតតាមស្រែនានាទូទាំងឃុំ ។ រហូតដល់ពេលនោះទើបខ្ញុំដឹងថា ក្នុងឃុំកំពង់ថ្មមានអ្នក១៧មេសា រហូតដល់ទៅបីជំនាន់ ។ អ្នកថ្មីជំនាន់ទីមួយ ភាគច្រើនជាអ្នកដែលមានស្រុកកំណើតនៅទីនេះ ។ អ្នកថ្មីជំនាន់ទីពីរ ជាអ្នកជម្លៀសសុទ្ធសាធ មានគ្នាប្រមាណជាងហាសិបគ្រួសារដែលត្រូវបានរដ្ឋអំណាចឃុំកំពង់ថ្ម ប្រមូលឲ្យទៅនៅកណ្តាលព្រៃ កាប់គាស់រុករានដីសង់ជម្រកបង្កើតជាភូមិថ្មីមួយដោយបាតដៃទទេ ។

ដោយប្រជាជនភូមិថ្មីភាគច្រើនជាអ្នកភ្នំពេញ ហើយមាននិន្នាការជាទាហានមានឋានៈខ្ពស់ៗ ជាអ្នករដ្ឋការ ក្នុងជួររដ្ឋាភិបាល អ្នកភូមិថ្មីមិនត្រឹមតែត្រូវបានស្លាប់ជាបន្តបន្ទាប់រាល់ថ្ងៃដោយអត់ឃ្លាន ដោយជំងឺប៉ុណ្ណោះទេ អ្នកភូមិថ្មីនៅបានជួប និងការរើសអើងយ៉ាងខ្លាំងពីសំណាក់អ្នកមូលដ្ឋានចាស់មួយចំនួន ។

អ្នកភូមិថ្មីត្រូវកាប់គាស់រុករានដីព្រៃ ដាំផ្ទះ បង្កបង្កើនផលខបត្តម្ភខ្លួនដោយខ្លួនឯង ដោយប្រឈមមុខនឹងភាពអត់ឃ្លាននោះ អ្នកភូមិថ្មីក្មេងចាស់ប្រុសស្រីបានដើរសុំទានតាមភូមិនានា មានអ្នកភូមិថ្មីខ្លះទៀតបានមកសុំជួយកិនស្រូវអង្ករតាមផ្ទះអ្នកមូលដ្ឋានចាស់ ដោយសុំយកតែកន្ទក់ត្រឡប់ទៅភូមិវិញតែប៉ុណ្ណោះ ។

ក្រោយពីពេលដែលពួកខ្ញុំជាអ្នកជម្លៀសមកពីស្រុកទន្លេ បានមកដល់ប្រជាជនអ្នកភូមិថ្មីទាំងមូលដែលនៅសេសសល់ពីស្លាប់ត្រូវបានអង្គការរំសាយឲ្យទៅរស់នៅតាមភូមិនានា ។ ក្នុងចំណោមនោះ មានគ្រួសារប្រពន្ធកូនលោក អំរុង អ្នកនាំពាក្យរងទីបញ្ជាការជាន់ខ្ពស់កងទ័ពជាតិនៃរដ្ឋាភិបាល ។ កូនប្រុសរបស់លោក អំរុង ឈ្មោះ សំណាង (ហៅបងអូន) ជានិស្សិតរៀននៅមហាវិទ្យាល័យវេជ្ជសាស្ត្របានប្រាប់ខ្ញុំថា ឪពុករបស់គាត់ត្រូវបានកងទ័ពខ្មែរក្រហមចូលមកចាប់ដល់ផ្ទះ តាំងពីថ្ងៃបែកភ្នំពេញដំបូងម្ល៉េះ ។ គាត់រសាត់អណ្តែតមកដល់ភូមិថ្មី ឃុំកំពង់ថ្ម នេះជាមួយម្តាយ និងប្អូនប្រុសពៅម្នាក់ឈ្មោះ អាធី ។

ប្រពន្ធកូនលោក អំរុង និងគ្រួសារលោកស័ក្តិ៥ ខ្មែរកម្ពុជាក្រោមត្រកូល ថាច់ មួយគ្រួសារទៀតគួរឲ្យសោកស្តាយបំផុត ដោយខ្ញុំមិនបានស្គាល់ឈ្មោះពិតប្រាកដរបស់គាត់ ដែលមានកូនពីរនាក់ កូនស្រីច្បងឈ្មោះ ថាច់ សូរិយា អាយុប្រមាណ១៥ឆ្នាំ ធ្លាប់រៀននៅ Petitte Lycee Angkor ក្រុងភ្នំពេញ និងកូនប្រុសពៅ អាយុ១១

ឬ១២ឆ្នាំឈ្មោះ ថាច់ ឆៃយ៉ា ត្រូវបានបែងចែកឲ្យទៅរស់នៅភូមិព្រៃភ្លូ ។

មានវិចិត្រករល្បីឈ្មោះម្នាក់ឈ្មោះលោក ឆោម ឆើត ត្រូវជាឪពុកមាបង្កើតរបស់លោក ឆោម ឆារី កីឡាករប្រដាល់អន្តរជាតិ និងគ្រួសារបងប្រុសគាត់ឈ្មោះលោក ឆោម ឆុំ ត្រូវបានគេបែងចែកឲ្យទៅរស់នៅភូមិឈើទាល ។

តាំងពីមុនពេលដែលអង្គការរំសាយភូមិថ្មីនេះ លោក ឆោម ឆើត តែងតែដើរគូររូបតាមផ្ទះអ្នកភូមិនានា ជាថ្នូរនឹងស្រូវអង្ករបន្តិចបន្តួចសម្រាប់ទប់ទល់នឹងភាពអត់ឃ្លាន ។ រូបភាពដែលគាត់បានគូរនឹងខ្មៅដៃ អ្នកភូមិបានដាក់ស៊ុមកញ្ចក់រក្សាទុកតាមផ្ទះរៀងៗខ្លួន ។

ភូមិទួលសង្កែក៏បានទទួលអ្នកភូមិថ្មី៦-៧គ្រួសារឲ្យមករស់នៅដែរ ក្នុងនោះមានទាំងគ្រួសារខ្មែរ អ៊ីស្លាមមួយគ្រួសារផង ដែលមានកូនប្រុសម្នាក់ឈ្មោះ ទៀត នៅក្នុងកងយុវជនជាមួយខ្ញុំ ។

អ្នកភូមិថ្មីដែលបានត្រូវគេបញ្ជូនឲ្យមករស់នៅភូមិធនមោងដែលស្ថិតនៅខាងលិចថ្នល់ជាតិព្រំប្រទល់ជាប់នឹងភូមិទួលសង្កែ មានគ្រួសារលោក អាំង អេងថុង គ្រួសារលោក ម៉ម ប៊ុនណារ៉ៃ តន្ត្រីករវិយោឡុងមាសដែលមានម្តាយចាស់ជរា និងក្មួយប្រុសកំព្រាម្នាក់ឈ្មោះ ម៉ម វីរដ្ឋា ដែលក្រោយមកត្រូវបានគេបញ្ចូលក្នុងអង្គភាពយុវជនចល័តឃុំជាមួយខ្ញុំដែរ ។ នៅមានគ្រួសារលោក ម៉ម បូផាន់ ជានាយកមហាវិទ្យាល័យដូរតន្ត្រី និងដែលត្រូវជាបងប្រុសបង្កើតរបស់លោក ម៉ម ប៊ុនណារ៉ៃ ដែលពេលនោះខ្ញុំមិនដែលឃើញមានវត្តមានលោក ម៉ម បូផាននី ទេ ឃើញតែភរិយារបស់គាត់ និងកូនពីរនាក់ ។

ភូមិផ្សេងទៀតក្រៅពីនោះ មានភូមិខ្វែក ភូមិល្អក់ ភូមិឃ្លៃ ភូមិស្នោ ភូមិកងសៅ ភូមិកំពង់ថ្ម សុទ្ធតែត្រូវបានអង្គការបញ្ជូនអ្នកភូមិថ្មីឲ្យទៅរស់នៅលើកលែងតែភូមិស្អាងមួយ ដែលស្ថិតនៅជាប់ស្រយាលពេក ។

បីខែដំបូងដែលខ្ញុំបានមករស់នៅក្រោមមេឃថ្មី ដីថ្មីនៃឃុំកំពង់ថ្មនេះ អ្នកថ្មីទាំងអស់គ្នាហាក់ដូចជាសប្បាយត្រេកត្រអាល ។ ផុតពីរដូវសម្រុកច្រូតកាត់ចូលដល់រដូវសម្រុកដកស្ទូងបន្តការហូបចុកនៅបើករបបស្រូវអង្ករ ស្ករត្នោតហូបតាមផ្ទះ ។ ពូផន ហាក់ដូចជាបានធូរស្បើយមិនសូវភិតភ័យដូចកាលដែលរស់នៅឯស្រុកទន្លេ ព្រោះនៅនឹងភូមិទួលសង្កែនេះ គាត់ជាមនុស្សថ្មីគ្មានអ្នកណាស្គាល់ពីសាវតាររបស់គាត់ឡើយ ។ មីងណារុង អ្នកម៉ែ និងយាយកំពង់សៀម ក៏បានទទួលការស្រឡាញ់រាប់អានជាភាគរៈពីសំណាក់អ្នកភូមិក្មេងចាស់ប្រុសស្រី ពេលនោះម្នាក់ៗគ្មានគិតស្អីទៀតទេ គិតតែពីទៅធ្វើការតាមផែនការរបស់អង្គការដាក់ចុះតែប៉ុណ្ណោះ ។

ថ្ងៃមួយមិត្តពឹន ប្រធានឃុំកំពង់ថ្ម បានកោះហៅប្រជាជនទូទាំងឃុំឲ្យមកជួបប្រជុំគ្នានៅនឹងវាលមួយក្រោមម្លប់ឈើធំៗជាប់ខាងជើងភូមិធនមោង ។ ក្នុងឱកាសនោះមិត្តពឹន បានប្រកាសឲ្យប្រជាជនបានដឹងពីផែនការរបស់អង្គការថ្នាក់លើ ដែលមានទិសដៅឲ្យបងប្អូនប្រជាជនទូទាំងប្រទេសសម្រុកធ្វើស្រែប្រពលវប្បកម្មបីដងក្នុង១ឆ្នាំ និងឲ្យបានផលពីមួយតោនទៅបីតោនក្នុងមួយហិកតា ។

មិត្ត ពឹន នៅបានប្រកាសប្តេជ្ញារួមចំណែកជាមួយប្រជាជនក្នុងឃុំទាំងដប់មួយភូមិ ជំរុញផែនការធ្វើស្រែប្រពលវប្បកម្មតាមទិសដៅដែលអង្គការថ្នាក់លើបានដាក់ចុះឲ្យបានសម្រេចជាស្ថាពរ ។ នៅទីបញ្ចប់មិត្តពឹន បាននិយាយសន្យានឹងប្រជាជនក្នុងឃុំបែបកំប្លែងថា ដល់យើងបង្កបង្កើនផលបីដងក្នុងមួយឆ្នាំ បីតោនក្នុងមួយហិកតាពេលនោះប្រជាជនយើងនឹងមានជីវភាពរស់នៅគ្រប់គ្រាន់មានរបបហូបចុកដល់ទៅបីពេលក្នុងមួយថ្ងៃ ។ មិត្តពឹន បានបន្ថែមចុងក្រោយថា មុនពេលបងប្អូនចេញទៅធ្វើការ យើងនាំគ្នាហូបបបរក្តៅៗជាមួយផ្អកចៀនឲ្យឆ្អែតសិន ។

ពេលរំសាយអង្គប្រជុំ ពូផន បានមកនិយាយខ្សឹបដាក់ត្រចៀកខ្ញុំតិចៗថា "បបរក្តៅៗនិងផ្អកចៀន...បែបទំនងម្ល៉េះដែរ..." ។ ក្រោយពីសម្រុកច្រូតកាត់តាមស្រែទូទាំងឃុំជិតរួចរាល់ហើយ កងកម្លាំងយុវជន យុវនារី និងកងវ័យកណ្តាលត្រូវបានរដ្ឋអំណាចភូមិបែងចែកជាពីរផ្នែក ។ មួយផ្នែកត្រូវចុះទៅច្រូតស្រូវនៅឯស្រែក្រោម និងមួយផ្នែកទៀតត្រូវត្រៀមខ្លួនចុះទៅការដ្ឋានលើកប្រព័ន្ធភ្លឺស្រែ នៅឯរលោះត្រពាំងវែង ជាយក្រុងកំពង់ធំ ជាការដ្ឋាន "តំបន់" ដ៏ធំមួយដែលមានកម្លាំងប្រមូលផ្តុំមកពីគ្រប់ស្រុកទាំងអស់ក្នុងតំបន់៤៣នេះ ។ ខ្ញុំត្រូវបាន មិត្តរឹន ប្រធានភូមិចាត់តាំងឲ្យទៅការដ្ឋានរលោះត្រពាំងវែង ជាមួយកងយុវជន យុវនារី និងពូមីងកងវ័យកណ្តាលប្រមាណជាងម្ភៃនាក់ទៀត ដែលមានមិត្ត នៅជាប្រធានដឹកនាំតំណាងឲ្យរដ្ឋអំណាចភូមិក្តាប់កម្លាំងពលកម្មរួម

ហើយកម្លាំងពលកម្មដែលត្រូវបានបញ្ជូនទៅទីនោះ មិនកំណត់ថាត្រូវនៅរយៈពេលមួយខែឬពីរខែទេ គឺនៅរហូតទាល់តែបិទការដ្ឋានតែម្តង ។ ថ្ងៃដែលត្រូវចេញដំណើរនៅរយៈពេលពីរថ្ងៃខាងមុខទៀតកម្លាំងទាំងអស់គ្រប់ភូមិក្នុងឃុំកំពង់ថ្មត្រូវមកជួបជុំគ្នានៅវត្តកំពង់ថ្មជាមុនសិន មុនពេលចេញដំណើររួមគ្នា ។ ពេលនោះគឺជាលើកដំបូងបង្អស់ហើយដែលខ្ញុំបែកឃ្លាតឆ្ងាយពីអ្នកម៉ែ តាំងពីពេលដាច់ភ្នំពេញជាងមួយឆ្នាំមកនេះ ។

មិត្ត នៅ ដែលត្រូវដឹកនាំកម្លាំងពលកម្មភូមិទួលសង្កែទៅចូលរួមការដ្ឋានតំបន់នៅរលោះត្រពាំងវែង រស់នៅជាមួយម្តាយមេម៉ាយ មិត្ត នៅ ជាកូនច្បងដែលមានប្អូនប្រុសម្នាក់បន្ទាប់ឈ្មោះមិត្ត នួន វិកលចរិត និងប្អូនប្រុសពៅតូចម្នាក់ទៀត ។ មិត្ត នៅ មានអាយុប្រមាណ១៨ឆ្នាំ អនុវជនមិនបានរៀនបានសូត្រអីទេ ។ ផ្ទះមិត្តនៅនៅចម្ងាយប្រមាណមួយស្រែពីខ្ទមដែលខ្ញុំរស់នៅ ។ ល្ងាចៗខ្លះមិត្តនៅ បាននាំខ្ញុំដើរទៅមើលឲ្យស្គាល់ភូមិទួលសង្កែចាស់ ដែលនៅប្របតាមបណ្តោយមាត់ស្ទឹងជីនិតដែលរងដោយការទម្លាក់គ្រាប់បែកកាលពីពេលសង្គ្រាម ឆេះខ្ទេចខ្ទីស្ទើរតែបាត់ស្រមោលភូមិមួយទាំងស្រុង ខ្ញុំឃើញនៅមានសល់តែជើងសរសរផ្ទះមួយពីរ ក្រៅពីនោះមានតែស្នាមរណ្តៅគ្រាប់បែកធំៗសព្វទីកន្លែងទាំងអស់ ។

កម្លាំងពលកម្មដែលត្រូវចេញដំណើរ ទៅការដ្ឋានតំបន់នៅរលោះត្រពាំងវែងទាំងយុវជនយុវនារី និងកងវ័យកណ្តាលជងទូទាំងឃុំកំពង់ថ្ម មានគ្នាប្រហែលជាងមួយរយនាក់ បានមកជួបជុំគ្នានៅវត្តកំពង់ថ្ម ។

ក្រោយពីរៀបចំកម្លាំងស្រួលបួលហើយ យើងក៏បានចេញដំណើរដើរជាជួរតាមបណ្តោយផ្លូវជាតិ ដើរតាមពីក្រោយរទេះគោដែលភូមិនីមួយៗមានរទេះគោពីរគ្រឿងសម្រាប់ដឹកសម្ភារចប បង្គី ឆ្នាំងខ្លះ និងអង្ករ ប្រហុកត្រីសាច់ ។ ដើរមកដល់ភូមិកកោះយើងនាំគ្នាសម្រាកហូបបាយថ្ងៃត្រង់នៅក្រោមម្លប់ដូងដ៏ត្រជាក់ជាច្រើនដើម ដុះជាជួរតាមបណ្តោយចិញ្ចើមថ្នល់ខាងស្តាំដៃ ហូបបាយកញ្ចប់ដែលបានខ្ចប់យកមកតាមរៀងៗខ្លួន ។ ហូបបាយរួចយើងបន្តដំណើរទៅមុខទៀត ដើរយូរៗទៅ ម្នាក់ៗចេញពីជួរដើររកេតរកូតពាសពេញថ្នល់ ដើរមួយកំណាត់ថ្ងៃទៅហើយ តាមបណ្តោយផ្លូវជាតិស្ងាត់ឈឹងគ្មានឃើញឡានមួយគ្រឿងបើកកាត់សោះ យូរៗម្តងឃើញមានរទេះគោអ្នកភូមិដែលរស់នៅតាមបណ្តោយផ្លូវជាតិបរឆ្លងថ្នល់ម្តង ។ ខ្ញុំមិនបានដឹងថា ពីកំពង់ថ្មទៅការដ្ឋានរលោះមានចម្ងាយប៉ុន្មានគីឡូម៉ែត្រទេ ព្រោះត្រូវដើរចុះពីថ្នល់ជាតិចូលជ្រៅទៅក្នុងរហូតជិតដល់វត្តរលោះ ទើបមើលឃើញដំបូលរោងប្រកស្លឹកផ្កាលនឹងដី សង់ជាប់ៗគ្នាជាច្រើនជួររំលេចដោយទង់បក្ស ទង់ជ័យលាដែលកំពុងតែត្រូវខ្យល់បករវិចៗ និងពុស្ករបទចម្រៀងបដិវត្តន៍លឺយៗពីចម្ងាយ ។

ពេលដែលយើងបានមកដល់ជួបជុំគ្នានៅទីទីស្នាក់ការ ដើម្បីបែងចែកជម្រកតាមឃុំ តាមភូមិ យប់ងងឹតល្ងម ។ រោងនានាដែលនៅឆ្ងាយបន្តិចពីទីស្នាក់ការ មានដុតភ្លើងចន្លុះភ្លឺព្រោងព្រាត មើលទៅដូចភ្លើងប្រទីបឆេះភ្លឺបភ្លែតកណ្តាលវាលដ៏ធំល្វឹងល្វើយក្រោមដំបូលមេឃដ៏ងងឹតសូន្យសុង ។

មានកម្លាំងតាមស្រុក និងតាមឃុំមួយចំនួនបានមកដល់ការដ្ឋានរលោះនេះ តាំងពីមួយសប្តាហ៍មុនម្ល៉េះ ហើយបានចាប់ផ្តើមការងារតាមការបែងចែកមុខសញ្ញាលើកប្រព័ន្ធភ្លឺស្រែតាមស្រុករៀងៗខ្លួន ។

មិត្តលន់ ប្រធានភូមិកងសៅ ជាអ្នកក្តាប់រួមកម្លាំងទូទាំង១១ភូមិនៃឃុំកំពង់ថ្ម ដោយមានមិត្តធឿន ប្រធានភូមិ ខ្វែក ជាអនុប្រធាន ។ ជម្រកស្នាក់នៅជាប់គ្នាជាមួយឃុំប្រាសាទ និងឃុំកកោះហើយរបបហូបចុក ហូបតាមភូមិរៀងៗខ្លួន ។

ការដ្ឋានរលោះ ជាការដ្ឋានលើកប្រព័ន្ធភ្លឺស្រែ ដែលប្រកបទៅដោយគ្រោះថ្នាក់បំផុត ព្រោះរលោះត្រពាំងវែងគឺជាអតីតសមរភូមិក្តៅ ជាខ្សែក្រវ៉ាត់ការពារដ៏រឹងមាំទីរួមខេត្តកំពង់ធំ រាល់ៗលើកពេលដែលខ្មែរក្រហមបើកយុទ្ធនាការវាយប្រហារដើម្បីកាន់កាប់ខេត្តកំពង់ធំ គឺត្រូវបរាជ័យនៅនឹងសមរភូមិរលោះត្រពាំងវែងនេះឯង ។

គ្រាប់បន្សល់ពីសង្គ្រាមដែលមិនទាន់ផ្ទុះ គ្រាប់បែកទម្លាក់ដោយយន្តហោះរដ្ឋាភិបាលនៅពាសពេញ ។ រាល់ៗព្រឹកពេលចេញដំណើរពីខ្ទមទៅកាន់ការដ្ឋានម្នាក់ៗបន់ព្រះសំពះទេវតាអស់ហើយព្រោះពេលដែលយើងលើកចបកាប់មួយចបៗកាប់ទាំងប្រថុយប្រថានអាចនឹងកាប់ប៉ះគ្រាប់ផ្ទុះស្លាប់ឬរងរបួសដោយយថាហេតុ ។

មិនឆ្ងាយប៉ុន្មានពីមុខសញ្ញារបស់ស្រុកសន្ទុក នៅនឹងដីស្រែ

ប្រហែលបួនប្រាំហិកតាជាប់ៗគ្នា គេឃើញមានព្រះសង្ឃប្រមាណជាង១០អង្គកំពុងតែភ្ជួររាស់ ។ ក្រោយមកមិត្ត លន់ បានប្រាប់ពួកខ្ញុំថា សង្ឃទាំងប៉ុន្មានអង្គនោះប្រឆាំងនឹងបញ្ជារបស់អង្គការ រឹងទទឹងមិនព្រមសឹក ទើបអង្គការបញ្ជូនឲ្យមកភ្ជួររាស់នៅទីនេះ ។ មុនពេលដែលពួកយើងមកការដ្ឋានរលោះនេះ មានសង្ឃពីរអង្គសុគត ដោយភ្ជួរប៉ះគ្រាប់ផ្ទុះ ។

មុខសញ្ញារបស់ស្រុកស្ទោងដែលនៅជិតបង្កើយនឹងវត្តរលោះ ជាមុខសញ្ញាអកុសលបំផុត ដែលកាប់ប៉ះគ្រាប់ផ្ទុះញឹកជាងគេ ជួនកាលមានផ្ទុះគ្រាប់ស្លាប់ផ្ទួនៗគ្នាដល់ទៅពីរដងក្នុងមួយថ្ងៃ ។

រាល់ពេលដែលបានឮស្នូរគ្រាប់ផ្ទុះភ្លាម ពួកមិត្តពេទ្យបដិវត្តន៍ទាំងនៅទីស្នាក់ការ និងទាំងពួកមិត្តដែលនៅប្រចាំការតាមមុខសញ្ញាស្រុកនាំគ្នារត់សំដៅទៅកាន់កន្លែងកើតហេតុ ដែលយើងមើលពីចម្ងាយទៅឃើញដីនៅហុយទ្រលោមនៅឡើយ អ្នកដែលរងរបួសត្រូវបានពួកមិត្តសែងយកទៅព្យាបាលនៅមន្ទីរពេទ្យខេត្តកំពង់ធំ អ្នកដែលស្លាប់នៅនឹងកន្លែងត្រូវបានគេយកទៅកប់នៅវត្តរលោះ ។ ជិតមួយខែកន្លងមកនេះជាភ័ព្វសំណាងធំណាស់ ដែលមុខសញ្ញាស្រុកសន្ទុក ជាពិសេសឃុំកំពង់ថ្មទាំងមូលពុំមានជួបហេតុអកុសលអ្វីឡើយ ។

វាលរលោះ ជាវាលមួយដ៏ធំវែងឆ្ងាយដាច់កន្ទុយភ្នែក ពេលថ្ងៃធាតុអាកាសសែនក្តៅស្អុះស្អាប់ ដល់ពេលយប់ឡើងប្រែជាត្រជាក់រងាដោយទឹកសន្សើម ។ នៅវត្តរលោះ មានដើមចារមួយដើមធំ ដែលមានផ្កាសម្បុរក្រហមរីកសំយុងទម្លាក់រំយោលប្រោលដាសពាសពេញដើម គួរជាទីគយគន់ ។ នៅនឹងគល់ផ្កាចារមួយដើមនោះ ហើយអ្នកដែលស្លាប់ដោយគ្រាប់ផ្ទុះនៅនឹងការដ្ឋានត្រូវបានគេយកមកកប់តម្រៀបគ្នាជាជួរ ។

ល្ងាចៗឡើង ពេលចប់ពីការងារ មនុស្សទាំងហ្វូងៗនាំគ្នាដើរទៅដួតទឹកនៅឯស្ទឹងសែន ។ រោងស្នាក់នៅតាមឃុំខ្លះឆ្ងាយបន្តិចពីស្ទឹងសែន ពួកគេនាំគ្នាទៅដួតទឹកនៅឯបឹងរលោះវិញ ។ ទឹកសម្រាប់ហូប និងដាំស្ល គេបររទេះទៅដឹកពីបឹងរលោះ ឬបររទេះឆ្លងថ្នល់ជាតិទៅដឹកពីស្ទឹងសែន នៅនឹងព្រៃឈ្មោះក្បែរៗរោង មានដើមផ្តៅបន្លាជាច្រើន ដែលមីងៗបាននាំគ្នាកាប់យកមកដុត យកដេះទៅត្រាំទឹករួចដួសទឹកក្បុងថ្លាៗខាងលើទុកសម្រាប់កក់សក់ព្រោះគ្មានសាប៊ូ ។

ឃុំកកោះមិនជួបការលំបាកក្នុងការដឹកជញ្ជូនទឹកសម្រាប់ហូប និងសម្រាប់ដាំស្លទេ ព្រោះនៅក្បែរនឹងរោង សំណាក់មានអណ្តូងទឹកធំមួយ ។

ប្រមាណជាកន្លះខែកន្លងមកទៀត ល្ងាចថ្ងៃមួយគេនាំគ្នាផ្អើលទៅមើលអណ្តូងទឹកនៅនឹងរោងឃុំកកោះ ខ្ញុំក៏បានទៅមើលនឹងគេដែរ នៅនឹងបាតអណ្តូងខ្ញុំបានឃើញលលាដ៏ក្បាល និងឆ្អឹងខ្មោចមួយគំនរធំ ។ ល្ងាចថ្ងៃមួយ ពេលដើរត្រឡប់មកពីដួតទឹកឯមាត់ស្ទឹងសែនវិញ ដោយចៃដន្យខ្ញុំបានជួបបង ម៉ៅ អាយុទ្ធ ជាអ្នកនិពន្ធប្រលោមលោកដ៏ល្បីល្បាញ និងជាអ្នកដឹកនាំខ្សែភាពយន្តជាច្រើនរឿងផង ។ កាលនៅរៀនឯមហាវិទ្យាល័យទួលស្វាយព្រៃ ខ្ញុំធ្លាប់បានជួបស្គាល់គាត់ម្តងក្នុងឱកាសទិវាអក្សរសាស្ត្រខ្មែរមួយដែលរៀបចំឡើងដោយសមាគមសិស្សនៃវិទ្យាល័យទួលស្វាយព្រៃ ។

បង ម៉ៅ អាយុទ្ធ គាត់រស់នៅក្នុងឃុំកកោះ ជាមួយប្រពន្ធ និងកូនស្រីគាត់នៅនឹងភូមិតូចមួយជាប់នឹងជើងភ្នំសន្ទុក គាត់បានប្រាប់ឈ្មោះភូមិនោះដែរ តែខ្ញុំភ្លេចបាត់សូន្យឈឹង ហើយនៅនឹងការដ្ឋាន គាត់ត្រូវបានគេហៅឈ្មោះ បងម៉ៅៗ ។ ទាំងចរិត កាយវិការ និងសំដីសំដៅរបស់គាត់ដែលជាសិល្បករគឺនៅដដែល ។ ខ្ញុំបានឆ្លៀតនិយាយលេងនឹងគាត់ថា បងយើងឮស្នូរស្នូរកញ្ចែស្ទុះក្រោករកចបរកបង្គីរាល់ព្រឹកនេះ ជាការពិតណា មិនមែនជាការសម្តែងទេ!...បងម៉ៅ សើចទាំងងក់ក្បាលតិចៗដាក់ខ្ញុំ ។

ឆ្លៀតឱកាសស្ងាត់ដែលគាត់ឈរជជែកជាមួយខ្ញុំតែពីរនាក់ក្បែរមាត់ស្ទឹង និងដោយពុំមានអ្នកណាមករំខានយើងនោះ ខ្ញុំក៏បានសួរគាត់ទៀតថា មុនពេលដាច់ភ្នំពេញ មនុស្សច្រើនណាស់ដែលឆក់ឱកាសចេញទៅក្រៅ បងមិនមែនគ្មានលទ្ធភាពទេ ចុះម៉េចបងមិនចេញទៅឲ្យបាត់នឹងគេ? បងម៉ៅ សើចយកដៃមកក្បៀកស្មាខ្ញុំ ហើយយើងបោះជំហានដើរទៅមុខព្រមគ្នា ដើរបណ្តើរគាត់បានពោលប្រាប់ខ្ញុំបណ្តើរថា បងជាមនុស្សម្នាក់ស្រឡាញ់ស្រុក ស្រឡាញ់ទេសខ្លាំងណាស់ បងឈានជើងចាកចេញទៅដូចគេម៉េចនឹងរួច បើបងស្រឡាញ់វាលស្រែ ស្រឡាញ់ដើមត្នោតយ៉ាងហ្នឹងៗ!... ។

**(តទៅលេខក្រោយ)**

**ប៉ុក ប៉ុនសូម៉ាង**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៧៩៧ ៣៩៤ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាសយដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។










ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានគ្រឹះសំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 190, 2015 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.